សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics
១៣៣*៧៧

## សារណាបញ្ចប់ការសិក្សា

# ទ្រព្យសម្បត្តិសហព័ទ្ធ នៅព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវដោយ

សុន ប៉ារ៉ាដា

អំ សុវណ្ណដា

សាស្ត្រាចារ្យណែនាំ

បណ្ឌិត ព្រុំ រិទ្ធី

ជំនាញ នីតិសាស្ត្រ

២០១៨

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

កាលដើមឡើយ មនុស្សរស់នៅជាមួយគ្នាតាមធម្មជាតិ ឬអាចនិយាយពាក្យសាមញ្ញថាតាមច្បាប់ព្រៃ។ ការវិវត្តរបស់មនុស្សពីសម័យកាលមួយទៅសម័យកាលមួយ បានបង្កើតឲ្យមានការចងភ្ជាប់រវាងគ្នានឹងគ្នា រហូតមកដល់ពេលបច្ចុប្បន្ននេះ ការចងភ្ជាប់ទាំងនោះគឺដោយចំណងគតិយុត្តដែលមនុស្សបានបង្កើតឡើងដើម្បីឱ្យមានភាពល្អប្រសើរ និងមានលក្ខណៈត្រឹមត្រូវតាមបរិបទនៃសង្គមនីមួយៗ។ ការបង្កើតឱ្យមានលក្ខណៈគតិយុត្តត្រឹមត្រូវបែបនេះ គឺក្នុងគោលបំណងដើម្បីឱ្យការរស់នៅមានភាពត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាពរវាងគ្នានឹងគ្នា និងដើម្បីបញ្ចៀសនូវរាល់បញ្ហាដែលអាចនឹងកើតមានឡើងទាំងពេលបច្ចុប្បន្ន និងទៅអនាគត។ ដោយសារមនុស្សរស់នៅក្នុងសង្គមមានទ្រព្យសម្បត្តិផ្ទាល់ខ្លួនរៀងៗខ្លួន វាអាចធ្វើឲ្យទំនាក់ទំនងរវាងបុគ្គលនិងបុគ្គលមានភាពលំបាកដោយពាក់ព័ន្ធទៅនឹងកម្មសិទ្ធិ។ ហេតុនេះហើយ ទើបទំនាក់ទំនងរវាងបុគ្គលពីររូប ជាពិសេសការកើតឡើងតាមរយៈអាពាហ៍ពិពាហ៍អាចប្រឈមមុខនឹងភាពលំបាកផ្សេងៗ ដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិនៃបុគ្គលទាំងពីរ។ ហើយប្រសិនបើបុគ្គលពីររូបរស់នៅជាមួយគ្នាដោយមិនរៀបអាពាហ៍ពិពាហ៍ និងចុះសំបុត្រអាពាហ៍ពិពាហ៍ទេនោះ ការពិភាក្សាគ្នាទៅលើទ្រព្យសម្បត្តិអាចបង្ករជាបញ្ហាធំបាន។ ប្រទេសមួយចំនួននៅតំបន់អឺរ៉ុបមានប្រជាជនភាគច្រើនដែលរស់នៅតាមលក្ខណៈខាងលើ ឬ អនីតិសង្វាស ប៉ុន្តែគេមានវិធីសាស្ត្ររបស់គេក្នុងការគ្រប់គ្រងទៅលើបញ្ហានេះដែរ។ ដោយឡែក ព្រះរាជាណាចក្រកម្ពុជា ដែលជាប្រទេសដែលមានអរិយធម៌ដ៏រុងរឿងមិនទទួលស្គាល់ការរស់នៅបែបនេះតាំងពីដើមរៀងមក ព្រោះជាទំលាប់មួយដែលមិនសមរម្យ និងប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ ជាពិសេសអាចបង្កជាការលំបាកនៅពេលដែលមានវិវាទជាដើម។ ហេតុនេះហើយ ទើបគ្រួសារនីមួយៗនៅក្នុងសង្គមត្រូវបានការពារយ៉ាងពេញលេញដោយច្បាប់ ចំពោះការគ្រប់គ្រងលើទ្រព្យសម្បត្តិ។

អាស្រ័យហេតុនេះហើយ ទើបក្រុមយើងខ្ញុំលើកយកប្រធានបទទាក់ទងនឹង ទ្រព្យសម្បត្តិសហព័ទ្ធ មកធ្វើការតាក់តែង និងធ្វើការបកស្រាយ។ ប្រធានបទនេះ មានលក្ខណៈពិសេសដោយវាចូលរួមក្នុងការកាត់បន្ថយនូវរាល់ការអនុវត្តជាក់ស្តែងណាមួយដែលមិនប្រក្រតី ឬផ្តល់ភាពត្រឹមត្រូវមិនពេញដល់ភាគីពាក់ព័ន្ធ។

## ២. ចំណោទបញ្ហា

តើអ្វីទៅជា ទ្រព្យសម្បត្តិសហព័ទ្ធ ដែលមាននៅក្នុងចំណងអាពាហ៍ពិពាហ៍ក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា? តើមានមូលហេតុអ្វីដែលត្រូវសិក្សាយល់ដឹងអំពី ទ្រព្យសម្បត្តិសហព័ទ្ធ?

ទ្រព្យសម្បត្តិប្ដីប្រពន្ធនៅក្នុងចំណងអាពាហ៍ពិពាហ៍ អាចត្រូវបានបែងចែកជាប៉ុន្មានប្រភេទ? តើសហព័ទ្ធអាចប្រើប្រាស់ទ្រព្យទាំងនោះដោយរបៀបណា? ប្រសិនបើមានបញ្ហាណាមួយកើតឡើងពាក់ព័ន្ធនឹងការផ្ដាច់ចំណងគ្រួសារ តើនឹងត្រូវដោះស្រាយយ៉ាងដូចម្ដេចទៅលើទ្រព្យនោះ?

## ៣. គោលបំណង

គោលបំណងនៃប្រធានបទមួយនេះ គឺដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់អំពីទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលកើតមានដោយសារអាពាពិពាហ៍ពិពាហ៍ ព្រមទាំងការគ្រប់គ្រង ចាត់ចែងនៅក្នុងរង្វង់គ្រួសារ។ ប្រធានបទមួយនេះនឹងផ្ដល់ភាពងាយស្រួលតាមដែលអាចធ្វើទៅបានដល់ប្ដីប្រពន្ធក្នុងការគិតពិចារណាអំពីទ្រព្យសម្បត្តិដែលពួកគេមានស្រាប់ និងនឹងមាននៅពេលអនាគត។ ទោះជាមានបញ្ញត្តិដែលច្បាប់បានកំណត់ក៏ពិតមែន វានៅតែមានចំណុចខ្លះដែលខ្វះខាត ឬធ្វើឲ្យអ្នកច្បាប់មួយចំនួនមានការលំបាកក្នុងការស្វែងរកដំណោះស្រាយ នៅពេលដែលជួបប្រទះបញ្ហាណាមួយថ្មីដែលមិនធ្លាប់កើតមាន។ ហេតុនេះ ប្រធានបទមួយនេះអាចផ្ដល់ជាជំនួយស្មារតី ឬដំណោះស្រាយថ្មីខ្លះៗដែលជាជំនួយដល់ការដោះស្រាយវិវាទដែលអាចនឹងកើតមានឡើង។

លើសពីនេះ ប្រធានបទមួយនេះនឹងបង្ហាញអំពីគោលគំនិតទៅលើទ្រព្យសម្បត្តិ ថាតើប្ដីប្រពន្ធអាចធ្វើអ្វីបានខ្លះជាមួយនឹងទ្រព្យសម្បត្តិដែលពួកគេមានទាំងការគ្រប់គ្រងគ្រួសារផ្ទាល់ និងការប្រើប្រាស់ផ្សេងទៀត។ បន្ថែមពីលើនេះ វាផ្ដល់ជាមធ្យោបាយដល់ប្រជាជននូវវិធីសាស្ត្រក្នុងការបែងចែកទ្រព្យនៅពេលផ្ដាច់ចំណងអាពាហ៍ពិពាហ៍ជាដើម។

## ៤.ដែនកំណត់ និងវិសាលភាព

ប្រធានបទនេះ បង្ហាញអំពី ទ្រព្យសម្បត្តិដែលសហព័ទ្ធមាន ដែលអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន និងដែលមានដែនកំណត់ក្នុងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ អំពីទម្រង់ការនៃប្រភេទទ្រព្យសម្បត្តិដែលសហព័ទ្ធមាន ព្រមទាំងដំណោះស្រាយចំពោះការបែងចែកទ្រព្យជូនប្ដីប្រពន្ធ ដែលធ្វើឡើងដោយអ្នកច្បាប់ និងស្ថាប័នពាក់ព័ន្ធដែលស្ថិតនៅព្រះរាជាណាចក្រកម្ពុជា។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃប្រធានបទនេះ គឺចែករំលែកចំណេះដឹងមិត្តនិស្សិត និងប្រជាជនទាំងអស់ឱ្យបានយល់ច្បាស់អំពីទ្រព្យសម្បត្តិប្ដីប្រពន្ធ និងទំហំនៃការចាត់ចែង និងបែងចែក។ ដោយយល់ឃើញថា ប្រជាជនមួយចំនួននៅមានភាពស្រពិចស្រពិលទៅលើទ្រព្យសម្បត្តិ ក៏ដូចជាសិទ្ធិដែលខ្លួនឯងមានទៅលើទ្រព្យនោះ ទើបធ្វើឱ្យមានបញ្ហាកើតឡើងជាច្រើនចំពោះប្ដីប្រពន្ធ ពិសេសគឺការបែងចែកទ្រព្យ។

សារៈសំខាន់មួយទៀត គឺដើម្បីកាត់បន្ថយនូវការចាត់ប្រភេទទ្រព្យ ការគ្រប់គ្រងថែរក្សា ដែលផ្ទុយពីបញ្ញត្តិច្បាប់ ឬនីតិវិធីរបស់តុលាការ ឬការចាត់ប្រភេទទ្រព្យដែលរំលោភបំពានដល់ភាគីម្ខាងទៀត ដោយធ្វើយ៉ាងណាឱ្យមានលក្ខណៈល្អប្រសើរ និងមានភាពយុត្តិធម៌។ ម្យ៉ាងវិញទៀត វានឹងរួមចំណែកឱ្យប្រព័ន្ធច្បាប់នៅកម្ពុជាមានភាពល្អប្រសើរ។ ប្រសិនបើទទួលបានជោគជ័យមែន នោះប្រព័ន្ធច្បាប់ដែលអនុវត្តន៍ទៅលើទ្រព្យសម្បត្តិនឹងមានភាពល្អប្រសើរ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំបានបែងចែកជា ៣ ជំពូកដូចជា៖

### ជំពូកទី១ ៖ សញ្ញាណទូទៅនៃទ្រព្យសម្បត្តិ

ក្នុងផ្នែកនេះ វាសម្តៅទៅលើការបង្ហាញអំពីអត្ថិភាពនៃប្រភេទទ្រព្យដែលអាចកើតមានដូចជា ការកំណត់របស់សហព័ទ្ធទាំងសងខាង និងការកំណត់របស់ច្បាប់។

១.១. ទ្រព្យសម្បត្តិដែលសហព័ទ្ធកំណត់តាមកិច្ចសន្យា

១.២. ទ្រព្យសម្បត្តិសហព័ទ្ធដែលកើតមានតាមច្បាប់កំណត់

### ជំពូកទី២ ៖ ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិប្តីប្រពន្ធ

ចំណុចនេះ នឹងផ្តោតសំខាន់ទៅលើសេរីភាពរបស់សហព័ទ្ធដែលអាចគ្រប់គ្រង និងចាត់ចែងលើទ្រព្យសម្បត្តិរបស់ខ្លួនទាំងទ្រព្យដែលមានពិតប្រាកដ និងកាតព្វកិច្ច។

២.១. ការគ្រប់គ្រង និងការចាត់ចែងលើទ្រព្យសកម្ម

២.២. ការគ្រប់គ្រង និងការចាត់ចែងលើទ្រព្យអកម្ម

២.៣. ករណីសហព័ទ្ធអសមត្ថភាព ឬអវត្តមាន

### ជំពូកទី៣ ៖ ការបែងចែកទ្រព្យ

៣.១. សន្តតិកម្ម

៣.២. ការបាត់ខ្លួន

៣.៣. ការលែងលះ

ខ្លឹមសារលម្អិតទាំងអស់នៃប្រធានបទនេះ នឹងធ្វើការបកស្រាយដូចខាងក្រោម៖

# ជំពូកទី ១៖ សញ្ញាណទូទៅនៃទ្រព្យសម្បត្តិ

## ផ្នែកទី១៖ ទ្រព្យសម្បត្តិដែលសហព័ទ្ធកំណត់តាមកិច្ចសន្យា

ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា គឺជាប្រព័ន្ធមួយដែលអនុញ្ញាតឱ្យប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិដែលពួកគេមាន នៅមុន ឬ ក្រោយពេលអាពាហ៍ពិពាហ៍បានដោយផ្អែកលើឆន្ទៈរបស់ពួកគេ។ ប៉ុន្តែ កិច្ចសន្យាប្រភេទនេះ អាចធ្វើទៅបានដោយមិនត្រូវផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ចនិងភាគបម្រុងបានឡើយ។[1] ក្នុងន័យនេះ ប្តីប្រពន្ធមានសេរីភាពពេញលេញក្នុងការបង្កើតកិច្ចសន្យានេះឡើងប៉ុន្តែច្បាប់បានកម្រិតនូវលក្ខខណ្ឌ ដែលមិនអនុញ្ញាតឱ្យប្តី ប្រពន្ធ បោះបង់ចោលសិទ្ធិសំខាន់ៗដូចជាសិទ្ធិទាមទារអាហារកាតព្វកិច្ច និងសិទ្ធិលើភាគបម្រុងបានឡើយ។

### ១.១. យន្តការនៃប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

#### ១.១.១. គោលគំនិតនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ការបង្កើតឱ្យមានឡើងនូវប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺក្នុងគោលបំណងឱ្យការកំណត់នូវទ្រព្យសម្បត្តិរបស់សហព័ទ្ធទាំងសងខាងមានភាពពិតប្រាកដ ច្បាស់លាស់ មិនថាទ្រព្យនោះជាប្រភេទអចលនទ្រព្យ ឬ ចលនទ្រព្យនោះទេ។ ក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ សហព័ទ្ធទាំងសងខាងអាចកំណត់ពីទំនាក់ទំនងសិទ្ធិ ករណីយកិច្ច និង ទំនាក់ទំនងទ្រព្យសម្បត្តិដែលមានលក្ខណៈជាក់ស្តែង ទៅតាមឆន្ទៈរបស់ពួកគេរៀងៗខ្លួន។ កិច្ចសន្យានេះអាចមានភាពបត់បែន ឬផ្លាស់ប្តូរទៅតាមទំហំនៃទ្រព្យសម្បត្តិ និងប្រភពចំណូលរបស់ពួកគេ។ វាបានផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនទៅដល់សហព័ទ្ធដូចខាងក្រោមនេះ។

##### ១.១.១.១. ការការពារអត្ថប្រយោជន៍សហព័ទ្ធទាំងសងខាង

ដោយយោងទៅតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានអនុញ្ញាតឱ្យបុគ្គលដែលជាប្តីប្រពន្ធធ្វើការចុះកិច្ចសន្យាទ្រព្យសម្បត្តិ មុន ឬ ក្រោយអាពាហ៍ពិពាហ៍បានដែលជាលក្ខណៈពិសេសក្នុងការធ្វើអោយមានភាពងាយស្រួល ក្នុងការធ្វើឱ្យច្បាស់ការនូវទំនាក់ទំនងសិទ្ធិ និង ករណីយកិច្ចរបស់ប្តីប្រពន្ធ។ នៅក្នុងកិច្ចសន្យា ការកំណត់អំពីចំណែកទ្រព្យ ឬការទទួលខុសត្រូវរបស់ភាគីនីមួយៗមានភាពប្រាកដ ដូច្នេះវាបានការពារផលប្រយោជន៍ភាគីម្ខាងចំពោះសិទ្ធិសេរីភាពលើការគ្រប់គ្រងទ្រព្យ និង ការការពារពីការបំពានពីសហព័ទ្ធម្ខាងទៀត។

[1] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៦៩ កថាខណ្ឌ១។

### ក. ការកំណត់លើសិទ្ធិ និង កាតព្វកិច្ចក្នុងកិច្ចសន្យា

ដោយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អនុញ្ញាតដល់សហព័ទ្ធក្នុងការកំណត់នូវសិទ្ធិ និង កាតព្វកិច្ចនោះប្តីប្រពន្ធទាំងសងខាងអាចកំណត់នូវ "ខ" ដែលពាក់ព័ន្ធទៅនឹងទ្រព្យរួម ទ្រព្យដោយឡែកដូចជា៖

- ទ្រព្យរួមទទួលខុសត្រូវរួម :

  ចំពោះសោហ៊ុយអាពាហ៍ពិពាហ៍ប្តីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយពិចារណាទៅលើទ្រព្យសម្បត្តិប្រាក់ចំណូល និង ស្ថានភាពផ្សេងៗទៀត។[2] ប្តីប្រពន្ធត្រូវមានករណីយកិច្ចក្នុងការចំណាយលើជីវភាពរួមនៃអាពាហ៍ពិពាហ៍ ដោយតម្រូវឱ្យសហព័ទ្ធចែករំលែកសោហ៊ុយនេះទៅតាមទំហំនៃប្រាក់ចំណូល ឋានៈការងារ និង មុខរបររបស់ពួកគេ។ ការចំណាយលើសោហ៊ុយរួមសម្រាប់អាពាហ៍ពិពាហ៍ មិនមែនសំដៅតែលើការចំណាយលើសំលៀកបំពាក់ ម្ហូបអាហារប្រចាំថ្ងៃ ការស្នាក់នៅនោះទេ តែសំដៅដល់ការចំណាយលើការសិក្សា និង ថែទាំកូនផងដែរ។

ករណីដែលមានសហព័ទ្ធណាដែលមិនបានបំពេញកាតព្វកិច្ចនៃសោហ៊ុយអាពាហ៍ពិពាហ៍នេះទេ សហព័ទ្ធម្ខាងទៀតអាចធ្វើការស្នើសុំទៅតុលាការឱ្យចេញដីការសម្រេចអំពីសោហ៊ុយអាពាហ៍ពិពាហ៍នេះបាន។ ឧទាហរណ៍៖ នៅក្នុងនីតិវិធីរឿងក្តីមិនមែនជាបណ្តឹងក្នុងការសាងសង់ផ្ទះមួយខ្នងសោហ៊ុយចំណាយទៅលើផ្ទះមួយខ្នងនោះជាកាតព្វកិច្ចរបស់អ្នកទាំងពីរ។ រាល់សោហ៊ុយនានាដែលតម្រូវឱ្យចំណាយលើផ្ទះនេះ ដូចជាការជួសជុល ការថែទាំ ជាដើម សហព័ទ្ធទាំងពីរត្រូវទទួលខុសត្រូវរួមគ្នា។

- ការទទួលខុសត្រូវដោយសាមគ្គី :

  ការទទួលខុសត្រូវដោយសាមគ្គីមានន័យថា ជាការចូលរួមដោយសាមគ្គីភាពរបស់សហព័ទ្ធនៅក្នុងសោហ៊ុយអាពាហ៍ពិពាហ៍ រួមទាំងបំណុល។

ចំពោះទំនាក់ទំនងបំណុលនានាជាមួយតតិយជន ដែលកើតមានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ សហព័ទ្ធត្រូវទទួលខុសត្រូវដោយសាមគ្គីលើកលែងតែ ករណីសហព័ទ្ធណាម្នាក់បានព្រមព្រៀងគ្នាថានឹងមិនទទួលខុសត្រូវចំពោះបំណុលដោយឡែករបស់សហព័ទ្ធម្ខាងទៀតនោះទេ។ ប៉ុន្តែប្រសិនបើបំណុលណាដែលកើតឡើងដោយសារការបម្រើដល់ប្រយោជន៍រួម ដូចជាការផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ សហព័ទ្ធត្រូវទទួលខុសត្រូវដោយសាមគ្គី។

[2] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៧១។

- ការតតាំងនឹងតតិយជន :

  ករណីសហព័ទ្ធណាម្នាក់ជាប់ទំនាក់ទំនងបំណុល ជាមួយតតិយជន នោះសហព័ទ្ធដែលជាភាគីក្នុងកិច្ចសន្យានោះត្រូវតតាំងដោយផ្ទាល់ជាមួយម្ចាស់បំណុល។ ប៉ុន្តែសួរថាតើកម្មវត្ថុនៃបំណុល សហព័ទ្ធខ្ចីដើម្បីអ្វី?

- ប្រសិនបើបំណុលដែលខ្ចីមកនោះកើតឡើងដោយសារតែ ការប្រើប្រាស់ផ្គត់ផ្គង់គ្រួសារ ឬ ក្នុងករណីចាំបាច់ណាមួយ ក្នុងគោលដៅបម្រើដល់ប្រយោជន៍រួម នោះត្រូវមានការសាមគ្គីពីភាគីម្ខាងទៀត ក្នុងការតតាំងចំពោះតតិយជន។
- ប្រសិនបើបំណុលដែលខ្ចីមកនោះកើតឡើងដោយសារតែ ប្រយោជន៍របស់សហព័ទ្ធម្ខាង ដែលមិនមែនសម្រាប់បម្រើដល់ប្រយោជន៍រួម មិនគួរឱ្យមានការសាមគ្គីពីភាគីសហព័ទ្ធម្ខាងទៀតនោះទេ។

ទោះជាកិច្ចសន្យាប្តីប្រពន្ធនេះទាមទារឱ្យមាននូវការគោរពឆន្ទៈរបស់ភាគីទាំងសងខាងក៏ដោយ ក៏កិច្ចសន្យានេះត្រូវតែមានភាពស្មើគ្នាលើសិទ្ធិមូលដ្ឋាននានាដូចជា ការទំនុកបម្រុងលើជីវភាពគ្រួសារ និង ឯករាជ្យភាពរបស់សហព័ទ្ធ។

**<u>ឧទាហរណ៍៖</u>**លោក ក ចង់កំណត់បង្កើតនូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះជាមួយដោយអ្នកនាង ខ ដើម្បីកំណត់នូវការចាយវាយក្នុងគ្រួសារដូចជា សោហ៊ុយចំណាយលើការទិញម្ហូប ការបង់ថ្លៃទឹក ថ្លៃភ្លើង ការបង់ថ្លៃសាលាកូន ជាបន្ទុកម្នាក់ពាក់កណ្តាលស្មើៗគ្នា តើលោក ក និង អ្នកនាង ខ អាចបង្កើតកិច្ចសន្យានេះបានដែរឬទេ?

**ចម្លើយ៖** អ្នកទាំងពីរនេះអាចបង្កើតកិច្ចសន្យាបែបនេះបាន បើសិនពួកគេទាំងពីរនាក់មានប្រាក់ចំណូលប្រហាក់ប្រហែលគ្នា។ ប៉ុន្តែ បើសិនជាអ្នកនាង ខ ឬ លោក ក ជាអ្នកគ្មានការងារធ្វើ មិនមានប្រាក់ចំណូល តើគួរតែជួយចំណាយម្នាក់ពាក់កណ្តាលទៀតឬទេ?

យើងឃើញថាក្នុងសង្គមខ្មែរភាគច្រើនស្ត្រីជាប្រពន្ធតែងតែជាស្ត្រីមេផ្ទះ មិនសូវមានប្រាក់ចំណូល ឬ មិនមានប្រាក់ចំណូលតែម្តង ដោយការចំណាយនានាក្នុងផ្ទះ ជាប្រាក់ចំណូលបានមកពីប្តីតែម្នាក់។ ប៉ុន្តែសួរថា តើពួកគាត់មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ប្រាក់ចំណូលនោះទៅលើសោហ៊ុយប្រចាំថ្ងៃឬទេ? ដោយយោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃដែលរកបានពីការងារធ្វើនៅក្រៅផ្ទះ។[3] ត្រង់នេះមានន័យថាច្បាប់ការពារដល់សហព័ទ្ធដែលមានការងារជាមេផ្ទះ។[4] សរុបមកវិញប្រាក់ចំណូលដែលបានមកពីសហព័ទ្ធម្ខាងសហព័ទ្ធម្ខាងទៀតក៏មានសិទ្ធិប្រើប្រាស់ដែរ ប៉ុន្តែក្នុងគោលដៅបម្រើប្រយោជន៍រួម។

[3] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា២០១០, មាត្រា៣៦ កថាខណ្ឌ៣។

[4] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៨០ កថាខណ្ឌ៣។

## ខ. កំណត់ពីសិទ្ធិគ្រប់គ្រង និង ចាត់ចែងទ្រព្យសម្បត្តិក្នុងកិច្ចសន្យា

- **ការគ្រប់គ្រង** :

នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ សហព័ទ្ធអាចព្រមព្រៀងគ្នា ថាទ្រព្យណាជាទ្រព្យរួម ទ្រព្យណាជាទ្រព្យដោយឡែកបាន តាមឆន្ទៈភាគីទាំងសងខាងតែមិនអាចបំពានប្រយោជន៍ភាគីណាម្ខាងបានឡើយ។ ក្នុងការបង្កើតកិច្ចសន្យានេះ ការគ្រប់គ្រង និង ចាត់ចែងទ្រព្យសម្បត្តិរួមក៏មិនអាចប្រាកចាកពីបញ្ញត្តិនៃទ្រព្យសម្បត្តិប្ដីប្រពន្ធតាមច្បាប់ដែរ។ ប្ដីប្រពន្ធ មានសិទ្ធិស្មើៗគ្នាក្នុងការ ប្រើប្រាស់ គ្រប់គ្រងទ្រព្យសម្បត្តិដែលជាទ្រព្យរួមបាន ក៏ដូចជាទទួលផលប្រយោជន៍ដែលចេញពីទ្រព្យរួមនោះ។ ចំណែកទ្រព្យសម្បត្តិដោយឡែក ពួកគេក៏មានសិទ្ធិគ្រប់គ្រង ប្រើប្រាស់ និងទទួលផលប្រយោជន៍បានរៀងៗខ្លួន។ សហព័ទ្ធត្រូវប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់សម្រាប់ខ្លួនឯង និងសម្រាប់ជីវភាពគ្រួសារ។ ការគ្រប់គ្រងទ្រព្យសម្បត្តិ ត្រូវធ្វើឡើងដោយមានការសហការគ្នាល្អរវាងប្ដី និង ប្រពន្ធ។ ក្នុងករណីណាមួយទាក់ទងនឹងភាពចាំបាច់សម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរួម សហព័ទ្ធម្ខាងអាចទាមទារឱ្យសហព័ទ្ធម្ខាងទៀតធ្វើចំណាត់ការបាន។ ប៉ុន្តែ បើការពិភាក្សាគ្នាលើការគ្រប់គ្រងទ្រព្យសម្បត្តិរួមមិនទទួលបានជោគជ័យ ឬ ភាគីមានភាពស្រពិចស្រពិល នោះពួកគេអាចទាមទារអោយតុលាការធ្វើការចាត់ចែងបាន។[5]

**ឧទាហរណ៍៖** លោក ក និង អ្នកនាង ខ ជាប្ដីប្រពន្ធនឹងគ្នា។ ពួកគេបានបង្កើត កិច្ចសន្យាប្ដីប្រពន្ធដែលក្នុងនោះពួកគេបានដាក់ផ្ទះមួយខ្នង និង រថយន្តមួយគ្រឿងជាទ្រព្យរួម។ ដូចនេះផ្ទះមួយខ្នង និង រថយន្តមួយគ្រឿងនេះ សហព័ទ្ធទាំងសងខាងអាចប្រើប្រាស់ គ្រប់គ្រងបានដូចគ្នា។ចំណែកឯការទាញយកផលប្រយោជន៍ពីទ្រព្យរួមនេះពួកគេក៏មានសិទ្ធិស្មើគ្នាផងដែរ។ បើសិនទ្រព្យរួមដែលជាផ្ទះ និង រថយន្តនេះមានការខូចខាត ភាគីទាំងពីរក៏មានសិទ្ធិស្មើគ្នាក្នុងការជួសជុល ឬទទួលយកបំណុលដែលកើតឡើងពីការគ្រប់គ្រងទ្រព្យរួមនេះ។

- **ការចាត់ចែង** :

នៅក្នុងការចាត់ចែងលើទ្រព្យសម្បត្តិ កិច្ចសន្យានេះអាចកំណត់នូវសិទ្ធិរបស់សហព័ទ្ធណាឱ្យធ្វើការចាត់ចែងលើទ្រព្យណាមួយបាន ដោយផ្អែកលើកម្មសិទ្ធិជាក់ស្តែងរបស់សហព័ទ្ធណាមួយ។ សហព័ទ្ធអាចកំណត់ថាទ្រព្យដោយឡែកណាមួយអាចឱ្យមានការចាត់ចែងរួមដូចជាទ្រព្យរួមបាន។ប៉ុន្តែទ្រព្យរួម មិនអាចធ្វើការ

[5] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៧៥។

ចាត់ចែងដោយឡែកបានទេ លើកលែងករណីចាំបាច់សម្រាប់ផ្គត់ផ្គង់គ្រួសារ។ វាមានលក្ខណៈស្រដៀងគ្នានឹងបញ្ញត្តិនៃច្បាប់ដែរ ការចាត់ចែងទ្រព្យរួម ត្រូវមានការយល់ព្រមពីសហព័ទ្ធទាំងសងខាង លើកលែងករណីចាំបាច់មួយចំនួនទាក់ទងនឹងការថែទាំជីវភាពគ្រួសារ នោះគឺអាចអនុញ្ញាតឱ្យសហព័ទ្ធណាម្នាក់ធ្វើការលក់ ឬចាត់ចែងផ្សេងទៀតបានដោយមានការអនុញ្ញាតពីតុលាការ។

មានការលើកឡើងថា បើសិនមានករណីចាំបាច់ដូចជាសហព័ទ្ធណាម្ខាងមានជំងឺ ឬ ហេតុការណ៍បន្ទាន់ណាមួយដែលចាំបាច់ត្រូវធ្វើការចាត់ចែងទ្រព្យរួម បើសិនសហព័ទ្ធម្ខាងទៀតមិនអាចធ្វើស្ទីការបាន តើត្រូវរង់ចាំសាលក្រមអនុញ្ញាតពីតុលាការដែរឬទេ? ករណីនេះបើសិនជានៅរង់ចាំការអនុញ្ញាតរបស់តុលាការ ឬ ពីសហព័ទ្ធម្ខាងទៀតដែលមិនអាចធ្វើស្ទីការបាន ឬ មានកត្តារាំងស្ទះណាមួយ នោះសហព័ទ្ធដែលចាំបាច់ត្រូវចាត់ចែងទ្រព្យនោះបានដោយមិនចាំបាច់មានស្ទីការពីសហព័ទ្ធម្ខាងទៀត ឬ ការអនុញ្ញាតពីតុលាការទេ។ បើសិនមាន ព្យសនកម្មដែលកើតឡើងក្រោយការចាត់ចែង សហព័ទ្ធម្ខាងដែលមិនបានធ្វើស្ទីការអាចទាមទារអោយលុបចោលការចាត់ចែងនោះបានដូចដែលរៀបរាប់ខាងលើ។

**ឧទាហរណ៍៖** លោក ក និង អ្នកនាង ខ ជាប្តីប្រពន្ធនឹងគ្នា។ អ្នកទាំងពីរក៏បានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិផងដែរ ។ ថ្ងៃមួយ អ្នកនាង ខ ដែលជាប្រពន្ធមានជំងឺជាទម្ងន់ដែលត្រូវការប្រាក់បន្ទាន់ដើម្បីវះកាត់។ លោក ក គ្មានជម្រើសផ្សេងក្រៅពីយកទ្រព្យរួម ទៅលក់យកប្រាក់ដើម្បីមកព្យាបាលប្រពន្ធនោះទេ ទោះជាវាផ្ទុយទៅនឹងបញ្ញត្តិនៃកិច្ចសន្យាក៏ដោយ ព្រោះនេះទាក់ទងនឹងអាយុជីវិត។ ករណីនេះ ការចាត់ចែងមិនចាំបាច់មានស្ទីការពីភរិយាគាត់ទេ ដោយសារតែអ្នកនាង ខ មិនអាចធ្វើស្ទីការបាន ហើយក៏មិនចាំបាច់រង់ចាំ ការអនុញ្ញាតពីតុលាការដែរដោយសារមានរយៈពេលយូរមិនអាចរង់ចាំបាន។

### ១.១.១.២. ការរួមចំណែកក្នុងនីតិវិធីដោះស្រាយរបស់តុលាការ

នៅពេលសហព័ទ្ធដែលមិនបានប្រើប្រាស់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនេះទេ វាបានផ្តល់ភាពពិបាកពេលដែលពួកគេដាក់ពាក្យបណ្តឹងលែងលះទៅតុលាការ ដោយតុលាការមានការលំបាកក្នុងការបើកការស៊ើបអង្កេតលើទ្រព្យសម្បត្តិទាំងអស់ ហើយកំណត់ថា តើទ្រព្យណាមួយជាទ្រព្យដោយឡែក ទ្រព្យណាមួយជាទ្រព្យរួម។ ម្យ៉ាងទៀតវាបានធ្វើឱ្យការងារនេះមានការយឺតយ៉ាវដោយសារវាត្រូវការរយៈពេលយូរទៅតាមនីតិវិធី។ នៅពេលដែលសហព័ទ្ធបានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះឡើង វាបានជួយសម្រួលនីតិវិធីនានានៅពេលមានវិវាទដូចជា៖

#### ក. វិវាទអំពីទ្រព្យពេលលែងលះ

បើគ្មានកិច្ចសន្យាត្រូវឆ្លងកាត់នីតិវិធីតុលាការជាច្រើន។ ក្នុងពេលដែលសហព័ទ្ធធ្វើការលែងលះគ្នាអ្វីដែលមានភាពស្មុគស្មាញជាងគេគឺលើការបែងចែកទ្រព្យ។ ករណីដែលសហព័ទ្ធ

មិនបានធ្វើការចុះបញ្ជីទ្រព្យសម្បត្តិពីមុនមកទេ តុលាការត្រូវបើកនីតិវិធីស៊ើបអង្កេតលើទ្រព្យ និង បំណុលទាំងអស់ដែលសហព័ទ្ធមាន។ ជាក់ស្តែង តុលាការធ្វើការស្តាប់ ការអះអាងរបស់ភាគីទាំងសងខាងទៅលើទ្រព្យហើយធ្វើការសន្មតលើប្រភេទទ្រព្យតាមរយៈភស្តុតាងជាក់ស្តែង។ ករណីដែលទ្រព្យដែលសហព័ទ្ធណាមួយមានមុនពេលរៀបអាពាហ៍ពិពាហ៍ សន្តតិកម្ម ជាអំណោយ ឬ ជាអច្ច័យទាន ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ត្រូវសន្មតជាទ្រព្យដោយឡែក។ ករណីដែលទ្រព្យដែលសហព័ទ្ធទាំងពីរ ឬ សហព័ទ្ធម្ខាងរកបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យរួម។ ក្រោយមកតុលាការត្រូវធ្វើការបែងចែកទ្រព្យនោះ។ ប៉ុន្តែករណីដែលសហព័ទ្ធណាម្ខាង ជាប្រពន្ធក្តី ជាប្តីក្តី ត្រូវបានតុលាការកំណត់ឱ្យមានអំណាចមេបាទៅលើកូន (បើសិនមាន) នោះទ្រព្យរួមខ្លះត្រូវកាត់ទៅអោយភាគីជាអ្នកមានអំណាចមេបា។ ក្នុងការបែងចែកទ្រព្យនៅពេលមានការលែងលះនោះតុលាការ លោកពិចារណាទៅលើភាពជាក់ស្តែងនៃទ្រព្យ និងភាពជិតស្និទ្ធរវាងភាគីជាម្ចាស់លើទ្រព្យនោះ។ ម្យ៉ាងទៀត ទ្រព្យខ្លះជា អចលនទ្រព្យ ឬទ្រព្យអវិភាគ ដែលមិនអាចបែងចែកជាចំណែកបាន ឬ មានការលំបាកក្នុងការបែងចែកដែលនាំឱ្យទ្រព្យនោះខូចតំលៃ ដូចនេះតុលាការអាចឱ្យភាគីដែលទទួលបានទ្រព្យនោះ កាត់សងជាប្រាក់ជំនួសទៅឱ្យភាគីម្ខាងទៀតទៅតាមតម្លៃទីផ្សាបាន។

### ខ. វិវាទអំពីទ្រព្យពេលបែងចែកមរតក

នៅពេលបែងចែកមតិក តុលាការយកកិច្ចសន្យាទ្រព្យសម្បត្តិ មកធ្វើជាមូលដ្ឋានក្នុងការបែងចែក ថាតើទ្រព្យណាខ្លះជាទ្រព្យដោយឡែករបស់មតកជនដែលត្រូវបញ្ចូលក្នុងមរតក។ បើគ្មានកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទេ ជាដំបូងគេត្រូវកំណត់ជាមុន ថាតើទ្រព្យណាខ្លះជាទ្រព្យដោយឡែករបស់មតកជនសិន ទើបអាចយកទ្រព្យដោយឡែកនោះមកធ្វើជាមូលដ្ឋានក្នុងការបែងចែកមរតក។

យើងឃើញថា ក្នុងក្រមរដ្ឋប្បវេណីយើងក៏បានចែង ពីគោលការណ៍ជ្រៀតជ្រែករបស់សហព័ទ្ធនៅរស់ក្នុងការចូលទៅចែកចំណែកមរតកដែរ ដោយសហព័ទ្ធនៅរស់នោះត្រូវជាសន្តតិជនជានិច្ច។ ក្នុងករណីដែលមានសន្តតិជនផ្សេងទៀត ក្រៅពីសហព័ទ្ធនៅរស់ដែលជាសន្តតិជនជានិច្ច នោះលំដាប់របស់សហព័ទ្ធនៅរស់គឺស្មើគ្នានឹង សន្តតិជនផ្សេងទៀត។[6]

### គ. វិវាទអំពីទ្រព្យក្នុងករណីទាមទារអោយអនុវត្តកាតព្វកិច្ច

នៅពេលមានបណ្តឹងទាមទារអោយអនុវត្តនូវកាតព្វកិច្ចច្រើនតែមានការលំបាកព្រោះប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាទ្រព្យ ដោយពេលខ្លះកម្មវត្ថុនោះអាចជាទ្រព្យរួមដែលមានចំណែកសហព័ទ្ធម្ខាងទៀត។ ដូច្នេះតុលាការត្រូវចំនាយពេលវេលាធ្វើការស៊ើបអង្កេតអង្គហេតុជាថ្មីទៅលើទ្រព្យនោះ។ ក្នុងករណីកម្មវត្ថុនៃការទាមទារជាប់ពាក់ព័ន្ធលើចំណែកទ្រព្យរួម ដែលសហព័ទ្ធ

[6] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា១១៦១។

ម្ខាងទៀតក៏ជាកម្មសិទ្ធិករ នោះតុលាការត្រូវធ្វើការបែងចែកចំណែកនៃទ្រព្យនោះត្រឹមទំហំពាក់កណ្តាល ឬ តាមកម្រិតដែលមានចែងក្នុងកិច្ចសន្យាដែលសហព័ទ្ធមានសិទ្ធិលើ។ ករណីខ្លះទ្រព្យនោះជាទ្រព្យអវិភាគដែលពិបាកក្នុងការបែងចែកចំណែក ដែលអាចធ្វើអោយវាខូចតម្លៃ នោះតុលាការអាចចេញសាលក្រមអនុវត្តលក់ទ្រព្យតាមតម្លៃទីផ្សារ ហើយសងទៅម្ចាស់បំណុលបាន។

### ១.១.២. នីតិវិធីនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

នីតិវិធីនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវគោរពតាមវិធានដែលមានចែងក្នុងប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ។ ប្រកាសនេះបានកំណត់នូវលក្ខខណ្ឌសំខាន់នានារួមមាន ទម្រង់របស់ពាក្យសុំចុះបញ្ជី ប្រភេទនៃពាក្យសុំចុះបញ្ជី អ្នកដាក់ពាក្យសុំចុះបញ្ជីរបៀបរបបនៃការស្នើសុំចុះបញ្ជីជាដើម។

#### ១.១.២.១. បទបញ្ញត្តិទូទៅនៃពាក្យសុំចុះបញ្ជី

ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវគោរពទៅតាមនីតិវិធីនានាដែលមានចែងក្នុងប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធទាំងលក្ខខណ្ឌគ្រឹះនិងលក្ខខណ្ឌទម្រង់។

- ***<u>លក្ខខណ្ឌគ្រឹះ</u> ៖***

ក្នុងការស្នើសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ត្រូវចាប់ផ្តើមពីការដាក់ពាក្យសុំជាមុន។ រាល់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះតម្រូវឲ្យធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ម៉្យាងវិញទៀត ពាក្យសុំច្បាប់ដើម ត្រូវមានហត្ថលេខា ឬ ស្នាមមេដៃរបស់អ្នកដាក់ពាក្យសុំដោយភ្ជាប់មកជាមួយនូវច្បាប់ថតចម្លងនៃច្បាប់ដើម។ ជាគោលការណ៍ ការសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវធ្វើឡើងរួមគ្នា លើកលែងតែក្នុងករណីមួយចំនួនដែលអាចដាក់ពាក្យសុំតែម្នាក់ឯងបាន ដូចជា ការផ្លាស់ប្តូរ ឬ ការកែតម្រូវឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និង ការចុះបញ្ជី ដោយផ្អែកលើសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចស្ថាពរ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដូចមានចែងនៅក្នុងមាត្រា ៣០ កថាខណ្ឌទី ៣ ចំណុច ខ, គ, ឃ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។ រាល់ពាក្យសុំចុះបញ្ជីខាងលើ អ្នកតំណាងក៏អាចកាន់យកមកដាក់នៅចំពោះមុខមន្ត្រីចុះបញ្ជី ជំនួសប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដែរ ដោយភ្ជាប់ជាមួយលិខិតបញ្ជាក់អំពីអ្នកតំណាង។ បុគ្គល ឬ អ្នកតំណាង ដែលដាក់ពាក្យសុំចុះបញ្ជី ត្រូវយកពាក្យសុំនោះ មកដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ដោយផ្ទាល់។[7]

- ***<u>លក្ខខណ្ឌទម្រង់</u> ៖***

ក្រោយពីបំពេញគ្រប់លក្ខខណ្ឌគ្រឹះរួចហើយ សហព័ទ្ធត្រូវបំពេញឱ្យគ្រប់នូវលក្ខខណ្ឌទម្រង់ផងដែរ។ ទម្រង់នៃពាក្យសុំចុះបញ្ជីត្រូវសរសេរ បារចនានៃព្រះរាជាណាចក្រកម្ពុជា ពាក្យសុំចុះ

[7] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, ប្រការ ១៥។

បញ្ជី ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើមាន) ហើយត្រូវគោរពចូលមករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងមានចុះកាលបរិច្ឆេទ និងហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ។ ក្រៅពីនេះ ត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាស។ លើសពីនេះទៀត ចំនុចសំខាន់ដែលត្រូវបំពេញនៅក្នុងពាក្យសុំគឺ អត្តសញ្ញាណរបស់សហព័ទ្ធ (ឈ្មោះ, ភេទ, ថ្ងៃ ខែ ឆ្នាំ កំណើត, ឋានៈ ជាប្តី ឬ ប្រពន្ធ, និង អាសយដ្ឋាន)។[8]

- ***ប្រភេទនៃពាក្យសុំចុះបញ្ជី ៖***

ប្រព័ន្ធចុះបញ្ជីទ្រព្យសម្បត្តិនេះ អនុញ្ញាតអោយសហព័ទ្ធទាំងសងខាង ចុះបញ្ជីនូវទ្រព្យសម្បត្តិនានារបស់ពួកគេដោយទាមទារអោយគោរពនូវ លក្ខខណ្ឌដែលរៀបរាប់ខាងលើ។ មិនតែប៉ុណ្ណោះ ប្រភេទនៃពាក្យសុំចុះបញ្ជីនេះ មានច្រើនប្រភេទដូចជា ពាក្យសុំចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំកែប្រែ ពាក្យសុំរំលាយនូវទំនាក់ទំនងសិទ្ធិ និង កាតព្វកិច្ចជាដើម។ ជាពិសេស ពួកគេក៏អាចធ្វើការលុបចោលកិច្ចសន្យាទ្រព្យសម្បត្តិបានដែរ តាមរយៈផ្លូវតុលាការ។ ការបង្កើត ការកែប្រែ និង ការលុបចោល នូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺត្រូវធ្វើតាមឆន្ទៈភាគីទាំងសងខាង។

- ***ឯកសារភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជី ៖***

នៅពេលដាក់ពាក្យសុំចុះបញ្ជី អ្នកដាក់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ(ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាអាទិ៍) ដូចមានចែងនៅក្នុងជំពូក ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសខាងលើ ត្រូវផ្តល់ឯកសារចាំបាច់មួយចំនួនទៅឱ្យនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនោះ។ ចំពោះពាក្យសុំចុះបញ្ជី ដែលអ្នកតំណាងយកមកដាក់ ដូចមានចែងក្នុងប្រការ ១៥ កថាខណ្ឌទី៣ ត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិតំណាងផងដែរ។

### ១.១.២.២. ការទទួល ការពិនិត្យ និងការកែតម្រូវពាក្យសុំចុះបញ្ជី

នៅពេលមន្ត្រីចុះបញ្ជីបានទទួលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចុះនិទ្ទេសនៅលើពាក្យសុំនោះនូវលេខរៀងទទួលពាក្យសុំ កាលបរិច្ឆេទ និងឈ្មោះនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីព្រមទាំងហត្ថលេខាបំព្រួញ និង ឈ្មោះមន្ត្រីចុះបញ្ជីនោះ។[9]

[8] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, ឧបសម្ព័ន្ធទី១ ដល់ ឧបសម្ព័ន្ធទី៧។

[9] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, ប្រការ ២៩។

មន្ត្រីចុះបញ្ជី ត្រូវពិនិត្យពាក្យសុំ និងឯកសារភ្ជាប់។ នៅពេលពិនិត្យពាក្យសុំ ដែលមានចែងនៅក្នុងកថាខណ្ឌទី១ ខាងលើនេះ បើមន្ត្រីចុះបញ្ជីមានវិមតិសង្ស័យនោះ មន្ត្រីចុះបញ្ជីអាចធ្វើការសាកសួរបន្ថែមទៅអ្នកដាក់ពាក្យសុំ ឬ អ្នកតំណាងនោះបាន។[10]

មន្ត្រីចុះបញ្ជី ត្រូវចេញលិខិតបង្គាប់ឱ្យកែតម្រូវ ដោយកំណត់អំឡុងពេលសមរម្យ និងជូនដំណឹង ទៅអ្នកដាក់ពាក្យសុំ ក្នុងករណីដែលមន្ត្រីចុះបញ្ជីពិនិត្យឃើញថា ពាក្យសុំចុះបញ្ជីធ្វើឡើងពុំត្រឹមត្រូវ ដោយមានមូលហេតុ ដូចខាងក្រោម ៖

-ព័ត៌មាន និងបែបបទក្នុងពាក្យសុំចុះបញ្ជីមិនស្របតាមប្រការដែលកំណត់

-ពុំបានផ្តល់ឯកសារដែលចាំបាច់

-ខ្លឹមសារនៅក្នុងពាក្យសុំ និងឯកសារភ្ជាប់មិនស្របគ្នា

-ពាក្យសុំចុះបញ្ជីនោះធ្លាប់បានដាក់ និងចុះបញ្ជីម្តងរួចមកហើយ

-ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំនៅក្នុងពាក្យសុំ មិនស្របគ្នាជាមួយនឹងការចុះបញ្ជី

-ពុំបានបង់សោហ៊ុយ ឬ

-ពាក្យសុំនោះ មិនអនុលោមទៅតាមលក្ខខណ្ឌនៃប្រកាសនេះ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តិផ្សេងទៀតដែលពាក់ព័ន្ធ។

នៅក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជី ពុំបានកែតម្រូវនៅក្នុងអំឡុងពេលសមរម្យនោះទេ មន្ត្រីចុះបញ្ជី ត្រូវចេញលិខិតលើកចោលពាក្យសុំចុះបញ្ជីនោះ ហើយផ្តល់ដំណឹងទៅអ្នកដាក់ពាក្យសុំ។[11]

### ១.១.២.៣. អានុភាពនៃការចុះបញ្ជី

ជាទូទៅ អានុភាពនៃការចុះបញ្ជីនេះ គឺការចុះបញ្ជីនៃកិច្ចសន្យាទ្រព្យសម្បត្តិដែល ត្រូវធ្វើតាមនីតិវិធីដែលមានចែងនៅក្នុងប្រកាសស្តីពីនីតិវិធីនៃការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ទៅតាមលក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់ដូចដែលរៀបរាប់ពីខាងលើ។ ម្យ៉ាងវិញទៀត ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អាច មានអានុភាពនៅពេលដែលមានការចុះហត្ថលេខា និងប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[12]

---

[10] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, ប្រការ ៣១។

[11] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, ប្រការ ៣២។

[12] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ, ប្រការ ៣៦។

### ១.១.៣. ប្រភេទនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

#### ១.១.៣.១. ការផ្លាស់ពីទ្រព្យដោយឡែកទៅជាទ្រព្យរួម

កិច្ចសន្យាប្រភេទនេះ គឺជាកិច្ចសន្យាមួយបែបដែលអនុញ្ញាតអោយភាគីជាប្តី ឬ ប្រពន្ធ អាចយកទ្រព្យដោយឡែករបស់ខ្លួនដែលមានមុន ឬ ក្រោយពេលរៀបអាពាហ៍ពិពាហ៍មិនថាជា ចលនវត្ថុ ឬ អចលនវត្ថុនោះទេ ដាក់ចូលជាទ្រព្យរួមវិញដែលភាគីម្ខាងទៀតមានសិទ្ធិលើទ្រព្យនោះពាក់កណ្តាល។ ការធ្វើដូចនេះ ត្រូវស្របតាមឆន្ទៈភាគីទាំងសងខាង ហើយមិនធ្វើឱ្យបាត់ប្រយោជន៍ភាគីណាមួយនោះទេ។ ការធ្វើដូចនេះ គឺដើម្បីបម្រើដល់ផលប្រយោជន៍រួម។

**<u>ឧទាហរណ៍៖</u>** លោក ក មានរថយន្តម៉ាក Highlanderមួយគ្រឿងតាំងពីមុនពេលរៀបអាពាហ៍ពិពាហ៍ជាមួយ លោកស្រី ខ មកម្ល៉េះ។ ក្រោយរៀបអាពាហ៍ពិពាហ៍ គាត់បានដាក់រថយន្តនោះជាទ្រព្យរួមដែលលោកស្រី ខ ក៏មានកម្មសិទ្ធិលើរថយន្តនោះដែរ។ លោកស្រី ខ មានសិទ្ធិប្រើប្រាស់ ចាត់ចែង និង អាស្រ័យផលលើរថយន្តនោះដូចជា លោក ក ដែលជាកម្មសិទ្ធិករដែរ។

#### ១.១.៣.២. ការផ្លាស់ពីទ្រព្យរួមឱ្យទៅជាទ្រព្យដោយឡែក

ប្រភេទកិច្ចសន្យារបៀបនេះ ជាកិច្ចសន្យាដែលមានក្រោយអាពាហ៍ពិពាហ៍ ដែលទ្រព្យជាកម្មវត្ថុនោះជាទ្រព្យរួមដែលកើតមានក្នុងអំឡុងពេលចំណងអាពាហ៍ពិពាហ៍ ហើយសហ-ព័ទ្ធព្រមព្រៀងគ្នាដាក់វាឱ្យទៅជាទ្រព្យដោយឡែករបស់ភាគីណាមួយវិញ ដោយការធ្វើជាអំណោយ ឬ អច្ច័យទាន។ ការផ្លាស់ប្តូរបៀបនេះត្រូវហាមឃាត់នៅក្នុងករណីទ្រព្យនោះជាកម្មវត្ថុនៃការរឹបអូសពីតុលាការ ឬ ជាកម្មវត្ថុនៃបំណុលជាមួយតតិយជន ឬ ជាកម្មវត្ថុនៃសន្តិកម្មជាដើម។ ការផ្លាស់ប្តូរនេះ ត្រូវតែស្របតាមឆន្ទៈភាគីទាំងសងខាងជានិច្ច។ ដោយឡែកសហព័ទ្ធម្ខាង អាចផ្លាស់ប្តូរបំណុលរួម ទៅជាបំណុលដោយឡែកបានដោយមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតដូចការផ្លាស់ប្តូរទ្រព្យដែរ។

**<u>ឧទាហរណ៍៖</u>** រថយន្តម៉ាក Highlander មួយគ្រឿងជាទ្រព្យរួមរបស់លោក ក និងលោកស្រី ខ។ ក្រោយមក លោក ក ចង់ដាក់រថយន្តនោះទៅជាទ្រព្យដោយឡែករបស់លោកស្រី ខ វិញដោយសារលោក ក ទិញរថយន្តថ្មីមួយគ្រឿងទៀត។ ក្រោយពីផ្លាស់ប្តូររថយន្តនោះទៅជាទ្រព្យដោយឡែករបស់លោកស្រី ខ ហើយនោះ លោកស្រី ខ ជាម្ចាស់កម្មសិទ្ធិករលើរថយន្តនោះតែម្នាក់គត់។

ក្នុងករណីដែលមានការបញ្ចូលគ្នានៃទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធណាម្ខាងដែលជាចលនវត្ថុ នឹងអចលនវត្ថុដែលជារបស់សហព័ទ្ធម្ខាងទៀត ហើយក្លាយជាផ្នែកមួយនៃអចលនវត្ថុនោះ កម្មសិទ្ធិនៅលើអចលនវត្ថុនឹងត្រូវមានអានុភាពទៅលើចលនវត្ថុនោះផងដែរ លើកលែងតែមានការព្រមព្រៀងពិសេស។ បើសិនសហព័ទ្ធដែលជាម្ចាស់នៃចលនវត្ថុ អាចទាមទារប្រាក់សំណង

បានតាមបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ តែមិនអាចទាមទារឱ្យធ្វើបដិទានបានឡើយ។[13] ឧទាហរណ៍៖ លោកស្រី សុខា បានរៀបការជាមួយ លោក សៅ។ មុនរៀបអាពាហ៍ពិពាហ៍ លោកស្រី សុខា មានដីមួយកន្លែង។ ក្រោយពីរៀបការបាន ពីរឆ្នាំ អ្នកទាំងពីរបានសន្សំប្រាក់បាន ៣០០០០ដុល្លារ រហូតព្រមព្រៀងគ្នា សាងសង់ផ្ទះមួយនៅលើដី ដែលជាទ្រព្យដោយឡែករបស់លោកស្រី សុខា។ តាមស្មារតីនៃមាត្រា ១៨៦ ផ្ទះដែលសាងសង់នៅលើដី ដែលជាទ្រព្យដោយឡែករបស់ លោកស្រី សុខា នឹងត្រូវក្លាយជាទ្រព្យដោយឡែករបស់ លោកស្រី សុខា។ ប៉ុន្តែ បើតាមបញ្ញត្តិនៃសេចក្តីចម្រើនឥតហេតុ លោក សៅ អាចទាមទារប្រាក់ចំនួន ១៥០០០ដុល្លារ ដែលជាតម្លៃចំណែកពាក់កណ្តាលនៃផ្ទះមកវិញ នៅពេលមានការលែងលះ។

### ១.១.៣.៣. ការកំណត់អំពីទំនាក់ទំនងកាតព្វកិច្ច និងសិទ្ធិលើបំណុល

កិច្ចសន្យាប្រភេទនេះ អនុញ្ញាតអោយប្តីប្រពន្ធចែងអំពីកាតព្វកិច្ច និងសិទ្ធិលើបំណុល ដែលមានមុន ឬ ក្រោយអាពាហ៍ពិពាហ៍ ក៏ដូចជាបែងចែកកាតព្វកិច្ចដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ ឬ បន្ទុកនៃកាតព្វកិច្ចជាក់លាក់ដែលអាចកើតឡើងក្រោយអាពាហ៍ពិពាហ៍។ កាតព្វកិច្ចទាំងអស់នោះមានដូចជា បំណុលដោយឡែករបស់សហព័ទ្ធណាម្នាក់ដែលមានមុនពេលអាពាហ៍ពិពាហ៍ជាដើម ហើយសហព័ទ្ធនោះត្រូវទទួលខុសត្រូវដោយខ្លួនឯងនូវបំណុលដែលកើតមានមុនពេលអាពាហ៍ពិពាហ៍។ ការកំណត់ពីទំនាក់ទំនងកាតព្វកិច្ច និង សិទ្ធិនេះគឺមិនត្រូវឱ្យប្រាសចាកពីច្បាប់ទេ ហើយមិនត្រូវកេងចំណេញលើភាគីជាសហព័ទ្ធណាម្ខាងឡើយ ក៏ដូចជាហាមឃាត់ ការកំណត់ណាមួយដែលប៉ះពាល់លើតតិយជនដែលជាម្ចាស់បំណុល។ ករណីមានការបំពានណាមួយ ភាគីរងគ្រោះអាចដាក់ពាក្យបណ្តឹងទៅតុលាការឱ្យធ្វើការរំលាយកិច្ចសន្យានេះបាន ។

**<u>ឧទាហរណ៍៖</u>** លោក ក និង អ្នកនាង ខ ជាប្តីប្រពន្ធនឹងគ្នា។ ក្រោយមកពួកគេបានព្រមព្រៀងគ្នាធ្វើការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយកំណត់អំពីបំណុលដែលមាន នៅមុនពេលអាពាហ៍ពិពាហ៍ត្រូវធ្វើការសងដោយខ្លួនឯង ឬ ប្តីជាអ្នកសងជំនួសប្រពន្ធ ឬ ប្រពន្ធជាអ្នកសងជំនួសប្តី។

### ១.១.៣.៤. កំណត់អំពីសិទ្ធិគ្រប់គ្រង និងចាត់ចែងទ្រព្យជាអាទិ៍

ប្រភេទនៃកិច្ចសន្យានេះ ប្តីប្រពន្ធអាចកំណត់អំពីសិទ្ធិគ្រប់គ្រង និង ចាត់ចែងទៅលើទ្រព្យរួមមិនថាជាចលនទ្រព្យ ឬ អចលនទ្រព្យនោះទេ ដែលពួកគេអាចកំណត់ថាតើបុគ្គល ប្តី ឬ ប្រពន្ធមានសិទ្ធិគ្រប់គ្រងលើទ្រព្យណាមួយនោះ។ តាមទិដ្ឋភាពជាក់ស្តែងនៅក្នុងសង្គម បុគ្គលជាប្តី ឬ ប្រពន្ធបានបង្កើតមុខរបររួមគ្នា ដែលយកទ្រព្យរួម ឬ ដោយឡែករបស់ពួកគាត់ក្នុងការបើកមុខរបរនោះ។ ក្នុងកិច្ចសន្យានេះពួកគាត់អាចកំណត់នូវសិទ្ធិដល់សហព័ទ្ធណាមួយក្នុងការគ្រប់គ្រង

[13] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា១៨៦។

បានដោយសារ សហព័ទ្ធមានភាពស្និទ្ធស្នាល ឬ ច្បាស់លាស់លើមុខរបរនោះ។ ប្រាក់ចំណូលដែលបានមកពីមុខរបរនោះ ពួកគាត់អាចធ្វើការចាត់ចែងដោយចែកជាចំណែកសមស្រមតាមឆន្ទៈរបស់ពួកគាត់។ប៉ុន្តែមិនអាចមានភាគីណាមួយកេងប្រវ័ញ្ច លើបុគ្គលម្ខាងទៀតទេ។

**<u>ឧទាហរណ៍៖</u>** លោក ក និង អ្នកនាង ខ ជាប្តីប្រពន្ធនឹងគ្នា។ ពួកគាត់បានបើកហាងចំនួន២សាខា។ គាត់បានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយកំណត់ពីសិទ្ធិគ្រប់គ្រង និង ចាត់ចែងដោយលោក ក គ្រប់គ្រងសាខា ទី១ និង អ្នកនាង ខ គ្រប់គ្រងសាខា ទី២។

### ១.១.៤. លក្ខខណ្ឌលាយលក្ខណ៍អក្សរ និងលក្ខខណ្ឌតតាំង

នៅក្នុងកិច្ចសន្យា ទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយធ្វើការចុះបញ្ជីទើបអាចតតាំងជាមួយតតិយជនបាន។ ក្នុងករណីសហព័ទ្ធធ្វើកិច្ចសន្យាផ្សេងពីកិច្ចសន្យាប្តីប្រពន្ធនេះបើមិនបានចុះបញ្ជីទេ មិនអាចយកទៅតតាំងនឹងតតិយជនបានទេ។[14] ក្នុងករណីដែលប្តីប្រពន្ធបានធ្វើកិច្ចសន្យាអំពីទ្រព្យសម្បត្តិរួម ផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ដើម្បីកុំឱ្យខូចប្រយោជន៍ដល់តតិយជន ចាំបាច់ទាមទារឱ្យមានការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។[15] គេបានហាមឃាត់ក្នុងការកែប្រែកិច្ចសន្យាប្តីប្រពន្ធដែលពាក់ព័ន្ធនឹងតតិយជននេះដើម្បីធានា និង ការពារដល់ប្រយោជន៍តតិយជនសុចរឹត។

### ១.១.៥. អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាកិច្ចសន្យាមួយប្រភេទដែលមានភាពងាយស្រួល និង ច្បាស់លាស់ ក្នុងការកំណត់លើបញ្ហាសំខាន់ៗនៃទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលមានដូចជាសិទ្ធិ កាតព្វកិច្ច ការគ្រប់គ្រង ការចាត់ចែង និងករណីយកិច្ចនានាផ្សេងៗដែលទាមទារឱ្យប្តីប្រពន្ធត្រូវគោរព និងអនុវត្តតាម។ ដើម្បីអោយកិច្ចសន្យាមួយនេះមានអានុភាពគតិយុត្តិ ភាគីជាប្តីប្រពន្ធត្រូវគោរពតាមការកំណត់នៃច្បាប់ដើម្បីជៀសវាងបញ្ហានៅថ្ងៃមុខ។

#### ១.១.៥.១. អានុភាពចំពោះភាគី

នៅពេលប្តីប្រពន្ធបានសម្រេចចិត្តចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ទៅតាមគោលការណ៍ច្បាប់ដែលបានកំណត់ដោយគោរពនូវឆន្ទៈរបស់ភាគីទាំងសងខាង នោះអានុភាពត្រូវមានចំពោះទ្រព្យសម្បត្តិភាគីទាំងពីរ។ ករណីនេះ អានុភាពនៃកិច្ចសន្យាមានទៅលើទំហំទ្រព្យសម្បត្តិដែលសហព័ទ្ធបានចុះបញ្ជីនៅក្នុងកិច្ចសន្យទ្រព្យសម្បត្តិ។ ទ្រព្យសម្បត្តិទាំងរួម និង ដោយឡែករបស់សហព័ទ្ធដែលបានកំណត់ក្នុងកិច្ចសន្យានេះបានកំណត់ពីសិទ្ធិ និង កាតព្វកិច្ចរួចហើយ។

[14] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៧០។

[15] មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិកម្ពុជា-ជប៉ុន, ច្បាប់ស្តីការអនុវត្តក្រមរដ្ឋប្បវេណី, កំណត់ហេតុសិក្ខាសិលា ២០១១, ៨។

ដូចនេះហើយ អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិចំពោះភាគីនេះ ចង់សំដៅទៅលើទំហំនៃសិទ្ធិទាក់ទងនឹងការលក់ ឬ ចាត់ចែងអ្វីមួយត្រូវគោរពលើឆន្ទៈភាគីដែលជាម្ចាស់កម្មសិទ្ធិ។ ប៉ុន្តែករណីខ្លះ ដោយសារតែមានភាគីម្ខាងជំពាក់បំណុលគេ ហើយគ្មានលទ្ធភាពសង នោះម្ចាស់បំណុលអាចរឹបអូសត្រឹមទ្រព្យសម្បត្តិដែលកូនបំណុលមានតែមិនអាចរឹបអូសនូវទ្រព្យរួមទេ ពោលគឺអាចរឹបអូសត្រឹមតែចំណែកទ្រព្យដោយឡែករបស់ភាគីប្ដី ឬ ប្រពន្ធជាកូនបំណុល។

#### ១.១.៥.២. អានុភាពចំពោះតតិយជន

ក្រៅពីមានអានុភាពចំពោះភាគី កិច្ចសន្យានេះក៏មានអានុភាពចំពោះតតិយជនផងដែរ។ អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិចំពោះតតិយជន គឺចង់សំដៅទៅលើតតិយជនមិនថាជារូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានប្រយោជន៍នៅក្នុងរង្វង់ទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធនោះ។ ក្នុងករណីតតិយជនដែលមានប្រយោជន៍ ក្នុងរង្វង់ទ្រព្យសម្បត្តិនៃប្ដីប្រពន្ធណាមួយ ឬ ចង់ដឹងពីការកំណត់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ក្នុងគោលដៅរកភាពច្បាស់លាស់មុនសម្រេចចិត្តរកស៊ី ឬធ្វើទំនាក់ទំនងកិច្ចសន្យាផ្សេងៗ តតិយជននោះអាចស្នើសុំឱ្យចេញលិខិតបញ្ជាក់នៃកិច្ចសន្យាទ្រព្យនេះបាន។

## ផ្នែកទី២៖ ទ្រព្យសម្បត្តិសហព័ទ្ធដែលកើតមានតាមច្បាប់កំណត់

"ដោយសារតែភាគីមិនបានគ្រប់គ្រងទ្រព្យសម្បត្តិតាមកិច្ចសន្យា គឺទ្រព្យសម្បត្តិត្រូវបានគ្រប់គ្រងតាមប្រព័ន្ធច្បាប់ មានន័យថានៅពេលដែលមានវិវាទ គឺលើកច្បាប់មកពិចារណា" (អ៊ាន សំអាត, បទសម្ភាស)។ នៅក្នុងច្បាប់រដ្ឋប្បវេណីកម្ពុជា វាបានកំណត់ពីនិយមន័យនៃប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធនេះផងដែរដោយរួមមានទ្រព្យដោយឡែក គឺជាទ្រព្យដែលមិនពាក់ព័ន្ធនឹងទំនាក់ទំនងអាពាហ៍ពិពាហ៍ទេ រីឯទ្រព្យរួមជាទ្រព្យដែលមានទំនាក់ទំនងជាមួយសហព័ទ្ធក្រោយអាពាហ៍-ពិពាហ៍។

### ២.១. ទ្រព្យសម្បត្តិសកម្មរបស់សហព័ទ្ធ

#### ២.១.១. ទ្រព្យសម្បត្តិដោយឡែក

យោងតាមមាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណី វាបានបញ្ញត្តិអំពីទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ដែលជាទ្រព្យដោយឡែកមានដូចជា៖

- ទ្រព្យដោយឡែកជាទ្រព្យដែលសហព័ទ្ធមានមុនពេលរៀបអាពាហ៍ពិពាហ៍ មានន័យថាមុនពេលពួកគាត់រៀបអាពាហ៍ពិពាហ៍ ទោះជាគាត់មានទ្រព្យប្រភេទណាក្តី ក្រោយពេលរៀបការទ្រព្យនោះនៅតែជារបស់គាត់ ហើយគាត់ជាកម្មសិទ្ធិករដដែល ដោយមិនរាប់បញ្ចូលទ្រព្យនោះទៅជាទ្រព្យរួមនោះទេ។

**<u>ឧទាហរណ៍៖</u>** លោក សៅ មានផ្ទះមួយខ្នងនៅខេត្តកំពង់ចាម ដែលបានទិញកាលពីឆ្នាំ២០០៩។ លុះដល់ឆ្នាំ ២០១៥ គាត់បានរៀបការជាមួយអ្នកស្រី ធីតា ។ ដូចនេះ ផ្ទះមួយខ្នងនោះ គឺជាទ្រព្យសម្បត្តិដោយឡែករបស់លោក សៅ ដដែល។

ចំពោះទ្រព្យសម្បត្តិដែលមានលក្ខណៈពិសេស ដូចជាមូលនិធិពាណិជ្ជកម្ម ដូចជា ការបើកអាជីវកម្មក្រុមហ៊ុន ពោលគឺត្រូវមើលកាលបរិច្ឆេទនៃការបង្កើតមូលនិធិពាណិជ្ជកម្មនោះដោយគិតចាប់ពីកាលបរិច្ឆេទនៃការបើកទទួលអតិថិជន។[16] ឧទាហរណ៍៖ នៅខែកក្កដា ឆ្នាំ ២០១៧ លោក ក បានបើកអាជីវកម្មហាងកាហ្វេមួយកន្លែង ដោយជួលបុគ្គលិក និងតុបតែងហាងបានយ៉ាងល្អ។ មួយខែក្រោយ គាត់ក៏បានដាក់សម្ពោធហាងនោះ។ នៅដើមឆ្នាំ ២០១៨ គាត់បានរៀបការជាមួយ អ្នកនាង ខ។ យើងឃើញថា ហាងកាហ្វេ នោះជាទ្រព្យដោយឡែករបស់លោក ក ដដែល ដោយសារហាងនោះបង្កើតឡើងនៅមុនពេលលោក ក និង អ្នកនាង ខ រៀបអាពាហ៍ពិពាហ៍ ពោលគឺថ្ងៃចាប់ផ្តើមទទួលអតិថិជន នៅមុនពេលលោក ក រៀបការនឹង អ្នកនាង ខ។ ប៉ុន្តែ ចំពោះផលចំណេញពីហាងកាហ្វេដែលរកបានបន្ទាប់ពីរៀបការ គឺជាទ្រព្យសម្បត្តិរួម។

- ដោយឡែក ទោះជាទ្រព្យនោះរូបគាត់ទទួលបាននៅក្នុងអំឡុងពេលនៃចំណងអាពាហ៍ពិពាហ៍ក្តីដូចជាកេរមរតកពីមតកជន ជាអំណោយផ្សេងៗ (ប្រទានកម្ម ឬ អច្ច័យទាន) ក៏នៅតែជាទ្រព្យដោយឡែករបស់គាត់ដែរ។
    - ករណីសន្តតិកម្ម៖ សន្តតិកម្ម គឺជាការផ្ទេរមតិកតាមការកំណត់របស់ច្បាប់ ពីមតកជន មក សន្តតិជន។

**<u>ឧទាហរណ៍៖</u>** លោក សុខ បានរៀបការជាមួយលោកស្រី បុផ្ផា។ មួយខែក្រោយមកឪពុករបស់លោក សុខ បានទទួលមរណភាព។ ឧបមាថាលោក សុខដែលជាសន្តតិជនត្រូវទទួលបានផ្ទះមួយខ្នង និង ប្រាក់ ២០០០០ដុល្លារ ក្នុងករណីនេះ សន្តតិជនដែលមានសិទ្ធិទទួលបានមតិក គឺមានតែលោក សុខ ប៉ុណ្ណោះ ចំណែក លោកស្រី បុផ្ផា មិនមានសិទ្ធិទទួលបានសន្តតិកម្មនេះទេ។ មរតកដែលមានផ្ទះមួយខ្នង និង ប្រាក់ ២០០០០ដុល្លារនោះត្រូវក្លាយជាទ្រព្យដោយឡែករបស់លោក ក មិនមែនជាទ្រព្យរួមទេ ទោះជាមរតកនោះទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ។

- ករណីប្រទានកម្ម៖ ប្រទានកម្ម គឺជាការប្រគល់នូវទ្រព្យសម្បត្តិណាមួយតាមឆន្ទៈពីសំណាក់ភាគីម្ខាង(ទាយក) ទៅអោយភាគីម្ខាងទៀត (បដិគ្គាហក) ដោយការយល់ព្រម និង មិនយកថ្លៃ។[17] ជាក់ស្តែងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដែលយើងឃើញថា នៅពេលដែលកូនៗរៀបការឪពុកម្តាយតែងតែចងដៃកូនជាគ្រឿងអលង្ការ ជាប្រាក់ ជាផ្ទះ ទោះជាចលនវត្ថុ ឬ អចលនវត្ថុបើសិនឪពុកម្តាយ ដែលជាម្ចាស់អំណោយឱ្យទៅអ្នកណា អ្នកនោះជាម្ចាស់ទ្រព្យ តែបើបញ្ជាក់ថាឱ្យទៅទាំង

[16] នុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, *នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ* (២០១៧), ៣៥៣។
[17] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៥៦៨។

ពីរប្ដីប្រពន្ធនោះវាជាទ្រព្យរួមវិញ។ ម៉្យាងទៀត ករណីដែលទ្រព្យ ដែលជាកេរ៍មត៌ករបស់មតកជនខាងប្ដីឱ្យប្ដី ត្រូវជាទ្រព្យដោយឡែករបស់ប្ដី រីឯខាងប្រពន្ធក៏ដូចគ្នាដែរ។

**ឧទាហរណ៍៖** លោក បុត្រ បានរៀបការជាមួយលោកស្រី ចាន់ណា។ មួយខែក្រោយលោក បុត្រទទួលបានផ្ទះមួយល្វែង ពីឪពុកមា។ ករណីនេះទោះជាប្រទានកម្ម កើតឡើងក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក្ដីក៏ទ្រព្យដែលទទួលបាននេះនៅតែចាត់ទុកជាទ្រព្យដោយឡែកដែរ។

- ករណីអច្ច័យទាន៖ អច្ច័យទាន គឺជាប្រទានកម្មដែលម្ចាស់បណ្ដាំធ្វើទៅឲ្យមនុស្សម្នាក់ ឬ ច្រើននាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់ទៅតាមភាគនោះ (អច្ច័យទានសកល) ឬជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ទៅមនុស្សម្នាក់ ឬ ច្រើននាក់ (អច្ច័យទានមានកំណត់)។[18] **ឧទាហរណ៍៖** ក្រោយពីឪពុករបស់លោក សុខ បានស្លាប់ គាត់បានបន្សល់ទុកនូវបណ្ដាំមួយច្បាប់ ដែលខ្លឹមសារគឺប្រគល់ដីមួយកន្លែងទៅអោយ លោក សុខ។ ករណីនេះ ជាអច្ច័យទានមានកំណត់ ដែលកម្មវត្ថុជាដីមួយកន្លែង ហើយប្រគល់អោយតែ លោក សុខ ម្នាក់គត់។

- បន្ថែមពីនេះ ទ្រព្យសម្បត្តិដែលទទួលបានពីតម្លៃតបពីទ្រព្យខាងលើក៏ជាទ្រព្យដោយឡែកដែរ មានន័យថាទ្រព្យដែលជាផលបានពីការចាត់ចែងទ្រព្យដោយឡែកហើយម្ចាស់ទ្រព្យយកផលនោះទៅចាត់ចែងផ្សេងទៀត។ **ឧទាហរណ៍៖** មុនរៀបការ លោក ផល មានដីមួយកន្លែង។ ក្រោយមកពេលដែលក្រោយរៀបការគាត់លក់ដីនោះបាន ១០០០០ដុល្លារ។ យើងឃើញថា ប្រាក់១០០០០ដុល្លារជាតម្លៃតបនៃទ្រព្យដោយឡែកដែលជាដីមួយកន្លែងនោះ ដូចនេះ ប្រាក់១០០០០ដុល្លារនៅតែជាទ្រព្យដោយឡែករបស់លោក ផល។

### ២.១.២. ទ្រព្យសម្បត្តិរួម

ក្រមរដ្ឋប្បវេណីក៏បានបញ្ញត្តិពីចំណាត់ថ្នាក់នៃទ្រព្យរួម ក៏ដូចជានិយមន័យ ករណីលើកលែងផងដែរ។ ប្រព័ន្ធទ្រព្យសម្បត្តិរួម ជាទំនាក់ទំនងទ្រព្យសម្បត្តិ ដែលសហព័ទ្ធទាំងសងខាង ឬតែម្ខាងទទួលបាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ តែលើកលែង ចំណុចដែលមានចែងក្នុងមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក)។[19] និយាយជារួម មានន័យថាទ្រព្យសម្បត្តិដែលក្រៅពីទ្រព្យដែលសហព័ទ្ធម្ខាងមានមុនពេលអាពាហ៍ពិពាហ៍ ទ្រព្យដែលបានពីសន្តតិកម្ម ឬ អំណោយ (ប្រទានកម្ម ឬ អច្ច័យទាន) និង ទ្រព្យជាតម្លៃតបនៃទ្រព្យដោយឡែក គឺសុទ្ធតែជាទ្រព្យរួម។ ជាក់

[18] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា១១៩៩។

[19] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៧៣។

ស្តែង ដូចជាទ្រព្យដែលទទួលបានដូចជា ប្រាក់ខែ ប្រាក់ចំណូលបានពីអាជីវកម្មជាដើមទោះជាសហ-ព័ទ្ធណារកបានក៏ដោយ។

**<u>ឧទាហរណ៍៖</u>** ភាគីប្តី មានផ្ទះមួយខ្នងនៅខេត្តកំពង់ចាម ដែលមានតម្លៃ ៣០០០០ដុល្លារ។ ក្រោយរៀបអាពាហ៍ពិពាហ៍ គាត់លក់ផ្ទះនោះបានក្នុងតម្លៃ៤០០០០ដុល្លារ ដោយចំណេញពីតម្លៃដើម ១០០០០ដុល្លារ។ ប្រាក់ ៣០០០០ដុល្លារ នៅតែជាទ្រព្យដោយឡែករបស់គាត់ចំណែកប្រាក់ ១០០០០ដុល្លារ ដែលជាប្រាក់ចំណេញ ត្រូវចាត់ទុកជាទ្រព្យរួម។ ក្នុងករណីនេះ ទោះជាទ្រព្យរបស់ភាគីប្តី ដែលជាផ្ទះមួយខ្នងនេះ ជាទ្រព្យដោយឡែកក្តី ប៉ុន្តែ ក្រោយមានចំណងអាពាហ៍ពិពាហ៍ ប្រាក់ដែលជាផលដែលកើតចេញពីទ្រព្យដោយឡែកនោះ នឹងត្រូវចាត់ចូលជាទ្រព្យរួមវិញ។

- យើញឃើញថា ករណីការទិញជាគ្រឿងអលង្ការ សម្លៀកបំពាក់ ឬ របស់របរប្រើប្រាស់ដែលប្តីប្រពន្ធ ភាគច្រើនបានទិញដោយប្រើប្រាស់ទ្រព្យរួម ថាតើត្រូវចាត់ទុកជាទ្រព្យរួម ឬ ទ្រព្យដោយឡែក បើសិនទ្រព្យនោះ វាបម្រើដល់ផលប្រយោជន៍នៃបុគ្គលភាគីសហព័ទ្ធតែម្ខាង។ ករណីនេះ គួរតែចាត់ទុកជាទ្រព្យរួម ដោយសារតែគ្មានបញ្ញត្តិនៃមាត្រាណាមួយ បញ្ញត្តិពីករណីលើកលែងទេ។ នៅពេលលែងលះថៅក្រម អាចកាត់សេចក្តីតាមឆន្ទានុសិទ្ធិដោយយោងតាមទិដ្ឋភាពជាក់ស្តែង ឬ លក្ខណៈ នៃទ្រព្យនោះ។

- ចំពោះករណីកម្មសិទ្ធិបញ្ញា ដូចជាសិទ្ធិអ្នកនិពន្ធជាដើម គឺគេត្រូវធ្វើការបែងចែក សិទ្ធិសីលធម៌(សិទ្ធិផ្តាច់មុខ) និង សិទ្ធិបេតិកភណ្ឌ (សិទ្ធិទទួលបានកម្រៃពីការធ្វើអាជីវកម្មលើស្នាដៃ)។ ដូចនេះ ប្រាក់ដែលទទួលបានពីសិទ្ធិបេតិកភណ្ឌ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺចាត់ទុកជាទ្រព្យសម្បត្តិរួមនៃសហព័ទ្ធ។[20] ឧទាហរណ៍៖ លោក សុភ័ក្រ ជាអ្នកនិពន្ធសៀវភៅមួយក្បាល កាលពីឆ្នាំ ២០១៥។ គាត់បានលក់ស្នាដៃសៀវភៅដែលជាការនិពន្ធរបស់គាត់បាន ៥០០០ដុល្លារនៅពេលនោះ។ នៅដើមឆ្នាំ ២០១៦ គាត់បានបានរៀបការនឹង លោកស្រី ជាតា ហើយនិពន្ធស្នាដៃសៀវភៅមួយទៀត ដែលលក់បាន ៤០០០ដុល្លារ។ ករណីនេះ ប្រាក់៥០០០ដុល្លារ ដែលគាត់លក់សៀវភៅបាននៅមុនពេលគាត់រៀបអាពាហ៍ពិពាហ៍ ជាទ្រព្យដោយឡែក ដែលកើតពីស្នាដៃរបស់គាត់ ប៉ុន្តែប្រាក់៤០០០ដុល្លារ ដែលលក់សៀវភៅក្រោយនោះ ត្រូវក្លាយជាទ្រព្យរួម។ គួរបញ្ជាក់ថា ប្រាក់ដែលរកបានពីស្នាដៃនេះនៅអំឡុងពេលអាពាហ៍ពិពាហ៍ជាទ្រព្យរួម ប៉ុន្តែស្នាដៃដែលជាសិទ្ធិអ្នកនិពន្ធនៅតែជាទ្រព្យដោយឡែក។

នៅក្នុងករណីមានការបង្កើតគណនីធនាគារសន្សំប្រាក់របស់សហព័ទ្ធ ដែលជាគណនីរួម ឬជាគណនីដោយឡែក តែងមានបញ្ហាជម្លោះនៅពេលមានការលែងលះ។ ករណីដែលមានការលែងលះ ហើយត្រូវធ្វើការបែងចែកទ្រព្យ តុលាការ មិនពិចារណាទៅលើ ឈ្មោះដែលជាម្ចាស់កម្មសិទ្ធិករនៃគណនីនោះក្នុងការកំណត់ថាតើនរណាមានសិទ្ធិ លើប្រាក់ដែលនៅក្នុងគណនីនោះទេ តែ

[20] រុន ពណ្ណារិទ្ធិ និង ចាន់ ស៊ីណាត, *នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ*, (២០១៧), ៣៥៩-៣៦០។

តុលាការពិចារណាទៅលើប្រភពនៃប្រាក់ដែលដាក់នៅក្នុងគណនីនោះវិញ។ យើងឃើញថា គណនីសន្សំប្រាក់ដែលសហព័ទ្ធបើកមុនពេលរៀបអាពាហ៍ពិពាហ៍ មិនមែនសុទ្ធតែកំណត់ជាទ្រព្យដោយឡែកនោះទេ។ ជាក់ស្តែង ប្រាក់ដែលដាក់សន្សំក្នុងគណនីធនាគារ នៅមុនពេលបុគ្គលម្នាក់រៀបអាពាហ៍ពិពាហ៍គឺជាទ្រព្យដោយឡែក ប៉ុន្តែ ករណីដែលក្រោយពេលគាត់បានរៀបការ ប្រាក់ដែលរកបានហើយដាក់បញ្ចូលក្នុងគណនីសន្សំនោះ មិនមានភាពច្បាស់លាស់ថាជាទ្រព្យដោយឡែកទេ វាអាចជាចំណូលនៃសហព័ទ្ធនោះ ដែលធ្លាក់ចូលជាទ្រព្យរួមវិញ។ តាមស្មារតីច្បាប់ គណនីធនាគារដែលសន្មតថាជា ទ្រព្យដោយឡែកគឺជាគណនីដាក់ប្រាក់ ដែលម្ចាស់គណនីនោះបង្កើតនៅមុនពេលរៀបអាពាហ៍ពិពាហ៍ ឬ ប្រភពនៃប្រាក់នៅក្នុងគណនីនោះ ម្ចាស់គណនីជាអ្នករកបានពីអំណោយ ឬ សន្តតិកម្ម ឬ ជាតម្លៃតបនៃទ្រព្យដោយឡែកនោះ។ ចំណែកឯ គណនីដែលសន្មតជាទ្រព្យរួម គឺគណនីដែលបង្កើតនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ហើយប្រភពប្រាក់ដែលដាក់ក្នុងគណនីនោះអាចសន្មតជាទ្រព្យរួមបាន ទោះជាឈ្មោះម្ចាស់គណនីនោះមានឈ្មោះរបស់សហព័ទ្ធតែម្នាក់ក្តី។ ជាទូទៅ នៅពេលលែងលះ ហើយធ្វើការបែងចែកទ្រព្យ នោះសហព័ទ្ធត្រូវទទួលបន្ទុកក្នុងការបង្ហាញភស្តុតាងទៅកាន់តុលាការ ថាតើសមតុល្យសាច់ប្រាក់នៅក្នុងគណនីនោះជាទ្រព្យរួម ឬ ទ្រព្យដោយឡែក។

### ២.២. ទ្រព្យអកម្ម ឬ កាតព្វកិច្ច

ជាទូទៅ ប្តីប្រពន្ធដែលរៀបការជាមួយគ្នាតែងតែមានទំនាក់ទំនងនៃទ្រព្យអកម្មដែលមានដូចជា បំណុល និង កាតព្វកិច្ចជាដើម។ បំណុល និង កាតព្វកិច្ចខ្លះកើតមានឡើងនៅមុនពេលដែលសហព័ទ្ធរៀបការជាមួយគ្នា ហើយ បំណុល និង កាតព្វកិច្ចខ្លះកើតមានក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍។

#### ២.២.១. កាតព្វកិច្ចដែលកើតមុនអាពាហ៍ពិពាហ៍

នៅក្នុងសង្គមខ្មែរ យើងឃើញថាមានប្តីប្រពន្ធភាគច្រើនខ្លះ មុនពេលរៀបការក៏មានជាប់នូវកាតព្វកិច្ចបំណុលរួចស្រេចទៅហើយ។ ឧទាហរណ៍៖ លោក ក ជំពាក់បំណុល លោក គ ចំនួន ១០០០០ដុល្លារ នៅឆ្នាំ ២០១៤ ដែលត្រូវសងនៅឆ្នាំ ២០១៦។ នៅឆ្នាំ ២០១៥ លោក ក និង លោកស្រី ខ បានរៀបការជាមួយគ្នា។ ក្នុងន័យនេះ យើងឃើញថា កាតព្វកិច្ចសងបំណុលរបស់លោក ក ជាកាតព្វកិច្ចនៃបំណុលដោយឡែកដែលលោក ក តែម្នាក់ជាអ្នកត្រូវសង ទោះជាអំឡុងពេលត្រូវសងនៅក្នុងអំឡុងពេលនៅចំណងអាពាហ៍ពិពាហ៍ក៏ដោយ។ មានការលើកឡើងថា តើនៅពេលដល់កំណត់សង តើទ្រព្យរួមអាចជាកម្មវត្ថុនៃកាតព្វកិច្ចសងបំណុលរបស់លោក ក ឬទេ? តាមការបកស្រាយ ទ្រព្យរួមក៏គួរតែអាចជាកម្មវត្ថុនៃការអនុវត្តសងដែរ ដោយសារ អំឡុងពេលនៃចំណងអាពាហ៍ពិពាហ៍ លោក ក ក៏មានចំណែកពាក់កណ្តាលនៃទ្រព្យរួមដែរ។ ទោះជាក្រុម

រដ្ឋប្បវេណីមិនបានកំណត់ច្បាស់លាស់លើចំណុចនេះក្តី ការសងបំណុលដោយឡែក ដោយយកទ្រព្យរួមមកជាកម្មវត្ថុក្នុងការសង ក៏សមហេតុផលក្នុងការការពារប្រយោជន៍របស់ម្ចាស់បំណុលដែរ។ ម្ចាស់បំណុលអាចស្នើសុំឱ្យតុលាការ ធ្វើការរឹបអូសទ្រព្យរួម និង ទ្រព្យដោយឡែករបស់កូនបំណុលដើម្បីសងបាន។ **ឧទាហរណ៍៖** លោក ក និង លោកស្រី ខ មានទ្រព្យរួមជាដីមួយកន្លែងទ្រព្យដោយឡែករបស់ លោកស្រី ខ មានប្រាក់ ៥០០០ដុល្លារ។ លោកស្រី ខ ជំពាក់បំណុលដែលជាបំណុលដោយឡែក ចំនួន១០០០០ដុល្លារ ដែលដល់កំណត់សង។ ម្ចាស់បំណុលអាចស្នើសុំទៅតុលាការដើម្បីទាមទារឱ្យអនុវត្តន៍រឹបអូសទ្រព្យរួម ព្រមទាំងទ្រព្យដោយឡែកខាងលើ ដើម្បីសងបំណុលបាន។

### ២.២.២. កាតព្វកិច្ចដែលកើតក្នុងអំឡុងពេលអាពាហ៍ពិពាហ៍

កាតព្វកិច្ចដែលកើតឡើងក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ជាកាតព្វកិច្ចដែលទាមទារអោយសហព័ទ្ធធ្វើការសហការគ្នាសង។

- កាតព្វកិច្ចដោយសាមគ្គី៖ កាតព្វកិច្ចដោយសាមគ្គីជាកាតព្វកិច្ចដែលម្ចាស់បំណុលអាចទាមទារឲ្យកូនបំណុលណាម្នាក់អនុវត្តកាតព្វកិច្ចទាំងអស់ ឬមួយភាគ ឬឲ្យកូនបំណុលទាំងអស់អនុវត្តទាំងអស់ ឬ មួយភាគ ដោយព្រមគ្នា ឬ ដោយបន្តបន្ទាប់។[21] កាតព្វកិច្ចដែលសហព័ទ្ធត្រូវទទួលខុសត្រូវដោយសាមគ្គីមានដូចជា៖
    - សោហ៊ុយក្នុងការថែរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និង សោហ៊ុយដើម្បីធ្វើការអប់រំ ឬ ការព្យាបាល ថែទាំកូន។ ឧទាហរណ៍៖ ប្រាក់ជំពាក់ពីការទិញទឹកដោះគោកូន។
    - កាតព្វកិច្ច ដែលសហព័ទ្ធបានព្រមព្រៀងគ្នាក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលជាកាតព្វកិច្ចដោយឡែក ឬ ជាកាតព្វកិច្ចរួមដែលត្រូវធ្វើការសាមគ្គីគ្នាសងទៅកាន់ម្ចាស់បំណុល។ **ឧទាហរណ៍៖** ប្តី បានព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យាប្តីប្រពន្ធ ថាសងបំណុលដោយឡែកទាំងអស់ ឬ មួយចំនួន របស់ប្រពន្ធគាត់។
    - កាតព្វកិច្ចដែលប្តីប្រពន្ធព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុល ឬ កាតព្វកិច្ចដែលសហព័ទ្ធម្ខាងទទួលបន្ទុក ដែលមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត។ **ឧទាហរណ៍៖** ប្តី ខ្ចីប្រាក់ ៥០០០ដុល្លារ ពីម្ចាស់បំណុលដើម្បីយកទៅសងបំណុលជំនួសឪពុកគាត់ហើយមានការយល់ព្រមឱ្យខ្ចីជាលាយលក្ខណ៍អក្សរពីភាគីប្រពន្ធ។

[21] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩២១។

○ សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម៖ ជាកាតព្វកិច្ចដែលកើតឡើងក្រោមរូបភាពដើម្បីថែរក្សា និង គ្រប់គ្រងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

**ឧទាហរណ៍៖** ប្តីខ្ញុំលុយគេមកជួលជុលផ្ទះអស់ ១០០០ដុល្លារ។

សរុបមក កាតព្វកិច្ចសាមគ្គី ជាកាតព្វកិច្ចដែលមានលក្ខណៈសហការគ្នាដោយសមាមាត្រ និងមិនកេងប្រយោជន៍របស់សហព័ទ្ធណាម្ខាងពេកនោះទេ ហើយការសហការគ្នានេះគឺទៅតាមសមត្ថភាពរបស់ភាគី និងទំហំនៃទ្រព្យដែលសហព័ទ្ធមាន ដើម្បីប្រយោជន៍រួម ឬប្រយោជន៍ដោយឡែក។ ម៉្យាងទៀត ម្ចាស់បំណុលក៏មានសិទ្ធិទាមទារអោយប្តីប្រពន្ធទាំងសងខាងសង ឬសហព័ទ្ធណាមួយសងក៏បានទៅតាមការជ្រើសរើសរបស់ម្ចាស់បំណុល។

## ផ្នែកទី៣៖ គុណសម្បត្តិ និងបញ្ហាប្រឈមនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

នៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់ និងការបង្កើតកិច្ចសន្យានេះឱ្យមានរូបរាងឡើងនៅកម្ពុជា គឺដើម្បីឆ្លើយតបទៅនឹងការវិវត្តិតាមសម័យកាល ភាពជឿនលឿនរបស់មនុស្ស ដែលបានចងចំណងជាគ្រួសារនឹងគ្នា។ ជាក់ស្តែង បណ្តាប្រទេសនានានៅសាកលលោកបានប្រើប្រាស់ប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះយូរមកហើយ ក្រោយមកប្រទេសកម្ពុជាបានមើលឃើញពីសារៈសំខាន់នៃកិច្ចសន្យានេះទើបគាត់តែងប្រព័ន្ធនេះអោយលេចរូបរាងឡើង ហើយបានចេញប្រកាសមួយស្តីពីនីតិវិធីចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះផងដែរ។ ប៉ុន្តែ ក្រៅពីអត្ថប្រយោជន៍នានាយ៉ាងច្រើននៃប្រព័ន្ធនេះក៏យើងឃើញមានបញ្ហាប្រឈមនានាផងដែរ ទាក់ទងនឹងបញ្ហាយល់ដឹងរបស់ប្រជាពលរដ្ឋលើប្រព័ន្ធនេះ បញ្ហាយឺតយ៉ាវនៃនីតិវិធី និង បញ្ហាទំនុកចិត្តរវាងប្តីប្រពន្ធពេលបង្កើតកិច្ចសន្យានេះ និងបញ្ហាចន្លោះប្រហោងនៃច្បាប់ជាដើម។

### ៣.១. គុណសម្បត្តិ

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មានសារៈសំខាន់ណាស់ក្នុងការការពារដល់ទ្រព្យសម្បត្តិរបស់សហព័ទ្ធទាំងសងខាង នៅពេលដែលពួកគេទាំងពីរមានវិវាទ ហើយឈានដល់ការលែងលះប្តឹងទៅតុលាការ ដែលតុលាការងាយស្រួលក្នុងការដោះស្រាយ។ សហព័ទ្ធអាចកំណត់នូវទ្រព្យសម្បត្តិទាំងឡាយ មិនថាជាចលនវត្ថុ ឬ អចលនវត្ថុឡើយឱ្យទៅជាទ្រព្យដោយឡែក ឬ ទ្រព្យរួមបាន។ លើសពីនេះសហព័ទ្ធអាចកំណត់នូវសិទ្ធិទៅលើ ទ្រព្យនោះថាជាសិទ្ធិរួម ឬ សិទ្ធិដោយឡែកផ្តាច់មុខរបស់ភាគីណាមួយ។ ការកំណត់ពីទ្រព្យរួម និង ទ្រព្យដោយឡែកឱ្យបានច្បាស់លាស់គឺងាយស្រួលនៅពេលករណីដែលសហព័ទ្ធណាម្នាក់ស្លាប់ សហព័ទ្ធដែលនៅរស់មិនប៉ះពាល់ដល់ប្រយោជន៍ ឬ មិនមានភាពស្មុគស្មាញនៅពេលយកទ្រព្យណាមួយទៅចាត់ចែង។ បើសិនសហព័ទ្ធមិនបានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិនេះទេ នៅពេលលែងលះគឺតុលាការយកបញ្ញត្តិច្បាប់មកធ្វើការដោះស្រាយ។

### ៣.២. បញ្ហាប្រឈម

ក្រៅពីគុណសម្បត្តិនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធក៏មាននូវគុណវិបត្តិមួយចំនួនដូចជាៈ

- នីតិវិធីយឺតយ៉ាវ និង ស្មុគស្មាញ ៖ ទោះជាកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានចែងពីនីតិវិធីនានាក្នុងការចុះបញ្ជីក្តីក៏យើងឃើញថា វានៅមានភាពស្មុគស្មាញ និង សាំញ៉ាំដែលសហព័ទ្ធភាគច្រើនមិនចង់ធ្វើ ដោយសារវាត្រូវឆ្លងកាត់ការបំពេញសំណៅឯកសារច្រើនដោយឆ្លងកាត់ច្រើនតំណាក់កាល ដែលចំណាយពេលវេលាយូរដោយសារប្រកាសនេះមិនបានកំណត់រយៈពេលនៃការចុះបញ្ជី។
- ទីកន្លែងមិនទាន់ឆ្លើយតបនឹងតម្រូវការៈ ទីកន្លែងនៃការចុះបញ្ជីទៀតសោតគឺមានតែមួយកន្លែងនៅភ្នំពេញ ដែលមិនឆ្លើយតបឱ្យបានឆាប់រហ័សដល់ប្រជាពលរដ្ឋទូទាំងប្រទេសនៅឡើយ ហេតុនេះហើយបានជាអ្នកនៅតាមបណ្តាខេត្តមួយចំនួនមិនបានដឹង ឬ មិនចង់ធ្វើកិច្ចសន្យានេះឡើយ។
- ការផ្សព្វផ្សាយនៅមានកម្រិតៈ បន្ថែមពីនេះ ស្ថាប័នរដ្ឋហាក់នៅមានកម្រិតក្នុងការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវការចុះបញ្ជីទ្រព្យសម្បត្តិនេះ ទៅដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានដើម្បីឱ្យពួកគាត់យល់ពីសារៈសំខាន់នៃកិច្ចសន្យាមួយនេះ។ ទោះជាកន្លងមកក្រសួងយុត្តិធម៌ បានធ្វើនូវសិក្ខាសាលានានាណែនាំដល់មន្ត្រី ក៏ដូចជាប្រជាពលរដ្ឋក្តី ក៏មិនទាន់មានប្រសិទ្ធិភាពនៅឡើយ។ ពេលខ្លះការផ្សព្វផ្សាយ គឺមានភាពមិនទូលំទូលាយដែលមានតែអ្នកដែលមានជំនាញច្បាប់ប៉ុណ្ណោះដែលធ្លាប់ឮពីកិច្ចសន្យាប្រភេទនេះ។
- កត្តាទំនុកចិត្តៈ បន្ថែមពីនេះទៀត ប្រជាជនខ្មែរនៅតែយល់ថាការចុះកិច្ចសន្យទ្រព្យសម្បត្តិប្តីប្រពន្ធនេះធ្វើឱ្យពួកគេបាត់បង់ទំនុកចិត្តរវាងគ្នានឹងគ្នា មិនស្មោះត្រង់នឹងគ្នា ហើយថែមទាំងគិតថាសហព័ទ្ធម្ខាងទៀតគិតតែពីទ្រព្យសម្បត្តិជាដើម។ទោះជាមានសហព័ទ្ធខ្លះបានធ្វើការចុះបញ្ជីកិច្ចសន្យានេះរួចហើយក្តី ក៏អាចមានគុណវិបត្តិខ្លះៗដូចជា ការខ្វះភាពសាមគ្គីគ្នាក្នុងការទំនុកបម្រុងជីវភាពគ្រួសារ ជម្លោះនានាក្នុងការប្រើប្រាស់ទ្រព្យដែលជារបស់រួម ឬ ដោយឡែកជាដើម។

# ជំពូកទី២៖ ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិប្ដីប្រពន្ធ

## ផ្នែកទី១៖ ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសកម្ម

តាមស្ថានភាពជាក់ស្ដែង សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នា។ គួសបញ្ជាក់ថា ពាក្យ ***គ្រប់គ្រង*** ជាពាក្យដែលមានន័យមិនសូវច្បាស់លាស់ ហើយក៏មិនមានអត្ថន័យជាក់លាក់ដែលក្រមរដ្ឋប្បវេណីបានកំណត់នោះដែរ។ ដូច្នេះ ការជួសជុលទ្រព្យសម្បត្តិរួម ការជួលទ្រព្យសម្បត្តិរួម ក៏គួរតែត្រូវចាត់ទុកថាជាសកម្មភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរួមដូច្នោះដែរ។[22] ហេតុដូច្នេះហើយ រូបភាពនៃសិទ្ធិលើការគ្រប់គ្រង និងការប្រើប្រាស់ទៅលើទ្រព្យមានច្រើនយ៉ាង ដែលសហព័ទ្ធមានពេញលេញ។ សហព័ទ្ធអាចធ្វើការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យរួមតាមវិធីដូចខាងក្រោមនេះ ៖

### ១.១. ការផ្គត់ផ្គង់ជីវភាព

មនុស្សម្នាក់ៗមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួនក្នុងការផ្គត់ផ្គង់សម្រាប់ជីវភាពរបស់ខ្លួនតាមតម្រូវការចាំបាច់។ ក្នុងករណីដែលប្ដីប្រពន្ធបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិ នោះអ្នកទាំងពីរមានសិទ្ធិគ្រប់គ្រាន់អនុវត្តន៍ការគ្រប់គ្រងទ្រព្យទៅតាមបញ្ញត្តិនៃកិច្ចសន្យានោះ។ ទោះជាកិច្ចសន្យានោះចែងយ៉ាងណាក្ដី ក៏ប្ដីប្រពន្ធទាំងសងខាងត្រូវមានកាតព្វកិច្ចចិញ្ចឹមបីបាច់ថែរក្សាគ្រួសារទាំងមូលដែរ។ ដូចគ្នានេះដែរដោយគិតទៅតាមច្បាប់ មិនថាទ្រព្យនោះជាទ្រព្យដោយឡែក ឬទ្រព្យរួមក្ដី ប្ដីប្រពន្ធអាចប្រើប្រាស់វាសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារទាំងមូល។ ដោយមានទំនាក់ទំនងគ្នាក្នុងចំណងគតិយុត្តនៃអាពាហ៍ពិពាហ៍ ប្ដីប្រពន្ធទាំងពីរមានសិទ្ធិស្មើគ្នាក្នុងការចាត់ចែងក៏ដូចជាប្រើប្រាស់ទ្រព្យរួមរបស់ខ្លួនតាមសេចក្ដីត្រូវការចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃដោយមិនគិតថាអ្នកណាមួយធ្វើការបានប្រាក់ខែ ឬចំណូលផ្សេងៗច្រើននោះទេ ទោះបីជាគ្រួសារខ្លះ ប្រពន្ធនៅធ្វើតែការងារផ្ទះក៏ដោយ។[23] លើសពីនេះ ប្ដីប្រពន្ធមិនអាចចាយវាយទ្រព្យរួមនោះតាមចិត្តចង់របស់ខ្លួនបានឡើយ ដែលនេះអាចធ្វើឲ្យមានការប៉ះពាល់ដល់សិទ្ធិរបស់សហព័ទ្ធម្ខាងទៀត។ ដូចគ្នានឹងបញ្ញត្តិស្ដីពីកម្មសិទ្ធិអវិភាគ មាត្រា២០៨ បានបង្ហាញថា កិច្ចការទាំងឡាយដែលទាក់ទងនឹងការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគ ត្រូវមានការយល់ព្រមដោយមតិភាគច្រើន តាមតម្លៃនៃចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ ដែលត្រូវគ្នានឹងការសម្រេចចិត្តពីសហព័ទ្ធម្នាក់ៗជាដាច់ខាត។ ដូចនេះ ជាគោលការណ៍ ប្ដីប្រពន្ធចូលរួមសហការគ្នា ថែរក្សា ចាត់ចែង ទ្រព្យសម្បត្តិរួមដើម្បីជាប្រយោជន៍គ្រួសារទៅថ្ងៃអនាគត។

[22] វុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, *នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ*, ៣៦០។
[23] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៧៤ កថាខណ្ឌ២។

មានសំណួរលើកឡើងថា ក្នុងករណីដែលទ្រព្យសម្បត្តិមួយចំនួនជារបស់ប្តីដែលប្រើប្រាស់ក្នុងអាជីវកម្មដែលមានមុនពេលអាពាហ៍ពិពាហ៍ តើប្រពន្ធមានសិទ្ធិប្រើប្រាស់ និងទទួលផលប្រយោជន៍ពីចំណូលដែលបានមកពីអាជីវកម្មនោះបានដែរឬទេ។

មុននឹងឈានទៅរកដំណោះស្រាយនៃបញ្ហាដែលបានចោទ យើងត្រូវធ្វើការពិចារណាទៅលើស្ថានភាពខាងលើអំពីផលចំណេញដែលកើតចេញពីអាជីវកម្ម។ វាមានលក្ខណៈដូចគ្នាទៅនឹងបញ្ញត្តិនៃមាត្រា៩៧២ ចំណុច គ ដែលបង្ហាញថា ផលចំណេញពីអាជីវកម្មគឺជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលប្តីមានមុនពេលអាពាហ៍ពិពាហ៍។ ដូច្នេះ វាត្រូវបានចាត់ទុកថាគឺនៅតែជាទ្រព្យសម្បត្តិដោយឡែករបស់ប្តីដដែល។ ប៉ុន្តែ ក្នុងករណីដែលបុគ្គលពីរនាក់មានចំណងគតិយុត្តនឹងគ្នាតាមរយៈអាពាហ៍ពិពាហ៍ នោះអ្នកទាំងពីរត្រូវចេះជួយយកអាសារគ្នាទៅវិញទៅមកមើលថែគ្នា ព្រមទាំងចែករំលែកការគ្រប់គ្រងគ្រួសារផងដែរ។ ហេតុនេះហើយ លទ្ធភាពដែលប្រពន្ធអាចប្រើប្រាស់ទ្រព្យខាងលើបាន គឺអាស្រ័យដោយការយោគយល់ពីបុរសជាប្តីក្នុងន័យចែករំលែកការចិញ្ចឹមបីបាច់ថែរក្សាគ្រួសារ។

### ១.២. ការលក់

យោងតាមបទបញ្ញត្តិនៃមាត្រា៩៧៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ប្តីប្រពន្ធទាំងសងខាងត្រូវតែយល់ព្រមនឹងគ្នាជាដាច់ខាតចំពោះការសម្រេចចិត្ត និងធ្វើការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ខ្លួន លុះត្រាតែស្ថិតក្នុងកាលៈទេសៈណាមួយផ្សេងទើបអាចសម្រេចចិត្តដោយឯកឯងបានដោយទទួលការអនុញ្ញាតពីតុលាការ។

**<u>ឧទាហរណ៍៖</u>** ដោយស្ថិតក្នុងស្ថានភាពទាល់ច្រកដែលពិបាកទាក់ទងលោក បូណា ជាប្តី អ្នកស្រី ផល បានសម្រេចចិត្តលក់ខ្សែកមួយខ្សែដែលជាអំណោយថ្ងៃអាពាហ៍ពិពាហ៍ដើម្បីយកប្រាក់មកព្យាបាលកូនដែលមានជំងឺគ្រុនឈាម។ ក្នុងឧទាហរណ៍ខាងលើនេះ យើងអាចមើលឃើញថាស្ថានភាពរបស់អ្នកស្រី ផល ជាស្ថានភាពមិនអាចពន្យាបាន និងកាលៈទេសៈបង្ខំ ទើបអ្នកស្រីមានសិទ្ធិតាមផ្លូវច្បាប់ក្នុងការចាត់ចែងទ្រព្យសម្បត្តិរួមនោះដោយមិនចាំបាច់មានការយល់ព្រមពីប្តីនោះទេ។ លើសពីនេះទៅទៀត ប្រសិនបើសហព័ទ្ធណាម្ខាងបានលក់ទ្រព្យសម្បត្តិរួមដោយមិនមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត និងមិនមានការអនុញ្ញាតពីស្ថាប័នតុលាការ សហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រមនោះមានសិទ្ធិទាមទារទៅតុលាការឲ្យធ្វើការលុបចោលនូវការលក់នោះបានក្នុងអំឡុងពេល ២ (ពីរ)ឆ្នាំ បើទ្រព្យនោះជាអចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ និងនៅក្នុងអំឡុងពេល ១ (មួយ)ឆ្នាំ បើទ្រព្យនោះជាទ្រព្យសម្បត្តិផ្សេង។[24] ជាពិសេស ចំពោះអចលនវត្ថុសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ ក្នុងចំណោមទ្រព្យសម្បត្តិរួម កាលៈទេសៈនេះកំណត់អំឡុង

[24] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៧៦ ថ្មី កថាខណ្ឌ៣។

ពេលវែង ដើម្បីឲ្យមានភាពប្រាកដប្រជាចំពោះការការពារការអាស្រ័យនៅ។ ម្យ៉ាងទៀត ភាគីម្ខាងទៀតនៃការជួញដូរ ចាំបាច់ត្រូវធ្វើការស្រាវជ្រាវបញ្ជាក់ថា ក្នុងបញ្ជីកម្មសិទ្ធិមានសហព័ទ្ធដែលមិនមានឈ្មោះ។[25] ក្រៅពីនេះ សហព័ទ្ធក៏អាចបង្កើតកិច្ចសន្យាលក់ទិញលើកម្មវត្ថុដែលមិនទាន់បានបញ្ចប់សព្វគ្រប់បានដែរ។[26] ឧទាហរណ៍៖ ការលក់ផ្ទះល្វែងដែលកំពុងសាងសង់ជាដើម។

លើសពីនេះទៅទៀត ទ្រព្យដោយឡែកខ្លះត្រូវបានប្រែក្លាយជាទ្រព្យរួម ប៉ុន្តែសហព័ទ្ធមិនបានជូនដំណឹងជាសាធារណៈជាទ្រព្យរួម ដោយការចុះបញ្ជី ឬ អង្គហេតុអាស្រ័យនៅនោះទេ។ ហេតុនេះ វាអាចជាបញ្ហាធ្ងន់ធ្ងរមួយសម្រាប់សហព័ទ្ធដែលមិនមានឈ្មោះក្នុងបញ្ជីកម្មសិទ្ធិ ដែលអាចនឹងត្រូវបាត់បង់សិទ្ធិចំពោះការចាត់ចែងនេះ។ ហេតុដូចនេះ ពុំមានមធ្យោបាយណាដើម្បីសង្គ្រោះសហព័ទ្ធដែលបាត់បង់ទ្រព្យរួមដែលមិនត្រូវបានបញ្ជាក់ដោយការចុះបញ្ជី ឬអង្គហេតុអាស្រ័យនៅ លើកលែងតែករណីដែលតតិយជនដែលធ្វើលទ្ធកម្មដោយទុច្ចរិត និងមានកំហុស ឬដោយមិនគិតថ្លៃ ហើយបញ្ហានេះត្រូវដោះស្រាយរវាងសហព័ទ្ធ។ នេះបានន័យថា ប្រសិនបើការលក់នោះរួមបញ្ចូលដោយអំពើទុច្ចរិត និងមានកំហុសពីតតិយជន សហព័ទ្ធម្ខាងទៀតនឹងមិនត្រូវបានបំពានសិទ្ធិលើទ្រព្យរួមនោះទេ តាមរយៈការលុបចោល ឬមធ្យោបាយផ្សេងជាដើម។

### ១.៣. ការប្រើប្រាស់ក្នុងភតិសន្យា

ជាទូទៅ ការដាក់ជួលទ្រព្យសម្បត្តិរួម ក៏ជាផ្នែកមួយនៃការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិផងដែរ។ នេះជាការទទួលបានផលប្រយោជន៍ដែលសហព័ទ្ធមានពីការប្រើប្រាស់ទ្រព្យសម្បត្តិ។ សហព័ទ្ធមានសេរីភាព និងសិទ្ធិគ្រប់គ្រាន់ទៅលើការដាក់ជួលទ្រព្យសម្បត្តិរបស់ខ្លួនដើម្បីមានចំណូលបន្ថែមទៅលើការផ្គត់ផ្គង់ជីវភាពគ្រួសារ។ បញ្ញត្តិដែលទាក់ទងទៅនឹងការដាក់ជួលទ្រព្យសម្បត្តិរួមនេះ គឺសហព័ទ្ធទាំងសងខាងត្រូវយល់ព្រមជាមួយគ្នាក្នុងការសម្រេចចិត្តដាក់ជួលចលនវត្ថុ ឬអចលនវត្ថុណាមួយនោះ ទោះបីជាមើលទៅឃើញថា ការដាក់ជួល គឺនឹងទទួលបានផលប្រយោជន៍ ហើយសហព័ទ្ធណាម្ខាងអាចសម្រេចចិត្តម្នាក់ឯងបានក៏ពិតមែន ប៉ុន្តែវាហាក់ដូចជាបំពានសិទ្ធិសហព័ទ្ធម្ខាងទៀតដែលមានលើទ្រព្យសម្បត្តិរួមនោះដែរ។ ហេតុដូចនេះហើយ ទើបច្បាប់តម្រូវឲ្យប្តីប្រពន្ធមានសិទ្ធិស្មើគ្នាលើទ្រព្យសម្បត្តិរួម និងធ្វើការសម្រេចចិត្តត្រូវគ្នាមុនឈានដល់ការចាត់ចែង និងគ្រប់គ្រងទ្រព្យសម្បត្តិរួមណាមួយបាន។ បើយោងតាមបទបញ្ញត្តិនៃភតិសន្យា សហព័ទ្ធទាំងសងខាងអាចដាក់ឲ្យភាគីម្ខាងទៀតប្រើប្រាស់ និងអាស្រ័យផលពីចលនវត្ថុ ឬអចលនវត្ថុណាមួយបានដោយយកថ្លៃឈ្នួល។[27] សូមធ្វើការពិចារណានូវឧទាហរណ៍ខាងក្រោម៖

---

[25] សេចក្តីកំណត់មាត្រានីមួយៗក្រមរដ្ឋប្បវេណីកម្ពុជា, មាត្រា៩៧៦ កថាខណ្ឌ ៣។

[26] អៀង សំណាង, *កិច្ចសន្យាពិសេស* (២០១៤), ៧។

[27] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៥៩៦។

**ឧទាហរណ៍ទី១៖** លោក ជា និងអ្នកស្រី ធីតា គឺជាប្តីប្រពន្ធនឹងគ្នា។ ក្នុងចំណោមទ្រព្យរួមរបស់អ្នកទាំងពីរ ក៏មានតូបលក់អីវ៉ាន់ចំនួនពីរនៅឯផ្សារ។ ដោយមានការមមារញឹកនឹងការងារខាងក្រៅ អ្នកទាំងពីរបានសម្រេចដាក់ជួលតូបទាំងនោះទៅឲ្យអ្នកដទៃដោយយកកម្រៃ។

ក្នុងឧទាហរណ៍ខាងលើនេះ សហព័ទ្ធទាំងពីរបានសម្រេចធ្វើការចាត់ចែងទ្រព្យរួមរបស់ខ្លួនដែលជាចលនវត្ថុទៅឲ្យអ្នកដទៃក្នុងគោលដៅស្វែងរកប្រាក់ចំណេញ។ ការអនុវត្តបែបនេះ គឺមានជារឿយៗនៅតាមទីផ្សារនានា ជាពិសេស ការជួលពីសំណាក់អាជីវករជាច្រើនចំពោះតូបលក់របស់អ្នកគ្រប់គ្រងផ្សារ ដែលបង្កើតបានជាកិច្ចសន្យាជួលសាមញ្ញមួយ និងមិនមានភាពស្មុគស្មាញចំពោះអ្នកបើករបររកស៊ីជាដើម។

**ឧទាហរណ៍ទី២៖** លោកជា និងអ្នកស្រីធីតា មានដីស្រែមួយកន្លែងនៅឯខេត្ត។ ដោយមានការស្នើសុំពីកសិករនៅឯភូមិនៃដីស្រែនោះក្នុងគោលបំណងប្រើប្រាស់ និងអាស្រ័យផល(ធ្វើស្រែយកទិន្នផល) អ្នកទាំងពីរក៏បានយល់ព្រមដាក់ជួលដីស្រែនោះទៅឲ្យកសិករដោយយកកម្រៃ។

ក្នុងឧទាហរណ៍ខាងលើនេះ អ្នកទាំងពីរបានសម្រេចចិត្តធ្វើការចាត់ចែងទ្រព្យរួមរបស់ខ្លួនដែលជាអចលនវត្ថុទៅឲ្យអ្នកដទៃដើម្បីបានប្រាក់ចំណេញបន្ថែមផ្គត់ផ្គង់ជីវភាពគ្រួសារ។ កិច្ចសន្យាដែលមានកម្មវត្ថុជាអចលនវត្ថុបែបនេះ វាជាការប្រសើរជាងក្នុងករណីដែលប្តីប្រពន្ធធ្វើវាជាលាយលក្ខណ៍អក្សរ ដើម្បីគ្រាន់តែជាការការពារផលប្រយោជន៍ភាគីទាំងសងខាង។[28]ម្យ៉ាងវិញទៀត យោងតាមបញ្ញត្តិស្តីអំពីភតិសន្យាអចលនវត្ថុ ការបង់ថ្លៃឈ្នួលគឺអាស្រ័យទៅតាមការប្រើប្រាស់វត្ថុជាក់ស្តែងដែលអាចបង់ជាខែ ឆ្នាំជាដើម។ ហេតុនេះ តាមឧទាហរណ៍ខាងលើ ការប្រើប្រាស់ និងអាស្រ័យផលពីដីស្រែ គឺទទួលទិន្នផលតាមរដូវ ដែលកសិករត្រូវបង់កម្រៃជារដូវដល់ប្តីប្រពន្ធទាំងពីរ។

ប្តីប្រពន្ធដែលជាកម្មសិទ្ធិករលើកម្មវត្ថុនៃការជួល អាចធ្វើអនុប្បទានវាទៅឲ្យអ្នកដទៃបានដែលនេះអាចនាំឲ្យមានការប៉ះពាល់ដល់ផលប្រយោជន៍ ជាពិសេសក្នុងករណីនៃការជួល ឬភតិ-សន្យាអចលនវត្ថុ។ ហេតុដូច្នេះ ប្តីប្រពន្ធដែលជាម្ចាស់កិច្ចសន្យាជួលមិនអាចបំពានសិទ្ធិអ្នកជួលបានទេ ក្នុងករណីដែលគេពឹងផ្អែកទៅលើអង្គហេតុថា បានកាន់កាប់ និងប្រើប្រាស់ និងអាស្រ័យផលពីអចលនវត្ថុជួលនោះជាបន្តបន្ទាប់។[29] នេះសរបញ្ជាក់ឲ្យឃើញថា ទោះជាមានទ្រព្យច្រើនប៉ុណ្ណាក៏ដោយ ប្តីប្រពន្ធត្រូវតែប្រើប្រាស់ និងចាត់ចែងវាក្នុងទំហំមួយដែលសមស្រប និងមិនប៉ះពាល់ផលប្រយោជន៍អ្នកដទៃ ដោយមិនមែនធ្វើវាដើម្បីប្រាក់ចំណេញតាមតែចិត្តខ្លួនឯងនោះទេ។

[28] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៣៣៦ កថាខណ្ឌ២។

[29] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ២, ៣១។

ប្រសិនបើការបង្កើតភតិសន្យា មានរយៈពេលលើសពី១៥ឆ្នាំ នោះសហាព័ទ្ធត្រូវអនុវត្តន៍ទៅតាមកិច្ចសន្យាស្តីពីសិទ្ធិជួលអចិន្ត្រៃយ៍។[30]

### ១.៤. ប្រទានកម្ម

ប្រទានកម្ម គឺជាកិច្ចសន្យាដែលមានសំណើរ និងស្ទីការ ដែលអានុភាពរបស់វាមាននៅពេលភាគីម្ខាងបានបង្ហាញឆន្ទៈផ្តល់ទ្រព្យសម្បត្តិទៅឲ្យភាគីម្ខាងទៀត ដោយមិនគិតកម្រៃ និងស្របពេលដែលភាគីម្ខាងទៀតនោះបានសម្រេចចិត្តយល់ព្រមទទួល។[31]

ដូចគ្នានេះដែរ សហាព័ទ្ធនីមួយៗអាចធ្វើប្រទានកម្មទៅឲ្យបុគ្គលដទៃទៀតនូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន។ ម្យ៉ាងវិញទៀត ចំណុច ខ នៃមាត្រា៩៧២(ទ្រព្យសម្បត្តិដោយឡែក)នៃក្រមរដ្ឋប្បវេណី ក៏បានកំណត់ច្បាស់លាស់នូវទ្រព្យដោយឡែករបស់សហាព័ទ្ធដែលបានមកពីប្រទានកម្មពីបុគ្គលដទៃដែលនេះហើយអាចបញ្ជាក់បានថា សហាព័ទ្ធដែលជាម្ចាស់កម្មសិទ្ធិមានសិទ្ធិពេញលេញក្នុងការធ្វើប្រទានកម្មបន្តទៅឲ្យអ្នកដទៃទៀត។ ឧទាហរណ៍៖ លោក ផល ទទួលបានម៉ូតូ១គ្រឿងពីថៅកែក្រុមហ៊ុនរបស់គាត់ ដោយសារតែគាត់ធ្វើការងារបានល្អ។ ជាមួយគ្នានេះដែរ លោក ផល អាចសម្រេចចិត្តដោយឯកឯងឲ្យម៉ូតូនោះទៅប្អូនប្រុស ឬអ្នកដទៃទៀតបាន។ ចំពោះទ្រព្យសម្បត្តិរួមវិញ ប្រសិនបើសហាព័ទ្ធមានបំណងធ្វើប្រទានកម្មទៅឲ្យតតិយជន អ្នកទាំងពីរត្រូវតែយល់ព្រមនឹងគ្នាសម្រេចចិត្តធ្វើប្រទានកម្មនោះ ព្រោះអ្នកទាំងពីរមានឈ្មោះជាសហកម្មសិទ្ធិលើកម្មវត្ថុនៃប្រទានកម្ម។ ឧទាហរណ៍ថា ប្តីប្រពន្ធមួយគូរបានសម្រេចចិត្តប្រគល់ដីមួយកន្លែងទៅឲ្យលោក បូណា និងគ្រួសារ ដោយសារតែយល់ឃើញថា ស្ថានភាពជីវភាពរបស់ពួកគាត់មានភាពក្រខ្សត់ និងមិនមានដីសម្រាប់សង់លំនៅឋាន។ ត្រង់ឧទាហរណ៍ខាងលើនេះ ប្តីប្រពន្ធបានយល់ព្រមគ្នាផ្តល់ដីទៅឲ្យអ្នកដទៃ ហើយអ្នកដទៃក៏បានយល់ព្រមទទួលនូវកម្មវត្ថុនោះដោយមានបញ្ជាក់ច្បាស់លាស់នៅក្នុងឯកសារ។ ផ្ទុយទៅវិញ ប្រសិនបើមានការរំលោភលើទំនុកចិត្តធ្ងន់ធ្ងរចំពោះទាយក(អ្នកប្រគល់) ទាយកអាចលុបចោលប្រទានកម្មនោះបាន។[32] ក្នុងឧទាហរណ៍ខាងលើនេះដដែល ប្រសិនបើគ្រួសារក្រខ្សត់នោះមានគំនិតទុច្ចរិតដោយការបន្លំភ្នែកអ្នកដទៃថាខ្លួនគ្មានដីសម្រាប់សង់លំនៅឋាន ប្តីប្រពន្ធដែលជាទាយកអាចដកហូតដីនោះមកវិញបានដោយផ្អែកតាមបញ្ញត្តិស្តីពីការសងនៃសេចក្តីចម្រើនដោយឥតហេតុបាន[33] និងត្រូវអនុវត្តទៅតាមពេលវេលាដែលមានកំណត់នៅក្នុងកថាខណ្ឌ២នៃមាត្រា៥៧១។ គួកត់សម្គាល់ផងដែរថា ក្នុងអត្ថន័យនៃប្រទានកម្ម ប្តីប្រពន្ធបានសម្តែងឆន្ទៈប្រគល់កម្មវត្ថុទៅឲ្យអ្នកណា គឺអ្នកនោះមានឈ្មោះជាម្ចាស់កម្មសិទ្ធិ ដោយ

---

[30] អៀង សំណាង, *កិច្ចសន្យាពិសេស* (២០១៤), ៦១។

[31] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៥៦៨។

[32] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៥៧១ កថាខណ្ឌ១។

[33] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៥៧៣។

ការពិនិត្យមើលទៅលើស្ថានភាពជាក់ស្តែងនៃការធ្វើប្រទានកម្មនោះ។[34] អាចនឹងមានសំណួរលើកឡើងថា តើសហាព័ទ្ធអាចដកហូតកម្មវត្ថុនៃប្រទានកម្មវិញបានដែរឬទេ ក្នុងករណីដែលទាយកផ្ទាល់បានជួបបញ្ហាជីវភាពគ្រួសារ? តាមស្ថានភាពជាក់ស្តែង បុគ្គលនានានឹងត្រូវបានជួយស្វែងរកយុត្តិធម៌នៅក្នុងសង្គម។ ដូចគ្នានេះដែរ តុលាការនឹងស្វែងរកដំណោះស្រាយជូនចំពោះបុគ្គលដែលជួបបញ្ហានានា។ ក្នុងស្ថានភាពនៃចម្ងល់ខាងលើ ករណីដែលប្តីប្រពន្ធ (ទាយក) ធ្លាក់ខ្លួនក្នុងស្ថានភាពទីទាល់ក្រ និងមានកាតព្វកិច្ចបង់នូវអាហារកាតព្វកិច្ច នោះអ្នកទាំងពីរអាចលុបចោលប្រទាន-កម្មវិញបាន។[35]

## ១.៥. ការប្រើប្រាស់ក្នុងពាណិជ្ជកម្ម

ពាក្យពាណិជ្ជកម្មនៅត្រង់នេះ គឺមានន័យសាមញ្ញថា ការបើកអាជីវកម្ម ឬការរកស៊ី។ មិនខុសគ្នាពីបញ្ហាដែលទាក់ទងនឹងទ្រព្យរួម ទ្រព្យដោយឡែកនោះឡើយ ដែលប្តីប្រពន្ធអាចប្រើប្រាស់សម្រាប់បើករកស៊ីបាន។ ប្តី ឬប្រពន្ធមានសិទ្ធិប្រើប្រាស់ទ្រព្យរៀងៗខ្លួនដើម្បីបើកអាជីវកម្មបានដោយមិនពាក់ព័ន្ធនឹងសហាព័ទ្ធម្ខាងទៀតនោះឡើយ។ ក៏ប៉ុន្តែ នៅក្នុងសង្គមជាក់ស្តែង ដោយផ្អែកលើស្មារតីរួមរស់នៅ និងទទួលខុសត្រូវលើគ្នាទៅវិញទៅមក ប្តីប្រពន្ធចូលរួមសហការគ្នា និងផ្តល់យោបល់ទៅលើការសម្រេចចិត្តរបស់សហាព័ទ្ធម្ខាងទៀត។ ក្រៅពីនេះ សហាព័ទ្ធអាចប្រើប្រាស់ទ្រព្យដោយឡែករបស់ខ្លួន ដោយការចូលរួមភាគហ៊ុនគ្នាតាមការព្រមព្រៀងគ្នា។ ដើម្បីធានាសិទ្ធិរៀងៗខ្លួន អ្នកទាំងពីរអាចធ្វើកិច្ចសន្យាអាជីវកម្មមួយដោយការវិនិយោគទ្រព្យធនរៀងៗខ្លួន ហើយប្រកបកិច្ចការដោយសហការគ្នា ដែលអនុវត្តទៅតាមបញ្ញត្តិនៃកិច្ចសន្យាក្រុមហ៊ុន។[36] យោងតាមខ្លឹមសារនេះ ទ្រព្យធនរបស់សហាព័ទ្ធនីមួយៗ និងទ្រព្យសម្បត្តិអាជីវកម្មផ្សេងៗទៀត ត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហាព័ទ្ធទាំងពីរ។ ហើយវាជាការល្អបន្ថែមទៀត នៅពេលដែលប្តីប្រពន្ធទាំងពីរបានសម្រេចចិត្តផ្លាស់ពីទ្រព្យដោយឡែកទៅជាទ្រព្យរួម ដើម្បីងាយស្រួលក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារ។ ក្នុងន័យនេះ ប្តីប្រពន្ធទាំងពីរមានសិទ្ធិសេរីភាពប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ខ្លួនសម្រាប់ការបើកអាជីវកម្មក្នុងមុខរបរប្រចាំថ្ងៃ។ ឧទាហរណ៍ ប្តីប្រពន្ធយកដើមទុនបើករកស៊ីលក់ចាប់ហួយដើម្បីជាចំណូលសម្រាប់ជីវភាពគ្រួសារ។ ក្រៅពីនេះ នៅក្នុងបរិបទដែលសហាព័ទ្ធរួមគ្នាបង្កើតអាជីវ-កម្មខ្នាតធំដូចជា ក្រុមហ៊ុនអាជីវកម្មជាដើម វាគឺជាបញ្ហាមួយផ្សេងដែលត្រូវអនុវត្តទៅតាមបញ្ញត្តិស្តីអំពីក្រុមហ៊ុន។ ពេលខ្លះ សហាព័ទ្ធម្ខាងជាពាណិជ្ជករតាំងពីមិនទាន់រៀបអាពាហ៍ពិពាហ៍ ប៉ុន្តែ សហាព័ទ្ធម្ខាងទៀតក៏អាចក្លាយជាពាណិជ្ជករដែរ បើសហាព័ទ្ធនោះប្រកបរបរពាណិជ្ជកម្មដែលមានចុះក្នុង

[34] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, *នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ,* ៣៥៤។
[35] អៀង សំណាង, *កិច្ចសន្យាពិសេស* (២០១៤), ៣២។
[36] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៧០០។

បញ្ជីពាណិជ្ជកម្មដោយឡែក។[37] បានន័យថា បើសហព័ទ្ធនៃពាណិជ្ជករគ្រាន់តែជួយការងារពាណិជ្ជកម្មរបស់សហព័ទ្ធម្ខាងទៀត សហព័ទ្ធនោះមិនត្រូវបានចាត់ទុកថាជាពាណិជ្ជករនោះទេ។

នៅក្នុងបរិបទនៃពាណិជ្ជកម្ម និងយោងតាមមាត្រា១៦ ២០ និងមាត្រា២១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម បានបង្ហាញប្រភេទផ្សេងៗគ្នាទាំងបីនៃភាគទុនដែលមានដូចជា ភាគទុនជាសាច់ប្រាក់ ភាគទុនជាវត្ថុ និងភាគទុនជាសេវាដែលអាចជាចំណេះដឹង ឬជាបទពិសោធន៍។[38] ដូចគ្នានេះដែរ សហព័ទ្ធម្ខាងអាចជ្រើសរើសជម្រើសណាមួយដែលខ្លួនមានលទ្ធភាពក្នុងការចូលហ៊ុនគ្នាបើកអាជីវកម្ម។ ឧទាហរណ៍ដូចជាករណីដែលនារីជាប្រពន្ធមានប្រាក់ច្រើនល្មមនឹងបើកអាជីវកម្ម ហើយបុរសជាប្តីមានជំនាញខាងកំព្យូទ័រ ដែលអ្នកទាំងពីរបានព្រមព្រៀងគ្នាបង្កើតហាងលក់ និងជួសជុលកំព្យូទ័រ។ នៅក្នុងឧទាហរណ៍នេះ ប្រាក់របស់ប្រពន្ធគឺជាទុនជាសាច់ប្រាក់ រីឯជំនាញខាងកំព្យូទ័រគឺជាទុនជាចំណេះដឹង និងជំនាញ ហើយដែលវានឹងត្រូវបានវាយតម្លៃជាសាច់ប្រាក់តាមការព្រមព្រៀងរវាងប្តីប្រពន្ធដើម្បីងាយស្រួលក្នុងការបែងចែកផលចំណេញ។ ប៉ុន្តែ នៅក្នុងស្មារតីនៃក្តីស្រឡាញ់ ការគោរពគ្នាទៅវិញទៅមក និងការមានទំនួលខុសត្រូវរវាងសហព័ទ្ធនៅក្នុងគ្រួសារ អ្នកទាំងពីរមិនចាំបាច់បែងចែកផលចំណេញនោះទេ ពោលគឺវាបានធ្លាក់ទៅជាទ្រព្យរួមដោយផ្អែកតាមចំណូលក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ទៅហើយ។

ទោះជាយ៉ាងនេះក៏ដោយ ប្រសិនបើក្រឡេកទៅមើលប្រភេទជាក់លាក់នៃក្រុមហ៊ុនដែលប្តីប្រពន្ធជ្រើសរើស វាអាចនឹងមានភាពស្មុគស្មាញក៏ថាបាន។ ក្រុមហ៊ុនមូលធន គឺជាក្រុមហ៊ុនមួយប្រភេទដែលមានភាគហ៊ុន ឬដើមទុនច្រើន។ ក្រុមហ៊ុនប្រភេទនេះ អាចត្រូវបានបង្កើតឡើងដោយបុគ្គលចាប់ពីពីរនាក់ និង កំណត់ភាគហ៊ុនច្បាស់លាស់ដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់វា ដូចជាការកំណត់ភាគហ៊ុនដែលមិនតិចជាងមួយពាន់ភាគហ៊ុន និងមួយភាគហ៊ុនមានតម្លៃមិនតិចជាង ៤០០០៛នោះទេ ហើយនឹងមានការកំណត់ដើមទុនជាក់លាក់នៅក្នុងបញ្ជីនៅពេលបង្កើតក្រុមហ៊ុន។[39] អាស្រ័យដោយមានការកំណត់ជាក់លាក់នេះហើយ វាមិនចោទជាបញ្ហាស្មុគស្មាញនោះទេចំពោះសហព័ទ្ធដែលមានបំណងបង្កើតក្រុមហ៊ុនមួយនេះ។ បានន័យថា ប្តីប្រពន្ធត្រូវចូលរួមភាគហ៊ុនជាមួយគ្នាដោយកំណត់ភាគហ៊ុនច្បាស់លាស់រៀងៗខ្លួននៅក្នុងលក្ខន្តិកៈ។ ដូច្នេះ ការទទួលបានប្រាក់ចំណេញ និងការខាតបង់ ត្រូវធ្វើឡើងទៅតាមសមាមាត្រ ឬមិនសមាមាត្រភាគហ៊ុនដែលមានចែងនៅក្នុងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុង។[40]

[37] ច្បាប់ស្តីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម, មាត្រា៦ កថាខណ្ឌ១។
[38] កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម* (២០១៥), ៨៦។
[39] កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម* (២០១៥), ២៨១។
[40] គង់ សាផន, *នីតិពាណិជ្ជកម្ម* (២០១២), ២២០។

**ឧទាហរណ៍៖** ប្តីប្រពន្ធបានចាប់ផ្តើមក្រុមហ៊ុនដោយមានភាគហ៊ុន២០០០ និងតម្លៃនីមួយៗគឺ ១០ដុល្លាអាមេរិច ដែលមានចែងច្បាស់លាស់នៅក្នុងបទបញ្ជា។ ប្រពន្ធចូលរួម១៥០០ភាគហ៊ុន ដែលស្មើនឹង៧៥% រីឯប្តីចូលរួម៥០០ភាគហ៊ុនដែលស្មើនឹង២៥% នៃភាគហ៊ុនទាំងមូល។

តាមករណីខាងលើនេះ ប្តីប្រពន្ធបានចាប់ផ្តើមអាជីវកម្មរបស់ខ្លួន គឺក្រុមហ៊ុនមូលធនមួយ ដែលអ្នកទាំងពីរកំណត់ចំណែកហ៊ុនរបស់ខ្លួននៅក្នុងបទបញ្ជា។ ដូច្នេះ ផលចំណេញដែលពួកគេនឹងទទួលបាន ក៏មានចំណែកទៅតាមភាគរយនៃចំណែកហ៊ុនរបស់ខ្លួនដែរ។ ប្រសិនបើទទួលបាន ចំណូល៥០០០ដុល្លាក្នុងមួយខែ នោះប្តីទទួលបាន១២៥០ដុល្លា រីឯប្រពន្ធទទួលបាន៣៧៥០ ដុល្លា។

ចំពោះក្រុមហ៊ុនសហកម្មសិទ្ធិវិញ ប្តីប្រពន្ធក៏មានជម្រើសបង្កើតវាដែរ។ វាមានភាពខុសប្លែកពីក្រុមហ៊ុនមូលធនដែលមិនកំណត់ពីដើមទុនអប្បបរមាជាក់លាក់នោះទេ។[41] ជាគោលការណ៍ សហកម្មសិទ្ធិករទាំងអស់ត្រូវទទួលខុសត្រូវដោយគ្មានកំណត់ និងដោយសាមគ្គីភាពលើបំណុលទាំងអស់របស់ក្រុមហ៊ុន។ ចំពោះផលប្រយោជន៍របស់សហកម្មសិទ្ធិករម្នាក់ៗនៅក្នុងទ្រព្យសម្បត្តិ ប្រាក់ចំណេញ និងការខាតបង់ គឺមានសមាមាត្រស្មើគ្នា លើកលែងតែមានចែងនៅក្នុងកិច្ចសន្យា។[42] ដូចគ្នានេះដែរ សហព័ទ្ធទាំងពីរសម្រេចចិត្តរួមគ្នាបង្កើតក្រុមហ៊ុនមួយនេះដោយដើមទុនរបស់ខ្លួននៅក្នុងគ្រួសារ។ ទោះជាភាគីម្ខាងណាចូលរួមថវិកាប៉ុន្មានក៏ដោយ អ្នកទាំងពីរមានសិទ្ធិទទួលបានផលចំណេញស្មើគ្នា និងត្រូវទទួលខុសត្រូវដោយសាមគ្គីគ្នាលើកាតព្វកិច្ចដែលមាន។ ប៉ុន្តែប្រសិនបើមានចែងនៅក្នុងកិច្ចសន្យា ពួកគេត្រូវអនុវត្តទៅតាមកិច្ចសន្យា។

**ឧទាហរណ៍៖** លោក សល់ និងអ្នកស្រី កល្យាន បានរៀបការនឹងគ្នាអស់រយៈពេលជាង៥ ឆ្នាំទៅហើយ។ កាលពីប៉ុន្មានថ្ងៃមុន លោក សល់ បានទទួលអំណោយកាមេរ៉ាម៉ាកCanonពីថៅហ្វាយរបស់គាត់។ ក្រោយមកទៀត លោក ព្រមទាំងភរិយា បានពិភាក្សាគ្នាបើកហាង ថតរូប និងផ្តិតរូប ដោយអ្នកស្រី កល្យាន ជាអ្នកចេញដើមទុន៣០០០ដុល្លា ហើយលោក សល់ ជាអ្នកចេញលើកាមេរ៉ា និងចំណេះជំនាញដែលគាត់បានរៀនបន្ថែមសម្រាប់មុខរបរមួយនេះ។

ក្នុងឧទាហរណ៍ខាងលើនេះ លោក សល់ និងអ្នកស្រី កល្យាន បានរួមគ្នាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិដោយ ប្តីជាអ្នកចេញសម្ភារៈ និងចំណេះដឹង រីឯប្រពន្ធជាអ្នកចេញថវិកាសម្រាប់ដើមទុនរកស៊ីមួយនេះ។ ក្នុងន័យនេះ កាមេរ៉ា និងចំណេះជំនាញនឹងត្រូវបានវាយតម្លៃទៅជាសាច់ប្រាក់តាមការព្រមព្រៀងរវាងសហព័ទ្ធ។ ដូច្នេះ ស្ថានភាពបែបនេះអាចបញ្ជាក់បានថា លោក សល់ និងអ្នកស្រី កល្យាណ នឹងទទួលបានចំណូលស្មើគ្នា ពោលគឺចំណូលទាំងប៉ុន្មាននឹងក្លាយជាទ្រព្យរួម

[41] គង់ សាផន, *នីតិពាណិជ្ជកម្ម* (២០១២), ១៦២។
[42] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥, មាត្រា២៤ កថាខណ្ឌ១។

ដែលដូចគ្នានឹងបញ្ញត្តិនៃចំណូលក្នុងគ្រួសារក្នុងអំឡុងពេលអាពាហ៍ពិពាហ៍នោះដែរ។ ផ្ទុយទៅវិញ ប្រសិនបើសហព័ទ្ធជ្រើសរើសយកវិធីកំណត់ប្រាក់ចំណេញ ការទទួលខុសត្រូវ នៅក្នុងកិច្ចសន្យាច្បាស់លាស់ នោះអ្នកទាំងពីរមិនអាចទទួលបានប្រាក់ចំណេញដោយសមាមាត្រស្មើគ្នាឡើយ។

## ផ្នែកទី២៖ ការគ្រប់គ្រង និងការចាត់ចែងលើទ្រព្យអកម្ម

### កាតព្វកិច្ច ឬបំណុល

ជាធម្មតា ប្រសិនបើសហព័ទ្ធណាម្ខាងមានកាតព្វកិច្ចលើបំណុលអ្នកដទៃ នោះវាជាបន្ទុករបស់សហព័ទ្ធនោះ។ ប៉ុន្តែចំណុចដែលត្រូវពិចារណានោះគឺ នៅពេលដែលសហព័ទ្ធទាំងពីរជំពាក់បំណុលអ្នកដទៃ ពួកគេត្រូវមានកាតព្វកិច្ចលើបន្ទុកនៃបំណុលនោះ។ ម្យ៉ាងវិញទៀត ចំពោះការសងបំណុល អ្នកទាំងពីរមានបន្ទុកស្មើគ្នាទៅលើកាតព្វកិច្ចនោះ ឬសហព័ទ្ធណាម្ខាងយល់ព្រមទទួលបន្ទុកច្រើនជាង ឬ សហព័ទ្ធណាម្ខាងយល់ព្រមទទួលបន្ទុកទាំងអស់ ព្រោះនេះគឺជាការស្ម័គ្រចិត្តរបស់ភាគី។ ជាធម្មតា ការទទួលបន្ទុកទៅលើបំណុលមានពីរប្រភេទដូចជា ការសងដោយការព្រមព្រៀងគ្នា និងការសងដោយមិនមានការព្រមព្រៀង។ វាអាចត្រូវបានទាញចេញជា បំណុលរួម និងបំណុលដោយឡែក។

ចំពោះបំណុលដែលកើតឡើងមុនពេលអាពាហ៍ពិពាហ៍ មិនអាចត្រូវបានចាត់ជាបំណុលរួមក្រោយពេលអាពាហ៍ពិពាហ៍នោះឡើយ ព្រោះវាជាការសម្រេចចិត្តដោយឯកឯង និងជាបញ្ហាផ្ទាល់ខ្លួនតាំងពីដំបូងរបស់សហព័ទ្ធ។ ម្យ៉ាងទៀត ទោះជាកាតព្វកិច្ចកើតឡើងអំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ ប្រសិនបើសហព័ទ្ធបង្កើតវាឡើងដោយការសម្រេចចិត្តឯកឯង និងមិនពាក់ព័ន្ធនឹងផលប្រយោជន៍គ្រួសារ ឬជីវភាពគ្រួសារ តែជាផលប្រយោជន៍ផ្ទាល់ខ្លួន ឬការខ្ចីដើម្បីលេងល្បែងស៊ីសងជាដើមទេ វានៅតែជាបំណុលដោយឡែកដដែល។ ម្យ៉ាងវិញទៀត កាតព្វកិច្ចដែលកើតឡើងដោយសារតែការគ្រប់គ្រង ថែរក្សាទ្រព្យដោយឡែក ជាបន្ទុករបស់ភាគីម្ខាងដូចជាការជួសជុលយានជំនិះផ្ទាល់ខ្លួនជាដើម។ ករណីខ្លះទៀត សហព័ទ្ធម្ខាងទទួលខុសត្រូវលើកាតព្វកិច្ចដែលកើតឡើងពីអំពើអនីត្យានុកូលរបស់ខ្លួនដោយចេតនាក្តី ឬអចេតនាក្តី។[43]

<u>**ឧទាហរណ៍៖**</u> បុរសជាប្តីបានបង្ករគ្រោះថ្នាក់ចរាចរណ៍ដល់អ្នកដទៃ ដោយត្រូវចេញសងថ្លៃខូចខាត ៥០០$។ បន្ថែមពីលើនេះទៀត ក៏អាចមានបំណុលដែលអាចកើតឡើងដោយសារប្រទានកម្ម អច្ច័យទាន ឬសន្តតិកម្មដែលកើតឡើងនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ផងដែរ។[44]
<u>***ឧទាហរណ៍ទី១ (អំពីប្រទានកម្ម)៖***</u> ដោយមិនមានអ្នកមើលការខុសត្រូវលើឃ្លាំងឡាន លោក ស័កបានសម្រេចចិត្តប្រគល់វា និងផ្តល់កម្មសិទ្ធិទៅឲ្យប្អូនស្រីរបស់គាត់ដែលទើបតែរៀបការកាលពីពីរ

[43] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៧៩៣ កថាខណ្ឌ១។
[44] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, *នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ*, ៣៧២។

ឆ្នាំមុន។ បញ្ជាក់៖ កាលពី៥ឆ្នាំមុន លោក ស័ក បានយកឃ្លាំងនោះដាក់ធានាកាតព្វកិច្ចដើម្បីខ្ចីប្រាក់ ៧០០០$ ដោយកំណត់សងរយៈពេល៥ឆ្នាំ។ នេះបញ្ជាក់ថា ប្អូនស្រីរបស់គាត់បានទទួលយកកាតព្វកិច្ចដែលជាប់មកជាមួយនឹងប្រទានកម្មពីបងប្រុសរបស់គាត់ ដោយត្រូវបង់សងសម្រាប់មួយឆ្នាំចុងក្រោយទើបគ្រប់៥ឆ្នាំ។ ***ឧទាហរណ៍ទី២(អំពីអច្ច័យទាន)៖*** ក្នុងវ័យចាស់ជរាណាស់ទៅហើយ លោក កុសល បានសម្រេចចិត្តផ្តល់ជំនួយមួយចំនួន ដោយធ្វើបណ្តាំប្រគល់ប្រាក់១០០០$ដល់មិត្តរបស់គាត់ដើម្បីជាដើមទុនបន្ថែមក្នុងការរកស៊ី។ គួរបញ្ជាក់ថា លោក កុសល ជំពាក់បំណុលគេ ២០០$។ ដូច្នេះ ក្រោយពេលដែលលោក កុសល ស្លាប់ មិត្តរបស់គាត់មានសិទ្ធិទទួលយកប្រាក់ ១០០០$ និងចូលរួមទទួលខុសត្រូវលើកាតព្វកិច្ចសង២០០$ផងដែរ ដែលនេះបញ្ជាក់ថាជាបំណុលដោយឡែករបស់គាត់។ ***ឧទាហរណ៍ទី៣(អំពីសន្តតិកម្ម)៖*** លោកផាន និងអ្នកស្រីផល ជាប្តីប្រពន្ធនឹងគ្នា។ ថ្ងៃមួយម្តាយរបស់អ្នកស្រីផលបានទទួលមរណៈភាព ហើយអ្នកស្រីផលក៏បានទទួលមត៌កមួយចំនួន ព្រមទាំងបំណុលដែលម្តាយជំពាក់គេចំនួន១០០០$ ដែលបំណុលនេះត្រូវបានចាត់ទុកថាជាបំណុលដោយឡែករបស់អ្នកស្រី ផល ព្រោះអ្នកស្រីព្រមទទួលមត៌ក ដូច្នេះអ្នកស្រីក៏ត្រូវទទួលយក និងចូលរួមអនុវត្តន៍កាតព្វកិច្ចលើបំណុលនោះដែរ។

ម្យ៉ាងវិញទៀត កាតព្វកិច្ចខ្លះកើតឡើងពីការទទួលខុសត្រូវរបស់សហព័ទ្ធម្ខាងក្នុងនាមជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន។[45] នៅក្នុងស្ថានភាពប្រចាំថ្ងៃ បញ្ហាអាចនឹងកើតមានឡើងគ្រប់ពេលវេលា ហើយទំនាក់ទំនងរវាងសាច់ញាតិក៏ជាទំនាក់ទំនងពិសេសមួយដែរដែលភាគីនីមួយៗគួរមានទំនួលខុសត្រូវលើគ្នាទៅវិញទៅមក។ ហេតុនេះ ទើបបញ្ហាដែលបានចោទឡើងខាងលើចង់បង្ហាញពីការតំណាងតាមផ្លូវច្បាប់សម្រាប់អនីតិជនដែលបានបង្កើតអំពើអនីត្យានុកូល ឬសកម្មភាពនានា។ ឧទាហរណ៍៖ បុរសជាប្តីត្រូវបានតុលាការជ្រើសតាំងឲ្យធ្វើជាអ្នកអាណាព្យាបាលសម្រាប់ក្មួយស្រីរបស់គាត់ដែលមានអាយុ១៥ឆ្នាំ ដោយគាត់ត្រូវទទួលខុសត្រូវសងការខូចខាតដែលបានកើតឡើងចំនួន ៣០០$ ដែលក្មួយស្រីរបស់គាត់បង្ករគ្រោះថ្នាក់ចរាចរណ៍។

ក្រៅពីបំណុលផ្ទាល់ខ្លួន សហព័ទ្ធនៅមានបំណុលដទៃទៀតដែលជាបំណុលរួម។ នេះ គឺជាបំណុលដែលកើតឡើងនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ហើយដែលយកមកបម្រើផលប្រយោជន៍រួម ដោយសហព័ទ្ធទាំងពីរព្រមព្រៀងទាំងអស់គ្នាចំពោះការបង្កើតកាតព្វកិច្ច ឬសហព័ទ្ធម្ខាងព្រមព្រៀងជាមួយម្ចាស់បំណុល ដោយមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតដោយមានលិខិតជាលាយលក្ខណ៍អក្សរ។ កាតព្វកិច្ច ឬបំណុលទាំងនោះ អាចមានដូចជា៖

- កាតព្វកិច្ចដែលសហព័ទ្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព។ ក្នុងន័យនេះ ម្ចាស់បំណុលអាចទាមទារឲ្យកូនបំណុលណាម្នាក់អនុវត្តកាតព្វកិច្ចទាំងអស់ ឬ មួយភាគ

[45] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, *នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ*, ៣៧០។

ឬ ឲ្យកូនបំណុលទាំងអស់អនុវត្តទាំងអស់ ឬ មួយភាគដោយព្រមគ្នា ឬ ដោយបន្តបន្ទាប់។[46] នៅក្នុងករណីខ្លះទៀត ប្រសិនបើសហព័ទ្ធណាមួយមិនមានលទ្ធភាពអនុវត្តកាតព្វកិច្ចបានទេ សហព័ទ្ធម្ខាងទៀតអាចចូលរួមទទួលខុសត្រូវបាន។ **<u>ឧទាហរណ៍៖</u>** បុរសជាប្ដីបានទិញអង្ករប្រាំបាវ ប៉ុន្តែមានលុយតែបីបាវដោយត្រូវជំពាក់ថ្លៃអង្ករពីរបាវសិន ដូច្នេះ ប្រពន្ធត្រូវចូលរួមសងថ្លៃអង្ករចំនួនពីរបាវបន្ថែមទៀត។

១ កាតព្វកិច្ចអាចជាសោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្ដីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូនជាអាទិ៍។[47] **<u>ឧទាហរណ៍៖</u>**ប្រាក់ដែលត្រូវបង់ជូនមន្ទីពេទ្យសម្រាប់ថ្លៃព្យាបាលកូនដែលមានជំងឺគ្រុនឈាម។ ក្រៅពីសោហ៊ុយខាងលើ គឺមានសោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម ដូចជាការជួសជុលផ្ទះជាដើម។ ផ្ទុយទៅវិញ ចំណុច ក នៃមាត្រា៩៧៥ នៃក្រមរដ្ឋប្បវេណីកម្ពុជា បានបញ្ជាក់ពីកាតព្វកិច្ចដែលប្ដី ឬប្រពន្ធទាំងពីរនាក់មាន ដោយមិនគិតពីស្ថានភាពផ្សេងៗរបស់ភាគីម្ខាងណាមួយឡើយ ដោយសហព័ទ្ធត្រូវតែមានបន្ទុកស្មើគ្នាលើកាតព្វកិច្ចនោះ។ បានន័យថា ទោះជាសហព័ទ្ធម្ខាងណាមានទ្រព្យសម្បត្តិតិចជាងក៏ដោយ ក៏ត្រូវទទួលខុសត្រូវលើកាតព្វកិច្ចដោយស្មើគ្នានឹងសហព័ទ្ធម្ខាងទៀតដែរ។

## ផ្នែកទី៣៖ ករណីសហព័ទ្ធអសមត្ថភាព ឬអវត្តមាន

### ៣.១. ករណីសហព័ទ្ធអសមត្ថភាព

តាមច្បាប់ ទោះបីជាសហព័ទ្ធម្ខាងមិនទាន់ក្លាយជានីតិជនពេញសិទ្ធិក៏ដោយ ក៏សហព័ទ្ធនោះក្លាយជានីតិជនដោយការរៀបអាពាហ៍ពិពាហ៍ដែរ ដែលគេហៅថា អត្តាធិនភាព។ ដូច្នេះ បញ្ហាដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិក្នុងករណីដែលសហព័ទ្ធជាអនីតិជន គឺមិនចោតឡើងនោះទេ។ ប៉ុន្តែអ្វីដែលគួតែធ្វើការពិចារណានោះគឺ ស្ថានភាពដែលបុគ្គលជាជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភ។

#### ៣.១.១. សហព័ទ្ធជាជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ ជាជនដែលស្ថិតក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។ ដូចគ្នានេះដែរ វាស្ថិតក្នុងករណីដែលប្ដី ឬប្រពន្ធស្ថិតក្នុងស្ថានភាពខាងលើដែលមិនអាចធ្វើការសម្រេចចិត្ត និងពិចារណាតាមផ្លូវច្បាប់បាន។ ហេតុនេះ ត្រូវតម្រូវឱ្យមាន

[46] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៦១។
[47] រុន ពណ្ណរិទ្ធ និងចាំង ស៊ីណាត, *នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ*, ៣៦៦។

អ្នកតំណាងតាមផ្លូវច្បាប់។[48] ជាធម្មតា កាលណាដែលសហព័ទ្ធណាម្ខាងបានធ្លាក់ខ្លួនជាជនដែលមានវិបល្លាសស្មារតី(ឆ្កួត) នោះអ្វីដែលនឹងត្រូវពិចារណាមុនគេគឺការគ្រប់គ្រងទ្រព្យសម្បត្តិរបស់គាត់ពីព្រោះគាត់មិនអាចគ្រប់គ្រងបានទៀតដោយឯកឯងនោះទេ។ ដូច្នេះ វាបង្ហាញថា កាលណាមានមនុស្សដែលស្ថិតក្នុងស្ថានភាពខាងលើ គឺតុលាការចាប់ផ្តើមប្រកាសអាណាព្យាបាលទូទៅតាមពាក្យសុំពីបុគ្គលដែលពាក់ព័ន្ធដោយតុលាការជាអ្នកជ្រើសតាំង ព្រោះមានការចាំបាច់ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរបស់សាមីខ្លួន។[49] មួយវិញទៀត អ្នកដែលមានសិទ្ធិ និងអាចស្នើសុំទៅតុលាការមានដូចជា សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតក្នុងបួន(៤)ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។[50] ដូចគ្នានេះដែរ តុលាការត្រូវគិតពិចារណាថាតើបុគ្គលណាដែលគួរធ្វើជាអាណាព្យាបាលទូទៅ។ អ្វីដែលសំខាន់នៅត្រង់នេះ បើសង្កេតទៅលើស្ថានភាពជាក់ស្តែង គឺមានតែសហព័ទ្ធម្ខាងទៀតប៉ុណ្ណោះដែលនៅជិតស្និត និងមានទំនាក់ទំនងស្និតស្នាលជាមួយនឹងសហព័ទ្ធដែលមានវិបល្លាសស្មារតីនោះជាងគេបើធៀបនឹងសាច់ញាតិ ឬបុគ្គលពាក់ព័ន្ធដទៃទៀត ដូច្នេះ តុលាការនឹងផ្តល់សិទ្ធិទៅសហព័ទ្ធជាអាណាព្យាបាលទូទៅតែម្តងដើម្បីងាយស្រួលគ្រប់គ្រងទ្រព្យរួម និងទ្រព្យដោយឡែក ។ ផ្ទុយទៅវិញ ប្រសិនបើអ្នកដទៃមើលឃើញថា ប្តីប្រពន្ធរស់នៅមិនសូវចុះសម្រុងគ្នា មានរឿងរកាំរកូសជារឿយៗ ហើយសហព័ទ្ធណាម្ខាងរៀបចំទុកដាក់ និងប្រើប្រាស់ទ្រព្យមិនសូវបានល្អ នោះតុលាការនឹងធ្វើការពិចារណាបន្ថែមទៀតអំពីអ្នកអាណាព្យាបាលដែលសមរម្យបំផុត។

តុលាការអាចនឹងផ្តល់សិទ្ធិទៅសហព័ទ្ធម្ខាងទៀតសម្រាប់គ្រប់គ្រងទ្រព្យរួម និងទ្រព្យដោយឡែក មិនមែនបានន័យថា សហព័ទ្ធនោះមានឈ្មោះជាម្ចាស់កម្មសិទ្ធិលើទ្រព្យរួម និងដោយឡែកនោះដែលអាចគ្រប់គ្រង និងចាត់ចែងតាមតែចិត្តនោះទេ។ ម្យ៉ាងវិញទៀត នេះជាការគ្រប់គ្រង និងចាត់ចែងដែលមានលក្ខណៈជាបណ្តោះអាសន្នតែប៉ុណ្ណោះ (សម្រាប់អំឡុងពេលដែលសហព័ទ្ធនៅមានជីវិត) ព្រោះទ្រព្យរបស់គាត់មិនអាចទុកចោលដោយមិនមានអ្នកថែរក្សានោះទេ។ ដូចគ្នានឹងកថាខណ្ឌ១ និង២ នៃមាត្រា៩៧៤ដែរ ការគ្រប់គ្រង និងចាត់ចែងនោះទៀតសោត ត្រូវមានលក្ខណៈស្របនឹងច្បាប់ និងស្របតាមទំហំនៃតម្រូវការក៏ដូចជាជីវភាពប្រចាំថ្ងៃ។ **<u>ឧទាហរណ៍៖</u>** អ្នកស្រី ភី បានយកប្រាក់របស់ស្វាមីចំនួន១០០០$ ដើម្បីបើករបររកស៊ីលក់ចាប់ហ៊ួយចិញ្ចឹមជីវិត និងកូនៗ។ ប្រសិនបើស្ថិតក្នុងស្ថានភាពមួយ ដែលមិនអាចជៀសវាងបានសម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ ប្តី ឬប្រពន្ធម្ខាងទៀតអាចលក់ ឬធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួមបាន

[48] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា២៤ កថាខណ្ឌ១។
[49] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, មាត្រា៩៦ កថាខណ្ឌ១។
[50] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា២៤ កថាខណ្ឌ១។

ដោយមានការអនុញ្ញាតពីតុលាការ។[51] **ឧទាហរណ៍៖** ដូចជាករណី ការព្យាបាលកូនដែលឈឺ ការជួសជុលផ្នែកខ្លះនៃផ្ទះដែលបែកបាក់ ការជួសជុលយានជំនិះជាដើម។ ក្រៅពីនេះ ក្នុងករណីសហព័ទ្ធដែលស្ថិតក្រោមអាណាព្យាបាលទូទៅបានលក់ ឬចាត់ចែងនូវទ្រព្យសម្បត្តិរួម សហព័ទ្ធម្ខាងទៀតអាចទាមទារឲ្យលុបចោលបានតាមរយៈតុលាការ។ នេះ គឺដោយយល់ឃើញថា សហព័ទ្ធនោះស្ថិតក្នុងស្ថានភាពខុសធម្មតា ដែលការធ្វើសកម្មភាពនានាជាមួយនឹងភាគីម្ខាងទៀតមិនមែនកើតចេញពីឆន្ទៈផ្ទាល់ខ្លួនទេ។ ផ្ទុយទៅវិញ ប្រសិនបើសកម្មភាពនោះជាសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ នោះនឹងមិនត្រូវបានលុបចោលទេ។ ឧទាហរណ៍៖ ករណីដែលសហព័ទ្ធយកប្រាក់ទៅទិញម្ហូបអាហារ ព្យាបាលជំងឺជាដើម។

### ៣.១.២. សហព័ទ្ធជាជនស្ថិតក្រោមហិតូបត្ថម្ភ

ជននៅក្រោមហិតូបត្ថម្ភ ជាជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី[52] ពោលគឺជាជនដែលនៅមានសមត្ថភាពតិចតួចក្នុងការគិតពិចារណាសម្រេចលើអ្វីមួយ បើធៀបនឹងជននៅក្រោមអាណាព្យាបាលទូទៅដែលគ្មានសមត្ថភាពតែម្តង។ មិនខុសពីចំណុចខាងលើនោះទេ ប៉ុន្តែនៅទីនេះ សម្តៅទៅលើសហព័ទ្ធដែលស្ថិតក្នុងស្ថានភាពក្លាយជាជនដែលមានបញ្ញាខ្សោយអាចយល់ដឹងបានតិចតួចអំពីបញ្ហាផ្លូវច្បាប់។ បុគ្គលប្រភេទនេះ គឺមានស្មារតីមិនប្រក្រតី មិនជាក់លាក់ ដែលពេលខ្លះអាចយល់ដឹងបាន ហើយពេលខ្លះទៀតមិនអាចយល់ដឹងបានទេ ពោលគឺម្តងឆ្កួត ម្តងជា។ ដោយមើលឃើញស្ថានភាពដែលមិនទៀងទាត់បែបនេះ គួបផ្សំនឹងបញ្ហាដែលអាចនឹងបង្ករឡើងដោយជននោះ តុលាការត្រូវតែតែងតាំងអ្នកអាណាព្យាបាលសម្រាប់គាត់ដើម្បីធ្វើសកម្មភាពនានា និងការគ្រប់គ្រងទ្រព្យសម្បត្តិជាដើម ទោះបីជននៅក្រោមហិតូបត្ថម្ភនោះនៅតែអាចមានការយល់ដឹងតិចតួចក៏ដោយ ព្រោះការធ្វើបែបនេះ គឺដើម្បីបញ្ចៀសនូវការភ័ន្តច្រឡំណាមួយ។ ដូចគ្នានេះដែរ សហព័ទ្ធដែលស្ថិតក្រោមហិតូបត្ថម្ភអាចធ្វើសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃបាន ប៉ុន្តែមិនអាចធ្វើសកម្មភាពទាំងឡាយដូចដែលមានចែងនៅក្នុងមាត្រា ៣០(សិទ្ធិលុបចោលសកម្មភាព)បានទេ លុះត្រាតែមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតទើបមានសុពលភាព ហើយប្រសិនបើធ្វើ វានឹងត្រូវបានគេលុបចោលដដែលព្រោះដោយសារហេតុផលតាមអង្គហេតុនីមួយៗ។ នេះបានន័យថា សហព័ទ្ធដែលស្ថិតក្រោមហិតូបត្ថម្ភនៅតែមានលទ្ធភាពក្នុងការធ្វើកិច្ចសន្យាណាមួយដោយមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ដោយសារតែគេយល់ថាបុគ្គលនោះអាចគិតពិចារណាបានខ្លះៗដែរ។

[51] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៧៦ កថាខណ្ឌ២។
[52] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា២៨ កថាខណ្ឌ១។

ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិ ក៏មិនខុសពីជននៅក្រោមអាណាព្យាបាលទូទៅប៉ុន្មានដែរ ដោយទ្រព្យសម្បត្តិរួម និងដោយឡែកត្រូវបានគ្រប់គ្រងជាបណ្តោះអាសន្នដោយសហព័ទ្ធម្ខាងទៀត ក្នុងរូបភាពជាការការពារផលប្រយោជន៍បុគ្គល។ សហព័ទ្ធម្ខាងទៀត គ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួនដោយមិនឲ្យមានផលប៉ះពាល់ដល់ភាគីម្ខាងទៀតឡើយ ពោលគឺប្រើប្រាស់របស់ខ្លួនឯងឲ្យបានត្រឹមត្រូវ។ ក្រៅពីនេះ ការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យរួម គឺត្រូវមានលក្ខណៈសមស្របដូចបានរៀបរាប់នៅក្នុងចំណុចដែលនិយាយអំពីជននៅក្រោមអាណាព្យាបាលទូទៅ។ រីឯករណីដែលសហព័ទ្ធប្រើប្រាស់ទ្រព្យដោយឡែករបស់សហព័ទ្ធដែលស្ថិតក្រោមហិតូបត្ថម្ភបាន លុះត្រាតែវាជាការចាំបាច់សម្រាប់ជីវភាពគ្រួសារ ឬហេតុផលផ្សេងទៀត។ ជារួម ហិតូបត្ថម្ភកៈ(ប្តី ឬប្រពន្ធ) មានសិទ្ធិអំណាចក្នុងការយល់ព្រមឲ្យសហព័ទ្ធម្ខាងទៀតធ្វើសកម្មភាព និងត្រូវគោរពឆន្ទៈរបស់សហព័ទ្ធនោះ ហើយត្រូវគិតពិចារណាដល់ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត និងស្ថានភាពជីវភាពរបស់ជននោះ។[53] នេះជាការគោរពសិទ្ធិមួយយ៉ាងត្រឹមត្រូវចំពោះសហព័ទ្ធដែលកំពុងធ្លាក់ក្នុងស្ថានភាពគ្រោះថ្នាក់។

### ៣.២. ករណីសហព័ទ្ធអវត្តមាន

ករណីនេះ គឺផ្តោតសំខាន់ទៅលើការដែលសហព័ទ្ធណាម្ខាងបានអវត្តមាន បានចេញពីលំនៅឋាន ឬទីសំណាក់ ហើយដែលគ្មានលទ្ធភាពនឹងត្រឡប់មកវិញដោយងាយស្រួល និងមិនបានចូលរួមលើការគ្រប់គ្រង ឬចាត់ចែងទ្រព្យដែលសហព័ទ្ធម្ខាងទៀតបានធ្វើ។[54] ផ្ទុយទៅវិញ ប្រសិនបើសហព័ទ្ធដែលអវត្តមាននោះបានចាត់តាំងអ្នកគ្រប់គ្រងច្បាស់លាស់សម្រាប់ទ្រព្យសម្បត្តិរបស់ខ្លួន សហព័ទ្ធម្ខាងទៀតមិនអាចស្នើសុំទៅតុលាការប្រកាសអ្នកគ្រប់គ្រង ហើយតុលាការក៏មិនអាចជ្រៀតជ្រែកក្នុងបញ្ហានេះបានដែរ ទោះបីជាតុលាការបានប្រកាសចាត់តាំងហើយក៏ដោយ ក៏វាអាចនឹងត្រូវបានស្នើសុំឲ្យលុបចោលវិញបានដែរ។[55] ផ្ទុយទៅវិញ ធ្លាប់មានបញ្ហាខ្លះបានកើតឡើងដោយសារអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលតែងតាំងដោយសហព័ទ្ធអវត្តមាននោះ ដូចជាការចាត់ចែងទ្រព្យសម្បត្តិដោយមានផលប៉ះពាល់ដល់សិទ្ធិសហព័ទ្ធម្ខាងទៀត និងបញ្ហាដូចដែលមានចែងក្នុងមាត្រា៣៩(ការផ្លាស់ប្តូរអ្នកគ្រប់គ្រង) ដែលពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននោះនៅរស់ ឬ ទទួលមរណៈភាព តុលាការអាចផ្លាស់ប្តូរអ្នកគ្រប់គ្រងបានតាមពាក្យសុំពីបុគ្គលដែលពាក់ព័ន្ធ។

ក្រៅពីនេះ អំឡុងពេលដែលសហព័ទ្ធនោះបានអវត្តមាន មិនត្រូវលើសពីរយៈពេល៥(ប្រាំ)ឆ្នាំ ដូចដែលមានចែងក្នុងមាត្រា៤១(ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន) ឡើយ។ នេះជា

[53] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា១១៣៩ កថាខណ្ឌ១ និង២។
[54] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៣៧ វាក្យខណ្ឌ១។
[55] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៣៨។

ការបែងចែកដាច់ដោយឡែកពីគ្នា រវាងអវត្តមាន និងការបាត់ខ្លួន ដោយអវត្តមាន ជាកាលៈទេសៈដែលបុគ្គលណាមួយមិនបានបង្ហាញខ្លួនក្នុងមួយរយៈពេលខ្លីដែលមិនលើសពីប្រាំ (៥) ឆ្នាំស្របទៅតាមបញ្ញត្តិច្បាប់កំណត់។ ផ្ទុយទៅវិញ ការបាត់ខ្លួន ជាកាលៈទេសៈមួយដែលបុគ្គលណាមួយមិនបានបង្ហាញខ្លួនអស់រយៈពេលយូរដែលលើសពីប្រាំ(៥)ឆ្នាំ ហើយមិនបានផ្តល់ដំណឹង ឬព័ត៌មានជាក់លាក់ដល់បុគ្គលពាក់ព័ន្ធ។

ចំពោះសិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិវិញ អ្នកនោះមានសិទ្ធិធ្វើសកម្មភាពតាមការកំណត់ក្នុងកថាខណ្ឌទី២ មាត្រា៣៦៦ (ទំហំនៃសិទ្ធិតំណាង) បានន័យថា ប្តី ឬប្រពន្ធដែលតំណាងសហព័ទ្ធដែលអវត្តមានអាចមានចែងនៅក្នុងកិច្ចសន្យាតំណាង ឬតាមបញ្ញត្តិច្បាប់។ ដូចគ្នានេះដែរក្នុងករណីដែលកិច្ចសន្យាមិនបានកំណត់សិទ្ធិតំណាង នោះសហព័ទ្ធអាចត្រឹមតែកែលម្អ និងថែរក្សាតែប៉ុណ្ណោះ ដោយមិនធ្វើឲ្យមានការផ្លាស់ប្តូរលក្ខណៈនៃទ្រព្យនោះឡើយ។ ម្យ៉ាងវិញទៀតប្រសិនបើពុំមានដំណឹងជាក់លាក់ថា សហព័ទ្ធម្ខាងទៀតនៅរស់ ឬទទួលមរណភាព តុលាការអាចអនុញ្ញាតឲ្យសហព័ទ្ធធ្វើអំពើចាំបាច់នានាបាន។ ឧទាហរណ៍៖ ប្រពន្ធលក់ខ្សែកមាសរបស់ប្តីដើម្បីបង្គ្រប់លុយព្យាបាលកូនប្រុសដែលត្រូវវះកាត់ព្យាបាលជំងឺ។

# ជំពូកទី៣៖ ការបែងចែកទ្រព្យ

ការបែងចែកទ្រព្យនៅត្រង់នេះ គឺសម្តៅទៅលើការដែលសហព័ទ្ធទាំងសងខាងធ្វើការបែងចែកទ្រព្យរួម និងទ្រព្យដោយឡែកនៅពេលអ្នកទាំងពីរផ្តាច់ចំណងអាពាហ៍ពិពាហ៍ ឬលែងលះ ការដែលសហព័ទ្ធណាម្ខាងបានទទួលមរណភាព ឬស្ថិតក្នុងស្ថានភាពដែលសហព័ទ្ធណាម្ខាងបានបាត់ខ្លួន។ វាមិនមានបញ្ហាអ្វីដែលត្រូវចោទឡើងនោះទេ ក្នុងករណីដែលសហព័ទ្ធទាំងសងខាងពិភាក្សាគ្នាបែងចែកទ្រព្យដោយឡែករៀងៗខ្លួន ពោលគឺភាគីទទួលយកទ្រព្យសម្បត្តិដោយឡែករៀងៗខ្លួន។ ក៏ប៉ុន្តែ បញ្ហាដែលត្រូវចោទឡើងនោះគឺ ការពិភាក្សាលើការបែងចែកទ្រព្យរួម។ គេសង្កេតឃើញថា តាំងពីប៉ុន្មានឆ្នាំមុនរហូតមកដល់ពេលបច្ចុប្បន្ននេះ ការពិភាក្សាបែកចែកទ្រព្យរួម គឺនៅតែជាបញ្ហាសំខាន់ ព្រោះការដោះស្រាយវិវាទនៅមិនទាន់មានភាពល្អប្រសើរនៅឡើយ ដោយសារតែប្រព័ន្ធទ្រព្យសម្បត្តិនៅមានភាពស្មុគស្មាញ ដែលធ្វើឲ្យមានលក្ខណៈពិបាកក្នុងការបែងចែកឲ្យដាច់ស្រាច់។ ទោះជាយ៉ាងណាក៏ដោយ ដំណោះស្រាយវិវាទលើការបែងចែកទ្រព្យប្តីប្រពន្ធ មានភាពល្អប្រសើរច្រើនដោយសារតែច្បាប់បានបញ្ញត្តិអំពីដំណោះស្រាយយ៉ាងច្បាស់លាស់ រួមជាមួយនឹងការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាពីសំណាក់ចៅក្រម ឬអ្នកប្រឹក្សាផ្នែកច្បាប់ និងការសម្របសម្រួលរវាងគូភាគី។

## ផ្នែកទី១៖ សន្តតិកម្ម

នៅពេលដែលសន្តតិជនទទួលមរណៈភាព នោះសន្តតិកម្មត្រូវបានចាប់ផ្តើម។[56] ជាទូទៅសន្តតិកម្មត្រូវតែបង្កើតឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬដោយតាមឆន្ទៈរបស់មតកជនដែលមានបណ្តាំជាដើម។ ប្រសិនបើក្នុងករណីដែលមានបណ្តាំមតិកច្បាស់លាស់ នោះការបែងចែកទ្រព្យ ត្រូវតែធ្វើតាមអ្វីដែលមានចែងនៅក្នុងបណ្តាំនោះ។ ប៉ុន្តែប្រសិនបើមតកជនមិនបានទុកបណ្តាំក្រោយពេលទទួលមរណភាពទេ ការបែងចែងទ្រព្យសម្រាប់សន្តតិកម្មអាចនឹងមានផលវិបាក។

កាលណាសន្តតិជនទទួលបន្តនូវទ្រព្យសម្បត្តិពីមតកជនតាមសន្តតិកម្ម នោះតាមបញ្ញត្តិនៃច្បាប់កំណត់ថា សន្តតិជនត្រូវតែទទួលបន្តនូវសិទ្ធិ និងករណីកិច្ចទាំងអស់ដែលជាប់ពាក់ព័ន្ធនឹងទ្រព្យសម្បត្តិនោះ លើកលែងតែសិទ្ធិផ្តាច់មុខរបស់មតកជនដែលមានលើទ្រព្យ។[57] បានសេចក្តីថាសន្តតិជនទទួលបានទ្រព្យតាមសន្តតិកម្ម ហើយក៏ត្រូវទទួលខុសត្រូវទៅលើករណីកិច្ចដែលមតកជនមានលើអ្វីមួយដូចជា បំណុលជាដើម។ ប៉ុន្តែក្នុងករណីដែលសន្តតិជនមិនចង់ទទួលខុសត្រូវលើករណីកិច្ចបំណុលនោះទេ សន្តតិជនមិនមានសិទ្ធិទទួលបានទ្រព្យសម្បត្តិពីមតកជននោះដែរ។ នេះគឺជារឿងសមហេតុផលមួយដែលសន្តតិជនត្រូវទទួលយកទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម។ កាលណាសហព័ទ្ធត្រូវបានសន្មតថាជាសន្តតិជនហើយ នោះចំណែកមតិកនឹងត្រូវបានបែងចែកទៅតាម

[56] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា១១៩៥។
[57] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា១១៩៧។

ករណីដែលមានតែសហាព័ទ្ធជាសន្តតិជន(១.១) មានតែសហាព័ទ្ធ និងបច្ឆាញាតិផ្ទាល់ជាសន្តតិជន(១.២) មានតែសហព័ទ្ធ និងឪពុកម្តាយរបស់មតកជនជាសន្តតិជន(១.៣) និងមានតែសហព័ទ្ធ និងបងប្អូនបង្កើត ឬបុព្វជនក្រៅពីឪពុកម្តាយជាសន្តតិជន(១.៤)។

### ១.១. ករណីសហព័ទ្ធជាសន្តតិជន

ក្នុងករណីដែលមានតែសហាព័ទ្ធជាសន្តតិជន ហើយមិនមានបុព្វញាតិ និងបច្ឆាញាតិ មិនមានបុគ្គលដូចដែលបានកំណត់ក្នុងមាត្រា១១៥៧(សន្តតិកម្មជំនួស) និងបងប្អូនបង្កើតនោះទេ សហាព័ទ្ធរបស់មតកជននោះនឹងទទួលបានទ្រព្យសម្បត្តិទាំងអស់ (ទទួលបាន១០០%)។




### ១.២. ករណីសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់ជាសន្តតិជន

ក្នុងករណីដែលមានតែសហាព័ទ្ធ និងបច្ឆាញាតិផ្ទាល់របស់សន្តតិជន នោះពួកគេនឹងទទួលបានចំណែកមតិកស្មើៗគ្នា។[58] បច្ឆាញាតិផ្ទាល់នៅត្រង់នេះ គឺសម្តៅទៅលើកូនបង្កើតរបស់មតកជនដែលនៅរស់។ ក្នុងន័យនេះដែរ កូនគឺអាចជាកូនបង្កើត ឬកូនសុំ ដែលពួកគេសុទ្ធតែមានសិទ្ធិស្មើៗនឹងសហាព័ទ្ធក្នុងការទទួលបានទ្រព្យសម្បត្តិពីមតកជន។

**<u>ឧទាហរណ៍៖</u>** សម្បត្តិ មានភរិយា កូនបង្កើតពីរនាក់ និង កូនសុំម្នាក់ ប៉ុន្តែកូនបង្កើតរបស់គាត់ម្នាក់បានស្លាប់កាលពីបីឆ្នាំមុន។ ស្ថានភាពគ្រួសាររបស់គាត់មានដូចខាងក្រោម៖




[58] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា១១៦២ កថាខណ្ឌ១។

យោងទៅតាមស្ថានភាពខាងលើនេះ ដោយសារតែកូនបង្កើតម្នាក់របស់មតកជនបានស្លាប់ នោះសន្តតិជនដែលត្រូវយកមកធ្វើការវិនិច្ឆ័យគឺមានតែកូនបង្កើតម្នាក់ កូនស្មុំម្នាក់ និងសហព័ទ្ធរបស់មតកជនតែប៉ុណ្ណោះ។ ដូច្នេះ ទាំងកូនបង្កើត កូនស្មុំ និងភរិយា គឺត្រូវទទួលបានចំណែកទ្រព្យសម្បត្តិរបស់លោកសម្បត្តិស្មើៗគ្នា។

ការកំណត់ឲ្យកូនទាំងអស់ និងសហព័ទ្ធមានចំណែកមតិកស្មើៗគ្នានេះ គឺដោយសារតែគិតពិចារណាទៅដល់ការចំណាយសម្រាប់ការរស់នៅជាអាទិ៍ ក្រោយពេលដែលមតកជនបានទទួលមរណភាព។ ម្យ៉ាងវិញទៀត ក្រមរដ្ឋប្បវេណីជប៉ុនបានបង្ហាញថា សហព័ទ្ធត្រូវទទួលចំណែក ១ភាគ២នៃមតិក ដោយមិនគិតអំពីចំនួនកូនរបស់មតកជនទេ នេះគឺដោយសារតែតាមច្បាប់ ទ្រព្យសម្បត្តិដែលសហព័ទ្ធម្ខាងទទួលបានក្នុងនាមខ្លួនផ្ទាល់នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាកម្មសិទ្ធិផ្ទាល់របស់អ្នកនោះ ហេតុនេះហើយទើបពេលទទួលមតិក សហព័ទ្ធត្រូវទទួលបានពាក់កណ្តាល។ រីឯមាត្រា៩៧៣(ទ្រព្យសម្បត្តិរួម) នៃក្រមរដ្ឋប្បវេណីកម្ពុជាវិញ ក៏បានលើកឡើងអំពីទ្រព្យសម្បត្តិដែលប្តីប្រពន្ធរកបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ជាទ្រព្យសម្បត្តិរួម ហេតុនេះហើយ ទោះបីជាសហព័ទ្ធណាមួយបានស្លាប់ក៏ដោយ ក៏ចំណែកទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធដែលនៅរស់នោះមិនត្រូវបានសន្តតិជនផ្សេងទៀតមកទទួលធ្វើសន្តតិកម្មបានឡើយ ដោយសារតែទ្រព្យសម្បត្តិនោះជាទ្រព្យរបស់សហព័ទ្ធដែលនៅរស់។ ដោយសារតែខ្លឹមសារខាងលើនេះហើយ ទោះបីជាការបែងចែកមតិកតាមវិធីខាងលើនេះ ក៏មិនមានអ្វីចោទជាបញ្ហានោះឡើយ បើសិនជាគិតទៅដល់សមភាពរវាងភេទទាំងពីរ ជាអាទិ៍។[59]

## ១.៣. ករណីសន្តតិជនជាសហព័ទ្ធ និងបុព្វញាតិផ្ទាល់

នេះ គឺជាករណីដែលមតកជនមិនមានបច្ឆាញាតិដូចជាកូន ឬសន្តតិជនជំនួស ហើយមានតែសហព័ទ្ធ និងឪពុកម្តាយដែលជាបុព្វញ្ញាត្តិដែលនឹងក្លាយទៅជាសន្តតិជន។ ចំណែកមរតកដែលនឹងត្រូវបែងចែក គឺត្រូវជា ១ ភាគ ៣ សម្រាប់បុគ្គលម្នាក់ៗ បានន័យថា ទាំងឪពុក ម្តាយ និងសហព័ទ្ធត្រូវបាន ១ ភាគ ៣ នៃមតិករបស់សន្តតិជន។[60] ឧទាហរណ៍ថា បូណា មានឪពុកម្តាយ និងសហព័ទ្ធដែលត្រូវក្លាយជាសន្តតិជនចំពោះមតិកសរុប ៣០,០០០ ដុល្លា។ នោះ ចំណែកមតិកដែលអ្នកទាំងបីត្រូវទទួលគឺ ម្នាក់បាន ១០,០០០ ដុល្លា។ ម្យ៉ាងវិញទៀត ប្រសិនបើឪពុកម្តាយណាម្ខាងបានទទួលមរណភាព នោះមតិករបស់មតកជនត្រូវបែងចែកជាពីរស្មើគ្នា។ ដោយទាញចេញពីឧទាហរណ៍ខាងលើ ប្រសិនបើម្តាយរបស់លោកបូណាបានស្លាប់ នោះឪពុក និងប្រពន្ធរបស់គាត់នឹងទទួលបានទ្រព្យសម្បត្តិម្នាក់ ១៥,០០០ ដុល្លា។

[59] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, មាត្រា១១៦២ កថាខណ្ឌ២។

[60] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា១១៦២ កថា. ២។

បើក្រឡេកទៅមើល និងវិភាគបន្ថែមទៀតទៅលើឪពុកម្តាយ អាចមានករណីដែលមតកជនជាកូនសុំ។ ប្រសិនបើមតកជនជាកូនសុំពេញលេញ នោះមិនមានអ្វីចោទជាបញ្ហានោះទេ គឺត្រូវគិតពិចារណាទៅតាមករណីដូចខាងលើដដែល។ ប៉ុន្តែចំណុចដែលត្រូវយកមកពិចារណានោះ មតកជន គឺជាកូនសុំធម្មតា ដែលមានន័យថាមិនទាន់ផ្តាច់ចំណងគតិយុត្តពីឪពុកម្តាយមុននោះឡើយ។ ក្នុងករណីនេះ ទោះបីមតកជនមានឪពុកម្តាយច្រើននាក់ក៏ដោយ ក៏សហាព័ទ្ធគួរតែទទួលបាន ១ ភាគ ៣ ដែរ។[61] ប្រសិនបើបែងចែកមតិកនោះជាប្រាំចំណែក វាហាក់ដូចជាមិនសូវសមរម្យទាល់តែសោះចំពោះសហាព័ទ្ធដែលគេចាត់ទុកថាជាសន្តតិជនជានិច្ច។ មានសំណួរបានលើកឡើងថា ហេតុអ្វីបានជាឪពុកម្តាយទាំងសងខាងមានសិទ្ធិទទួលបានទ្រព្យសម្បត្តិតែ ២ ភាគ ៣? ចម្លើយអាចនឹងត្រូវបានបកស្រាយថា ទោះបីអ្នកទាំងនោះជាឪពុកម្តាយបង្កើត និងចិញ្ចឹមក៏ដោយ ពួកគេគួរតែទទួលបានចំណែក ២ ភាគ ៣ ជាការគ្រប់គ្រាន់ ហើយមើលទៅវាក៏សមហេតុផលម្យ៉ាងដែរ ដែលសហាព័ទ្ធគួររក្សាចំណែករបស់ខ្លួនដដែល។

### ១.៤. ករណីសន្តតិជនជាសហាព័ទ្ធ បុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយ ឬបងប្អូនបង្កើត ឬអ្នកទទួលសន្តតិកម្មជំនួស

ប្រសិនបើសន្តតិជនដែលត្រូវទទួលមតិកមាន សហាព័ទ្ធ និងបុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយ ឬបងប្អូនបង្កើត ឬអ្នកទទួលសន្តតិកម្មជំនួសបុគ្គល សហាព័ទ្ធមានសិទ្ធិទទួលបានចំណែកពាក់កណ្តាលនៃទ្រព្យរបស់មតកជន រីឯបុគ្គលដទៃទៀតត្រូវទទួលបានចំណែកដែលនៅសល់ពាក់កណ្តាលទៀត។[62] បានន័យថា ចំណែកមតិកពាក់កណ្តាលនៃទ្រព្យរបស់មតកជនត្រូវយកទៅបែងចែកឲ្យបុគ្គលផ្សេងទៀតក្រៅពីសហាព័ទ្ធ។

ករណីដែលសន្តតិជនមានតែសហាព័ទ្ធ និងបងប្អូនបង្កើត ឬបុគ្គលដែលជំនួសបងប្អូនបង្កើត។ ចំណែកពាក់កណ្តាលត្រូវបែងចែកឲ្យបងប្អូនបង្កើតដែលនៅរស់ បានន័យថា ពួកគេទទួលបាន ១ ភាគ ៤។ ប្រសិនបើបងប្អូនបង្កើតណាម្នាក់បានស្លាប់ នោះចំណែកទ្រព្យរបស់គាត់ត្រូវបែងចែកទៅឲ្យកូនរបស់គាត់ គឺស្មើនឹង ១ ភាគ ៨។




## ផ្នែកទី២៖ ការបាត់ខ្លួន

ការបាត់ខ្លួន គឺជាស្ថានភាពដែលបុគ្គលមិនមានវត្តមានអស់រយៈពេលយូរ ឬលើសពីប្រាំ(៥) ឆ្នាំ ហើយដែលនឹងត្រូវបានប្រកាសថាបានបាត់ខ្លួនតាមពាក្យសុំពីសហាព័ទ្ធ និងបុគ្គលពាក់ព័ន្ធដទៃ

[61] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, មាត្រា១១៦២ កថាខណ្ឌ៣។
[62] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា១១៦២ ចំណុច គ។

ទៀត។[63] ម្យ៉ាងវិញទៀត រយៈពេលនៃការបាត់ខ្លួននោះគិតតែត្រឹម១(មួយ)ឆ្នាំប៉ុណ្ណោះ ប្រសិនបើសហព័ទ្ធចូលទៅតំបន់មានសង្គ្រាម ស្ថិតក្នុងនាវាដែលបានលិច ឬបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងៗដែលមិនបានបង្ហាញខ្លួនក្នុងរយៈពេលដែលបានកំណត់ខាងលើនេះ តុលាការនឹងប្រកាសថាបានបាត់ខ្លួន ឬទទួលមរណភាពតែម្តង។ ដោយសារតែសហព័ទ្ធដែលបានបាត់ខ្លួនក្នុងរយៈពេលយូរត្រូវបានចាត់ទុកថាបានស្លាប់ ហេតុដូច្នេះ ការចាត់ចែងទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលបានបាត់ខ្លួននោះ នឹងត្រូវអនុវត្តន៍ទៅតាមសន្តតិកម្ម ព្រោះវាមានខ្លឹមសារដែលបញ្ជាក់អំពីមរណភាពដូចគ្នា។

ប្រសិនបើថ្ងៃណាមួយ សហព័ទ្ធដែលបានបាត់ខ្លួនបានបង្ហាញខ្លួនមកវិញ សាម៉ីខ្លួន ឬសហព័ទ្ធម្ខាងទៀតអាចស្នើសុំឲ្យលុបចោលការប្រកាសការបាត់ខ្លួនវិញបាន។ ហេតុនេះ រាល់ការចាត់ចែងទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលបានមកវិញ នឹងត្រូវបាត់បង់អានុភាពទៅតាមការលុបចោលការប្រកាសបាត់ខ្លួន ដែលតម្រូវឲ្យបុគ្គលទាំងឡាយដែលបានទទួលផលប្រយោជន៍ប្រគល់វិញនូវផលប្រយោជន៍ទាំងនោះ។[64] ក្នុងចំណុចនេះ អាចនឹងមានសំណួរលើកឡើងថា តើត្រូវប្រគល់ផលប្រយោជន៍ដែលទទួលបានទៅវិញទាំងអស់ដែរឬទេ ប្រសិនបើអ្នកទទួលនោះបានប្រើប្រាស់អស់មួយភាគទៅហើយ? ក្នុងការឆ្លើយតបទៅនឹងបញ្ហាខាងលើ ដោយផ្អែកទៅលើស្មារតីនៃច្បាប់ដែលទាក់ទងទៅនឹងការការពារផលប្រយោជន៍បុគ្គល និងអំពើសុចរិត បុគ្គលដែលបានប្រើប្រាស់ ឬចាត់ចែងទ្រព្យអស់មួយភាគទៅហើយ នឹងសងត្រឡប់មកវិញត្រឹមកម្រិតផលប្រយោជន៍ដែលខ្លួននៅមាន ក្នុងករណីដែលបុគ្គលនោះមិនបានដឹងថា ការប្រកាសការបាត់ខ្លួន គឺផ្ទុយនឹងការពិត។

ក្រៅពីនេះ ដោយសារតែការប្រកាសការបាត់ខ្លួនមានអានុភាព ទើបវាមិនអាចធ្វើឲ្យបញ្ហាខ្លះកែប្រែបាននោះឡើយ។ តួយ៉ាង ដូចក្នុងមាត្រា៩៤ កថាខណ្ឌ៩ បានបញ្ជាក់ថា ប្រសិនបើសហព័ទ្ធដែលនៅលំនៅឋានបានរៀបការថ្មីជាមួយអ្នកផ្សេងបន្ទាប់ពីការបាត់ខ្លួនបានអនុវត្ត នោះទោះជាសហព័ទ្ធម្ខាងទៀតបានត្រឡប់មកវិញក៏ដោយ ក៏មិនអាចលុបចោលអាពាហ៍ពិពាហ៍ថ្មីបានដែរ។ ឧទាហរណ៍៖ បន្ទាប់ពីមានជម្លោះនឹងគ្នាលើការមើលថែកូន លោក សំអាត បានចាកចោលពីផ្ទះអស់រយៈពេលយ៉ាងយូរ។ ដោយសង្កេតឃើញថា ប្តីរបស់ខ្លួនបានបាត់ខ្លួនអស់រយៈពេលជិត ៦ (ប្រាំមួយ) ឆ្នាំទៅហើយ អ្នកស្រី ភី បានស្នើសុំទៅតុលាការប្រកាសពីការបាត់ខ្លួនរបស់ប្តី។ ក្រោយពីធ្វើរួចរាល់ លោក សុខា បានស្នើសុំអ្នកស្រី ភី ធ្វើជាប្រពន្ធ និងបានរៀបការតាមប្រពៃណី។ ថ្ងៃបន្ទាប់ លោក សំអាត បានត្រឡប់មកវិញ ប៉ុន្តែគាត់មិនមានចំណងគតិយុត្តនឹងអ្នកស្រី ភី ទៀតនោះឡើយដោយសារតែអាពាហ៍ពិពាហ៍ថ្មីបានលុបអាពាហ៍ពិពាហ៍ចាស់បាត់ទៅហើយ។ ក៏ប៉ុន្តែប្រសិនបើក្រឡេកទៅមើលស្ថានភាពជាក់ស្តែងខ្លះ វាគួរតែត្រូវបានយកមកពិចារណាឲ្យបានគ្រប់

---

[63] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩១, កថាខណ្ឌ១។

[64] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៤, កថាខណ្ឌ២ វាក្យខណ្ឌ១។

ជ្រុងជ្រោយទើបជាការប្រសើរ ព្រោះករណីខ្លះ វាហាក់ដូចជាមានភាពអយុត្តិធម៌ចំពោះភាគីម្ខាងទៀតដែលសុច្ចរិត និងគ្មានកំហុស។

**<u>ឧទាហរណ៍៖</u>** ប៉ុន្មានថ្ងៃក្រោយនេះ លោក សាន មានបញ្ហាខ្លះៗជាមួយមិត្តរួមការងារ និងថៅកែ។ ដោយមានគំនិតចង់ធ្វើបាបលោក សាន ថៅកែបានបញ្ជូនលោក សាន ទៅធ្វើការនៅសាខាក្រុមហ៊ុនឯក្រៅប្រទេសដោយផ្ដាច់ទំនាក់ទំនងគាត់ជាមួយនឹងប្រពន្ធ និងក្រុមគ្រួសាររហូតដល់ទៅប្រាំឆ្នាំកន្លះ។ ក្រោយមកទៀត ថៅកែនោះបានយល់ព្រមឲ្យលោក សាន ត្រឡប់មកគេហដ្ឋានខ្លួនវិញ។ ជាអកុសល ប្រពន្ធរបស់គាត់បានប្រាប់គាត់ថា បានស្នើសុំប្រកាសការបាត់ខ្លួនរបស់ប្ដី និងបានរៀបការនឹងស្វាមីថ្មីរួចទៅហើយ មិនអាចរស់នៅជាមួយគ្នាបានទៀតទេ ព្រោះលោក សាន បានចាកចោលផ្ទះយូរខ្លាំងពេក។

នៅក្នុងឧទាហរណ៍ខាងលើនេះ លោក សាន បានបាត់ខ្លួនអស់រយៈពេលជាយូរដែលលើសប្រាំឆ្នាំ ហើយវាសមស្របទៅនឹងការប្រកាសអំពីការបាត់ខ្លួនរបស់បុគ្គលណាមួយ។ ម្យ៉ាងវិញទៀតប្រពន្ធរបស់គាត់មានសិទ្ធិក្នុងការជ្រើសរើសស្វាមីថ្មីស្របទៅតាមច្បាប់ ហើយលោក សាន ក៏លែងមានចំណងគតិយុត្តជាមួយនឹងប្រពន្ធទៀតដែរ ដែលគាត់គ្មានសិទ្ធិនៅក្នុងអាពាហ៍ពិពាហ៍ថ្មីនោះទេ។ ទោះជាយ៉ាងណាក៏ដោយ លោក សាន មានសិទ្ធិទាមទារទៅតុលាការដើម្បីឲ្យពិចារណាអំពីរឿងនេះ។ ទោះបីជាបានបាត់ខ្លួនអស់រយៈពេលយូរ មិនបានភ្ជាប់ទំនាក់ទំនងប្រាស្រ័យទាក់ទងជាមួយប្រពន្ធ និងមិនបានបង្ហាញខ្លួនខ្លះក្នុងរយៈពេលនៃការបាត់ខ្លួនក៏ដោយ លោក សាន អាចបញ្ជាក់អំពីហេតុផលជាក់លាក់របស់ខ្លួនថាខ្លួនគ្មានចេតនាក្នុងការរត់ចេញពីផ្ទះនោះទេ ហើយការដែលខ្លួនបាត់ខ្លួន គឺដោយសារតែការចាប់បង្ខំ និងមានគំនាបពីអ្នកដទៃដែលធ្វើឲ្យខ្លួនមិនមានឱកាស និងមានការលំបាកខ្លាំងក្នុងការទាក់ទងមកប្រពន្ធ និងក្រុមគ្រួសារ។ ដោយគិតទៅលើស្មារតីនៃភាពយុត្តិធម៌នៅក្នុងសង្គម អាពាហ៍ពិពាហ៍ថ្មីគួរតែត្រូវបានលុបចោល ហើយអនុញ្ញាតឲ្យលោក សាន រស់នៅជុំគ្នាជាមួយនឹងគ្រួសាររបស់គាត់វិញ។

### ផ្នែកទី៣៖ ការលែងលះ

ការពិភាក្សាអំពីការបែងចែកទ្រព្យរវាងប្ដីប្រពន្ធតាមរយៈការលែងលះ ក៏មានលក្ខណៈដូចគ្នា និងអនុវត្តន៍ដូចគ្នាទៅនឹងការបែងចែកទ្រព្យតាមរយៈការលុបចោលនៃអាពាហ៍ពិពាហ៍។ ប្រសិនបើករណីដែលសហព័ទ្ធទាមទារទៅតុលាការ នោះតុលាការត្រូវធ្វើការសម្រេចសេចក្ដីទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ។[65] ជាគោលការណ៍ ទ្រព្យសម្បត្តិត្រូវបែងចែកតាមការព្រមព្រៀង ប្រសិនបើពុំមានការព្រមព្រៀងទេ "សហព័ទ្ធម្នាក់ៗត្រូវដកយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលមានមុនពេលរៀបការ ឬ ទ្រព្យកេរ្ដិ៍មរតកចេញ" (យី ពិសី ២០១៧) ហើយទ្រព្យសម្បត្តិរួមត្រូវបែងចែកស្មើគ្នារវាង

[65] ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០, មាត្រា២២ កថាខណ្ឌ១។

សហាព័ទ្ធ។[66] ប៉ុន្តែ ករណីខ្លះទៀតដែលទ្រព្យសម្បត្តិមិនត្រូវបានបែងចែកដោយងាយនោះទេ នេះបើយោងតាមការសិក្សាអំពីការលុបចោលអាពាហ៍ពិពាហ៍។ ក្នុងករណីដែលអាពាហ៍ពិពាហ៍នោះនឹងត្រូវបានលុបចោល ហើយដែលសហាព័ទ្ធម្ខាងទៀតមិនបានដឹងអំពីមូលហេតុនៅពេលរៀបការនោះទេ ទ្រព្យសម្បត្តិដែលសហាព័ទ្ធនោះទទួលបាន ត្រូវសងត្រឹមកម្រិតនៃផលប្រយោជន៍ដែលខ្លួនបានទទួល ទៅឲ្យភាគីម្ខាងទៀត។[67] ម្យ៉ាងទៀត បើសហាព័ទ្ធបានដឹងពីមូលហេតុនៃការលុបចោលនោះត្រូវសងផលប្រយោជន៍ទាំងអស់ដែលបានទទួលដោយការរៀបការ។[68] ការលែងលះនាពេលបច្ចុប្បន្ន គឺជាបញ្ហាមួយដែលកើតឡើងជាញឹកញាប់ ហើយវាពេលខ្លះបានបង្កជាការលំបាកដល់ប្តីប្រពន្ធក្នុងការពិភាក្សាគ្នាស្វែងរកដំណោះស្រាយ ក្នុងការបែងចែកទ្រព្យសម្បត្តិក្រោយពេលលែងលះ។

វាជាការល្អមួយ និងមិនមានអ្វីចោទជាបញ្ហានោះឡើយ នៅក្នុងករណីដែលសហាព័ទ្ធទាំងពីរបានព្រមព្រៀងគ្នាពីដំបូងធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់ទ្រព្យរបស់ខ្លួន ក៏ដូចជាការបែងចែកក្រោយពេលលែងលះគ្នា ឬបញ្ហាណាមួយផ្សេង។ នេះបានន័យថា ក្រោយពេលលែងលះ ប្តីប្រពន្ធត្រូវបែងចែកទ្រព្យទៅតាមបញ្ញត្តិដែលមានចែងក្នុងកិច្ចសន្យា លើកលែងមានលក្ខខណ្ឌផ្សេងពីនេះ ឬបែងចែកតាមការយល់ឃើញរបស់តុលាការដែលពិចារណាទៅឃើញថា សមរម្យ និងសមហេតុផលដោយផ្អែកលើជីវភាពរបស់សហាព័ទ្ធនីមួយៗ។ លើសពីនេះ ភាគីដែលគ្មានកំហុស ហើយខ្វះខាត អាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន ហើយភាគីម្ខាងទៀតត្រូវតែជួយទៅតាមលទ្ធភាពរបស់ខ្លួន។[69] **<u>ឧទាហរណ៍ទី១៖</u>** ក្នុងករណីដែលសហាព័ទ្ធបានធ្វើកិច្ចសន្យាទ្រព្យប្តីប្រពន្ធ។ ក្រោយពេលលែងលះ ការបែងចែកទ្រព្យត្រូវបានធ្វើតាមកិច្ចសន្យានោះ ប៉ុន្តែដោយយល់ឃើញថា ភាគីខាងប្រពន្ធទទួលបានចំណែកតិចតួចដែលមានការលំបាកក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារទៅថ្ងៃមុខ រួមទាំងមានបន្ទុកក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន តុលាការអាចនឹងធ្វើការពិចារណាអំពីបញ្ហានេះ ដោយគួរតែធ្វើយ៉ាងណាផ្តល់លិទ្ធភាពឲ្យគូភាគីទទួលបានចំណែកមួយដែលសមរម្យ និងអាចទទួលយកបានពីសំណាក់ភាគីទាំងសងខាង។ **<u>ឧទាហរណ៍ទី២៖</u>** លោក ម៉េង និងអ្នកស្រី លី បានរៀបការតាមផ្លូវច្បាប់ និងរស់នៅជាមួយគ្នាជាយូរឆ្នាំមកហើយ ហើយមានកូនម្នាក់ទៀតផង។ ប៉ុន្តែ ក្រោយមក អ្នកទាំងពីររស់នៅមិនចុះសម្រុងគ្នាចេះតែឈ្លោះប្រកែកគ្នារហូតមានការលែងលះ។ លោក ម៉េង ក៏បានដាក់ពាក្យបណ្តឹងសុំលែង និងសុខចិត្តប្រគល់កូន ព្រមទាំងអាហារកាតព្វកិច្ចទៅឱ្យប្រពន្ធ។[70] ចំពោះឧទាហរណ៍មួយនេះ ទោះជា

[66] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, *នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ*, ៣៩៥។
[67] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៦៤ កថាខណ្ឌ២។
[68] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៦៤ កថាខណ្ឌ៣។
[69] ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩, មាត្រា៧៦។
[70] សាលក្រមលែងលះ, លេខ ២០"ង", ២៧ កុម្ភៈ ២០១៨។

ប្ដីមិនបានបង្ហាញឆន្ទៈផ្ដល់អាហារកិច្ចក៏ដោយ ក៏តុលាការនៅតែពិចារណាថា អ្នកស្រី លី ដែលជាម្ដាយរបស់កូនអាចមានសមត្ថភាពគ្រប់គ្រាន់ និងអាចមើលថែកូនបានល្អជាងបុរសជាប្ដី ប៉ុន្តែអាចមានការលំបាកខ្លះទៅនឹងប្រាក់ចំណូល ដែលជាហេតុតម្រូវឱ្យប្ដីចូលរួមទទួលខុសត្រូវ។

ក្នុងករណីដែលភាគីមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធនោះទេ ការបែងចែកទ្រព្យនឹងត្រូវធ្វើតាមបញ្ញត្តិនៃច្បាប់។ ជាទូទៅ នៅក្នុងករណីដែលប្ដីប្រពន្ធលែងលះគ្នា ការបែងចែកទ្រព្យសម្បត្តិរួមត្រូវតែធ្វើឡើងដោយភាពយុត្តិធម៌សម្រាប់គូភាគី ដោយផ្អែកតាមការពិភាក្សារបស់អ្នកទាំងពីរ។[71] តាមបញ្ញត្តិនៃច្បាប់ សហព័ទ្ធនីមួយៗមានសិទ្ធិទទួលបាន ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម។ នៅក្នុងករណីពិសេសដោយមានការពិចារណាទៅលើស្ថានភាពនានាដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាដើម ភាគីប្ដីប្រពន្ធណាម្ខាងអាចទាមទារទៅតុលាការឲ្យធ្វើបែងចែកទ្រព្យរួមបាន។[72] ឧទាហរណ៍ដូចជាក្នុងករណីខ្លះដែលសហព័ទ្ធណាម្ខាងទទួលបានចំណែកទ្រព្យ ១ ភាគ ៣ ប្រសិនបើភាគីទើបរៀបអាពាហ៍ពិពាហ៍រយៈពេលខ្លី ឬសហព័ទ្ធនោះមិនបានចូលរួមបរិច្ចាគច្រើនចំពោះជីវភាពគ្រួសារ ហើយករណីខ្លះទៀត សហព័ទ្ធណាម្ខាងទទួលបាន ២ ភាគ ៣ ឬ ៣ ភាគ ៤ ប្រសិនបើសហព័ទ្ធនោះចាស់ជរា ឬមានវិបត្តិស្មារតី ឬរាងកាយ ឬក៏មានករណីខ្លះទៀតដែលប្រពន្ធត្រូវទុកលទ្ធភាពឲ្យទទួលបានចំណែកមួយចំនួនធំដើម្បីជាផលប្រយោជន៍នៃការអាស្រ័យនៅរបស់កូន ឬប្រពន្ធមិនមានលទ្ធភាពចិញ្ចឹមជីវិតដោយខ្លួនឯងបាន។ លើសពីនេះទៅទៀត ការបែងចែកអាចត្រូវបានអនុឡោមទៅតាមការបែងចែកជាក់លាក់តាមបញ្ញត្តិស្ដីពីកម្មសិទ្ធិអវិភាគក្នុងគន្ថីទី៣ស្ដីពី សិទ្ធិប្រត្យក្ស ដូចជា ការបែងចែកវត្ថុជាក់ស្ដែង ការបែងចែកតាមតម្លៃ ការបែងចែកតាមការសងជំនួស[73] និងការបែងចែកដោយផ្អែកលើការបង្កើតផលុបភោគ ជាអាទិ៍។ ឧទាហរណ៍ដូចជាការបែងចែកឡាន ដែលភាគីទាំងពីរអាចពិភាក្សាគ្នាថាបែងចែកជាមួយនឹងតម្លៃថ្នូរពីវត្ថុផ្សេង(ការដូរនឹងខ្សែកមាស ដែលមានតម្លៃប្រហាក់ប្រហែល) ការលក់បែងចែកតម្លៃ ឬ ការបង់ប្រាក់សំណងនៃចំណែកទៅឲ្យភាគីម្ខាងទៀតដែលមិនបានទទួល។

[71] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៨០ កថាខណ្ឌ១។
[72] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា៩៨០ កថាខណ្ឌ២ ចំណុច ខ។
[73] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧, មាត្រា២១២។

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវលើប្រធានបទ "ទ្រព្យសម្បត្តិសហាព័ទ្ធ" មួយរយៈពេលរួចមក យើងឃើញថា ប្រធានបទនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ទំនាក់ទំនងរវាងប្ដី និងប្រពន្ធ។ ប្រធានបទនេះ មិនត្រឹមតែមានប្រយោជន៍ដល់សហាព័ទ្ធទាំងសងខាងប៉ុណ្ណោះទេ តែវាក៏បានផ្ដល់អត្ថប្រយោជន៍ដល់ជនទូទៅមិនថាជា និស្សិត ចៅក្រម មេធាវី ឬមន្ត្រីរាជការនានានោះទេ ក្នុងការយកទៅស្វែងយល់ និងប្រើប្រាស់លើចំនុចសំខាន់ៗនៃប្រធានបទនេះ។

ជាក់ស្ដែង ក្រមរដ្ឋប្បវេណីក៏បានបញ្ញត្តិពីប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមច្បាប់កំណត់ និងតាមកិច្ចសន្យាផងដែរ ដើម្បីជាមាគ៌ាក្នុងការ ប្រើប្រាស់ គ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិឱ្យបានត្រឹមត្រូវ ជៀសវាងមានទំនាស់កើតឡើងនៅពេលលែងលះ។ ការកំណត់ពីប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមកិច្ចសន្យានៅក្នុងក្រមរដ្ឋប្បវេណីនៅមាត្រា ៩៦៩ និង៩៧០ គឺជាការកំណត់មួយ ដែលអនុញ្ញាតឱ្យមានសិទ្ធិលើការបង្កើតកិច្ចសន្យាប្ដីប្រពន្ធទៅលើទំនាក់ទំនងទ្រព្យសម្បត្តិ កំណត់កម្មសិទ្ធិករនៃទ្រព្យ កំណត់អំពីសិទ្ធិ និងកាតព្វកិច្ច កំណត់អំពីសិទ្ធិគ្រប់គ្រង និងចាត់ចែងជាដើម ប៉ុន្តែមិនអាចផ្ទុយនឹងបញ្ញត្តិនៃច្បាប់ទេ។ ការបង្កើតកិច្ចសន្យានេះទៀតសោត ទាមទារឱ្យមានការគោរពនូវលក្ខខណ្ឌទម្រង់ដែលតម្រូវឱ្យធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវមានការចុះបញ្ជីទើបអាចតតាំងនឹងតតិយជនបាន។ ចំណែកឯប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ចាប់ពីមាត្រា ៩៧១ ដល់ មាត្រា ៩៧៧ ក៏បានកំណត់ពីចំណាត់ថ្នាក់នៃទ្រព្យដោយឡែក ទ្រព្យរួម របៀបរបបក្នុងការគ្រប់គ្រង ប្រើប្រាស់ ចាត់ចែង និងការទទួលខុសត្រូវលើទ្រព្យសម្បត្តិជាដើម។

ក្រោយមក នៅថ្ងៃទី៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ ក្រសួងយុត្តិធម៌បានចេញប្រកាសមួយ ស្ដីអំពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដែលសហការរៀបរៀងឡើងជាមួយទីប្រឹក្សាផ្នែកច្បាប់របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ។ ប្រកាសនេះបានបើកឱកាសដល់ប្ដីប្រពន្ធដែលមានបំណងចុះបញ្ជីទ្រព្យសម្បត្តិប្ដីប្រពន្ធនេះអាចទៅចុះបញ្ជីបានទៅតាមបែបបទ និងទម្រង់ដែលមានចែងក្នុងប្រកាសនេះ។

នៅក្នុងសង្គមខ្មែរបច្ចុប្បន្ន ទោះជាមានបញ្ញត្តិច្បាប់ខ្លះៗទាក់ទងលើទ្រព្យសម្បត្តិសហាព័ទ្ធក៏ដូចជាប្រកាសស្ដីពីនីតិវិធីក្នុងការចុះបញ្ជីកិច្ចសន្យាប្ដីប្រពន្ធក្ដី ក៏នៅមានបញ្ហាជម្លោះកើតឡើងជាបន្តបន្ទាប់ស្ដីពីទ្រព្យសម្បត្តិនេះនៅពេលសហាព័ទ្ធលែងលះ។ នៅពេលមានជម្លោះកើតឡើងតែងតែមានការលំបាកក្នុងការដោះស្រាយ ដោយសារខ្វះភស្តុតាងបញ្ជាក់ថាទ្រព្យណាមួយជាទ្រព្យរួម ឬទ្រព្យដោយឡែក។ ជាពិសេស ប្រជាជនខ្មែរមិនសូវនិយមបង្កើតកិច្ចសន្យាទ្រព្យនេះដូចបណ្ដាប្រទេសដទៃទៀតទេ ដែលនាំឱ្យមានការលំបាកនៅពេលលែងលះ ហើយត្រូវបែងចែកទ្រព្យ។

ដោយសារមើលឃើញពីភាពខ្វះចន្លោះក្នុងការយល់ដឹងពីប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធនេះ ពួកយើងក៏បានធ្វើការស្រាវជ្រាវលើប្រធានបទនេះ។ ប្រធានបទនេះ បានធ្វើឡើងដើម្បីឆ្លុះបញ្ចាំងពីភាពស្រពិចស្រពិលមួយចំនួនដែលប្ដីប្រពន្ធភាគច្រើនមានការភ័ន្តច្រឡំ និងមិនច្បាស់លាស់ទៅលើទំនាក់ទំនងនៃទ្រព្យសម្បត្តិដែលបុគ្គលជាប្ដីប្រពន្ធមាន មិនថាជាទ្រព្យដោយឡែក ឬ ជាទ្រព្យរួមនោះទេ។

ឆ្លងកាត់ការរៀបរាប់ពីប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធខាងលើនេះ បញ្ជាក់ឱ្យឃើញថាការយល់ដឹងលើប្រព័ន្ធទ្រព្យសម្បត្តិសហាព័ទ្ធនេះពិតជាមានសារៈសំខាន់ណាស់ដល់បុគ្គលដែលនឹងត្រូវរៀបការជាមួយគ្នា ក៏ដូចជាប្ដីប្រពន្ធដែលបានរៀបការរួចមកហើយ ក្នុងការប្រើប្រាស់ ចាត់ចែងទ្រព្យទៅតាមលក្ខខណ្ឌត្រឹមត្រូវនៃគតិយុត្តិ។

# អនុសាសន៍

នៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធនេះ វាទាមទារឱ្យសហព័ទ្ធត្រូវគោរពតាមនីតិវិធីច្បាប់ដែលមានចែងដើម្បីឱ្យទំនាក់ទំនងទ្រព្យសម្បត្តិប្ដីប្រពន្ធមានភាពត្រឹមត្រូវ។ ផ្ទុយមកវិញ បើសិនជាប្ដីប្រពន្ធមិនបានគោរពទៅតាមគោលការណ៍ច្បាប់ នោះទំនាក់ទំនងនៃទ្រព្យសម្បត្តិរបស់ពួកគេនឹងឈានដល់វិវាទនៅថ្ងៃណាមួយជាក់ជាមិនខាន។

បន្ទាប់ពីមើលឃើញនូវចំណុចខ្វះខាតកន្លងមក ក្រុមយើងខ្ញុំសុំផ្ដល់នូវអនុសាសន៍មួយចំនួនទាក់ទងទៅនឹងប្រធានបទនេះ។ សហព័ទ្ធដែលមានបំណងរៀបអាពាហ៍ពិពាហ៍ ឬ រៀបអាពាហ៍ពិពាហ៍រួចហើយក្ដី គួរតែបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធនេះ ដោយសារវាជាការប្រសើរមួយក្នុងការធ្វើឱ្យមានភាពច្បាស់លាស់ទៅលើទ្រព្យសម្បត្តិរបស់ពួកគេ។ សហព័ទ្ធគួរណាស់តែគិតពីផលវិជ្ជមាននៃកិច្ចសន្យានេះ ជាជាងផ្ទត់គំនិតដែលមានពីមុនៗដែលគិតថាកិច្ចសន្យានេះប៉ះពាល់ដល់ទំនាក់ទំនងល្អនៃប្ដីប្រពន្ធ ឬចំណងក្ដីស្រឡាញ់ជាដើម។ ជាពិសេសសហព័ទ្ធដែលចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវតែធ្វើដោយឆន្ទៈ និងស្របតាមច្បាប់កំណត់។ បន្ថែមពីនេះ ប្ដីប្រពន្ធត្រូវមានការពិភាក្សាគ្នាទៅលើការគ្រប់គ្រង ចាត់ចែងទ្រព្យសម្បត្តិទាំងទ្រព្យរួម និងដោយឡែក ដើម្បីឈានឆ្ពោះទៅកាន់អនាគតល្អនៃគ្រួសារ ដែលមានសុភមង្គល និងដើម្បីការចិញ្ចឹមបីបាច់កូន។ ចុងក្រោយ រាជរដ្ឋាភិបាល រួមជាមួយអង្គការសង្គមស៊ីវិលនានា ត្រូវរួមសហការគ្នាឱ្យល្អបន្ថែមទៀត ក្នុងការធ្វើអោយប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធនេះមានភាពប្រសើរឡើង ក៏ដូចជាធ្វើការអប់រំ និងផ្សព្វផ្សាយបន្តទៀតដល់ប្រជាពលរដ្ឋអោយមានការយល់ដឹងកាន់តែច្រើនលើប្រព័ន្ធនេះ ហើយអនុវត្តតាមទាំងអស់គ្នាឱ្យមានប្រសិទ្ធិភាព។